ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Premiere instance

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 20-Apr-2017, 10:52
CMS/CFO: Sann Rada

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី
# ជំនុំជម្រះក្តីនៅដំណាក់កាលពីរ

**សាធារណៈ**

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី២៣ ខែមេសា ឆ្នាំ២០១៥**

**ម៉ោង ០៩:០២នាទី**

**សវនាការលើកទី២៧២**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ក្លូឌា ហ្វេនស៍
*(Judge Claudia FENZ)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវ៉ែន៍
*(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្ដរា

ចៅក្រម ធូ មណី (បម្រុង)

ចៅក្រម ម៉ាទីន ខារ៉ុបគីន (បម្រុង)
*(Judge Martin KAROPKIN)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោក ឯម ហ៊ុយ

កញ្ញា ជា ស៊ីវហ៊ាង

កញ្ញា រ៉ូប៊ីន្នី ក្រូហ្វត៍ *(Ms. Robynne CROFT)*

លោក រូស្សែល ហប់គីនស៍
*(Mr. Russell HOPKINS)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

កញ្ញា សុង ឆវ័ន្ត

លោក ឌេល លីសាក់ *(Mr.Dale LYSAK)*

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក វិចទ័រ កូប៉េ*(Mr.Victor KOPPE)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

លោក អាកទួរ វែកគែន

*(Mr. Arthur VERCKEN)*

**មេធាវីប្រចាំការលោក ខៀវ សំផន៖**

លោកស្រី ទូច វរល័ក្ស

លោក ខលវីន សោនដឺស៍

*(Mr Calvin SAUNDERS)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោកស្រី ម៉ារី ហ្គីរ៉ូដ៍*(Ms.Marie GUIRAUD)*

លោក ហុង គឹមសួន

លោក វ៉េន ពៅ

លោកស្រី ស៊ីន សុវ៉ន

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុច អរុណ

លោកស្រី សួ សុទ្ធាវី

**បញ្ជីឈ្មោះអ្នកនិយាយ៖**

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ហ្សង់ម៉ាក ឡាវែន៍ | បារាំង |
| លោកស្រី ស៊ីន សុវ៉ន | ខ្មែរ |
| លោកស្រី ម៉ារី ហ្គីរ៉ូដ៍ | បារាំង |
| លោក រ៉ិចទ័រ កូប៉េ | អង់គ្លេស |
| លោក ពេជ្រ ជឹម (2-TCCP-809) | ខ្មែរ |

# ឧបសម្ព័ន្ធ

**ការសួរសំណួរទៅសាក្សី: លោក ពេជ្រ ជីម** (2-TCW-809)

សួរដោយលោកស្រី ស៊ីន សុវ៉ន ផ្ដើមពី ....................................................................ទំព័រ ៣
សួរដោយលោកស្រី ម៉ារី ហ្គីរ៉ូដ៍ ផ្ដើមពី ....................................................................ទំព័រ ៩
សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៍ ផ្ដើមពី ..............................................................ទំព័រ ២០
សួរដោយប្រធានអង្គជំនុំ ផ្ដើមពី ..............................................................................ទំព័រ ៣៦
សួរដោយលោក វ៉ិចទ័រ កូប៉េ ផ្ដើមពី.........................................................................ទំព័រ ៤២

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៩:០២:៤៣]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ ហើយនៅសវនាការនៅថ្ងៃនេះ អង្គជំនុំជម្រះធ្វើសវនាការស្ដាប់សក្ខីកម្មសាក្សី ពេជ្រ ជឹម បន្ត។

ក្រឡាបញ្ជីសវនាការ កញ្ញា ជាស៊ីវហ៊ង ឡើងរាយការណ៍អំពីស្ថានភាពវត្តមាន អវត្តមានភាគី និងបុគ្គលដែលអង្គជំនុំជម្រះកោះអញ្ជើញឱ្យចូលរួមនៅក្នុងកិច្ចដំណើរការសវនាការថ្ងៃនេះ។

**ក្រឡាបញ្ជី៖**

សូមគោរពលោកប្រធាន សម្រាប់សវនាការនៅថ្ងៃនេះ ក្រឡាបញ្ជីកត់សម្គាល់ឃើញថាគ្រប់ភាគីទាំងអស់នៃរឿងក្ដីនេះមានវត្តមាន លើកលែងតែលោក សុន អរុណ មេធាវីជាតិការពារក្ដីឱ្យលោកនួន ជា អវត្តមានដោយមូលហេតុសុខភាព។ ដោយឡែកលោក នួន ជា មានវត្តមាននៅបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការនេះ ដោយលោកស្នើសុំលះបង់សិទ្ធិមានវត្តមានដោយផ្ទាល់ពីបន្ទប់សវនាការ។ លិខិតលះបង់សិទ្ធិរបស់ជនជាប់ចោទ នួន ជា បានប្រគល់ដល់ក្រឡាបញ្ជីរួចហើយ។ សាក្សី ដែលត្រូវមកផ្ដល់សក្ខីកម្មបន្តនៅថ្ងៃនេះ គឺលោក ពេជ្រ ជឹម។ លោក និងមេធាវីប្រឹក្សាលោក មឿន សុវណ្ណ មានវត្តមានរួចហើយនៅក្នុងបន្ទប់សវនាការនេះ។ សូមអរគុណលោកប្រធាន។

[០៩:០៤:០៩]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ កញ្ញា ស៊ីវហ៊ង។

បាទ ឥឡូវនេះ អង្គជំនុំជម្រះសម្រេចលើសំណើសុំរបស់ជនជាប់ចោទ នួន ជា ជាមុនសិន។

អង្គជំនុំជម្រះបានទទួលលិខិតសុំលះបង់សិទ្ធិចូលរួមសវនាការដោយផ្ទាល់ ក្នុងបន្ទប់សវនាការនេះរបស់ជនជាប់ចោទ នួន ជា ចុះថ្ងៃទី២៣ ខែមេសា ឆ្នាំ២០១៥ ដែលបញ្ជាក់ថា ដោយគាត់មានបញ្ហាសុខភាព ឈឺក្បាល ឈឺចង្កេះ មិនអាចអង្គុយយូរបាន មិនអាចផ្ចង់អារម្មណ៍បានយូរ និងដើម្បីមានលទ្ធភាពចូលរួមសវនាការនៅថ្ងៃមុខឱ្យមានប្រសិទ្ធភាព ខ្លួនសុំលះបង់សិទ្ធិចូលរួម និងមានវត្តមានដោយ

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឱ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ផ្ទាល់នៅក្នុងបន្ទប់សវនាការនៅថ្ងៃទី២៣ ខែមេសា ឆ្នាំ២០១៥។ ដោយមេធាវីការពារក្ដីរបស់ខ្លួន បានប្រាប់អំពីផលប៉ះពាល់ នៃការលះបង់សិទ្ធិនេះថា ការលះបង់សិទ្ធិនេះមិនអាចបកៗស្រាយថា ជាការលះបង់សិទ្ធិរបស់ខ្លួនក្នុងការកាត់សេចក្ដីដោយយុត្តិធម៌ ឬក៏សិទ្ធិក្នុងការជំទាស់ ទៅនឹងភស្តុតាងក្នុងការដាក់បង្ហាញ ឬដាក់ជូនតុលាការនេះគ្រប់ពេលនៃសវនាការលើរូបខ្លួនឡើយ។

បានឃើញកំណត់ហេតុពិនិត្យសុខភាពជនជាប់ចោទ នួន ជា ដែលធ្វើឡើងដោយគ្រូពេទ្យប្រចាំការ ពិនិត្យព្យាបាលថែទាំសុខភាពជនជាប់ចោទនៅ អ.វ.ត.ក ចុះថ្ងៃទី២៣ ខែមេសា ឆ្នាំ២០១៥ បានកត់សម្គាល់ថាស្ថានភាពសុខភាពរបស់ជនជាប់ចោទលោក នួន ជា មានអការៈឈឺចង្កេះរ៉ាំរ៉ៃ និងឈឺកាន់តែខ្លាំងនៅពេលអង្គុយយូរ។ និងបានផ្ដល់អនុសាសន៍សូមឲ្យអង្គជំនុំជម្រះអនុញ្ញាតឲ្យលោក នួន ជា ចូលរួម តាមដានកិច្ចដំណើរការសវនាការពីបន្ទប់ខាងក្រោមសាលសវនាការនេះ។ ផ្អែកលើមូលដ្ឋាននេះ និងយោងតាមបទប្បញ្ញត្តិនៃវិធាន៨១(៥) នៃវិធានផ្ទៃក្នុងអ.វ.ត.ក អង្គជំនុំជម្រះយល់ព្រម និងអនុញ្ញាតឲ្យជនជាប់ចោទ នួន ជា បន្តចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅក្រោមសាលសវនាការនេះ  តាមរយៈឧបករណ៍សោតទស្សន៍សម្រាប់រយៈពេលសវនាការពេញមួយថ្ងៃនេះ។

បង្គាប់ឲ្យបុគ្គលផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទ នួន ជា អាចចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយពីបន្ទប់ឃុំខ្លួនមួយស្ថិតក្រោមសាលសវនាការនេះក្នុងអំឡុងពេលនៃដំណើរការសវនាការសម្រាប់ថ្ងៃនេះ។

បាទ  ជាបន្តទៅនេះអង្គជំនុំជម្រះផ្ដល់វេទិកាជូនទៅតំណាងដើមបណ្ដឹងរដ្ឋប្បវេណី  ដើម្បីមានឱកាសក្នុងការតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះ។

[០៩:០៦:២៥]

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

សូមអរគុណលោកប្រធាន។ ខ្ញុំសូមផ្ដល់វេទិកានេះជូនសហភាតាខ្ញុំ ហើយបន្ទាប់មកទៀតបានខ្ញុំសួរសំណួរដោយខ្លួនខ្ញុំផ្ទាល់។ សូមអរគុណលោកប្រធាន។

**លោកស្រី ស៊ីន សុវ៉ន៖**

ចាស សូមអរគុណលោកប្រធាន។ ចាស សូមជម្រាបសួរលោកប្រធាន ហើយនិងអង្គសវនាការទាំងមូល។

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ការតាំងសំណួរដោយសហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី**

**សួរដោយលោកស្រី ស៊ីន សុវ៉ន៖**

**ស៖** សូមជម្រាបសួរដែរ លោកសាក្សី។ ចាស ខ្ញុំឈ្មោះ ស៊ីន សុវ៉ន ជាមេធាវីនៅអង្គការក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា ហើយជាមេធាវីតំណាងឲ្យដើមបណ្តឹងក្នុងសំណុំរឿង០០២។ ចាស យើងកន្លងមកយើងឃើញហើយថា លោកបានឆ្លើយសំណួរជាច្រើនជាមួយសហព្រះរាជអាជ្ញាអន្តរជាតិ ពាក់ព័ន្ធនឹងជុំវិញទៅនឹងបញ្ហាសហករណ៍ត្រាំកក់ និងក្រាំងតាចាន់។ ចាស យើងឃើញហើយថា លោកជាសាក្សីមួយដ៏សំខាន់ ដើម្បីស្វែងរកការពិត និងយុត្តិធម៌ជូនជនរងគ្រោះ ក៏ដូចជាជូនសង្ស័យ។ ចាស អ៊ីចឹងនៅពេលនេះ សូមលោកមេត្តាសហការបន្តជាមួយនឹងខ្ញុំ ដើម្បីស្វែងរកការពិតហ្នឹង។

ដំបូងខ្ញុំចង់សួរលោកពាក់ព័ន្ធនឹងការរៀបការដោយបង្ខំក្នុងសម័យខ្មែរក្រហម។ ក្នុងសំណួរទី១ ខ្ញុំចង់សួរលោកថាក្នុងនាមលោកសាក្សីដែលជាលេខាស្រុក១០៥ តើលោកមានបានដឹងពីគោលនយោបាយនៃការរៀបការនេះទេ?

[០៩:០៨:១១]

**លោក ពេជ្រ ជឹម៖**

**ឆ៖** សូមមានយោបល់ ពីគោលនយោបាយនៃការរៀបការនេះ ខ្ញុំបានដឹងមិនមានជាច្បាប់បញ្ញត្តិមាត្រាអីមួយពីរអីច្បាស់លាស់ទេ។ តែផ្សាយតៗតាមរយៈពីលើចុះក្រោម ថ្នាក់ដឹកនាំចុះមក ក៏ដឹងតាមហ្នឹងទៅ ហើយរួមគ្នាអនុវត្តធ្វើតាម។ ដូចខ្ញុំបញ្ជាក់វែងហើយម្សិលមិញ។

**ស៖** ចាស សូមអរគុណ។ អ៊ីចឹង ខ្ញុំចង់សួរលោកសាក្សីបន្តថា តើគោលនយោបាយហ្នឹងថ្នាក់ណាដែលមានសិទ្ធិបង្កើត និងឲ្យថ្នាក់ក្រោមហ្នឹងផ្សព្វផ្សាយតៗគ្នាហ្នឹង?

**ឆ៖** មិនដឹង--

**ប្រធានអង្គជំនុំ៖**

សូមកុំអាលទាន់ឆ្លើយតបលោកពេជ្រ ជឹម ក្បាលមីក្រូហ្វូនអត់ទាន់ប្រតិបត្តិការអំមិញ។ អ៊ីចឹងសំឡេងរបស់លោកអត់ចូលទៅប្រព័ន្ធចែកចាយសំឡេងនៅក្នុងបន្ទប់សាលសវនាការនេះទេ។ សូមលោករង់ចាំឆ្លើយនៅពេលក្បាលមីក្រូហ្វូនប្រតិបត្តិការដោយឲ្យសញ្ញាភ្លើងក្រហម។

**លោក ពេជ្រ ជឹម៖**

**ឆ៖** តាមពិតគឺការបញ្ញត្តិធ្វើនេះរួមគ្នាពិគ្រោះក្នុងតំបន់ ស្រុក ក្រោមការណែនាំគោលៗពីភូមិ

ភាគមកក៏ធ្វើទៅ។ ដល់ធ្វើទៅ តាមខ្ញុំឃើញ ពិនិត្យមិនដិតដល់ គេតាមការស្នើៗ គេថាគេព្រមហើយៗ នៅប្រហោងហ្នឹង -- ប្រុងនឹងហៅមកសួរផ្ទាល់មាត់ទាំងអស់គ្នា ស្រុករវល់ការងារច្រើន ប្រគល់ឃុំសួរផងទៅ ឃុំប្រគល់មេកងទៅ។ ដល់ពេលធ្វើពិធីសម្រេច អ្នកដែលគេពេញចិត្តទាំងសងខាង គេរីករាយ អ្នកដែលមិនពេញចិត្តសងខាង មួយរយៈក៏គេលែងគ្នា។ លទ្ធផលអ៊ីចឹង សូមជម្រាប។

**សួរដោយលោកស្រី ស៊ីន សុវ៉ន៖**

**ស៖** ចាស សូមអរគុណ។ អ៊ីចឹង សូមឲ្យលោកបញ្ជាក់ជូនអង្គជំនុំជម្រះឲ្យច្បាស់មើល៍ គោលនយោបាយនៃការរៀបការ ដែលលោកថាអនុវត្តតៗគ្នា។ ពេលនុ៎ង អនុវត្តទូទាំងប្រទេស ឬក៏ម៉េចដែរលោក?

[០៩:១១:១២]

**ឆ៖** ខ្ញុំមិនដឹងទូទាំងប្រទេសទេ ខ្ញុំដឹងតែផ្នែកដែលខាងធ្វើនៅនិរតីនេះមានធ្វើអ៊ីចឹង។ តែ៣៣ ក៏មិនដឹងគេធ្វើម៉េចដែរ អត់ដឹង។ ៣៥ ក៏មិនដឹងធ្វើម៉េច អត់ដឹង។ សូមអស់។

**ស៖** ចាស សូមអរគុណ។ ចាស អម្បាញ់មិញ លោកមានប្រសាសន៍ថា គូដែលៗរៀបការហ្នឹង គូខ្លះក៏ព្រមព្រៀង គូខ្លះមិនព្រមព្រៀង ក៏លែងលះគ្នាទៅ។ ខ្ញុំចង់ជម្រាបសួរលោក ឬក៏ចង់ឲ្យលោកបញ្ជាក់ជូនអង្គជំនុំជម្រះឲ្យច្បាស់ថា គូដែលដូចថាទៅរៀបការហ្នឹង ដូចថាបានស្រឡាញ់គ្នា ឬក៏បានព្រមព្រៀងគ្នា ក្នុងឆ្នាំណាដែរលោក ក្នុងឆ្នាំ៧៥ ឬក្នុង៧១, ៧២? ខ្ញុំចង់ឲ្យលោកបញ្ជាក់ឲ្យច្បាស់។ ក្នុងអំឡុងឆ្នាំ៧៥ ឬក៏ឆ្នាំណា ចាស?

**ឆ៖** សូមជម្រាប រៀបការច្រើន ៧៥នេះទេ។ ៧១, ៧២, ៧៣ នៅក្នុងសង្គ្រាម មិនមានទេ មានមួយៗ។ ហើយឲ្យធ្វើស្ងាត់ បើគគ្រឹកគគ្រេងមានភ្លេងភ្លាត់ទៅ ប៉ះពាល់ដល់អ្នកទៅសមរភូមិដែលខំទៅច្បាំង ហើយគេការគគ្រឹកគគ្រេង ហៅថាចលនាទៅមកភូមិអត់ចូល។ អ៊ីចឹង ធ្វើដោយលួចលាក់អ្នកយល់ព្រម ៧១, ៧២, ៧៣ នេះ។ ដល់៧៥ គឺមានទ្រង់ទ្រាយធំ ចំនួនក៏ច្រើន ហើយពេលឱកាសវេលារំដោះទូទាំងប្រទេសហើយ ហ្នឹងមួយ។ ពីរ ពិនិត្យថាយុវជននិងនារីភេទ ក៏មានវ័យចាស់ជរាហើយ អ៊ីចឹងក៏ហៅថាបន្ធូរៗច្បាប់ កុំតឹងពេកសម្រួលមកឲ្យវាការច្រើនៗទៅ។ រៀបម្ដងមួយក្រុមពីរក្រុមអ៊ីចឹងទៅ។ ដល់ឮថាធូរហើយ មនុស្សចេះតែចង់លឿន ចង់របស់ ក៏ធ្វើទៅវាខ្លាំងទៅ វាច្រើន វាមានទ្រង់ទ្រាយធំ មិនមែនមានច្បាប់បញ្ជាថាឲ្យធ្វើអ៊ីចឹងហ្នុង អត់ទេ។ វាររបៀបជាគ្រួសារ ដឹកនាំកាលនោះរបៀបជាគ្រួសារប្រាប់ៗគ្នាធ្វើទៅ។ តាមប្រពៃណីអត់ឲ្យយកគ្នា អត់ការ -- អត់ខុសប្រពៃណី ត្រង់ន័យ

ថាបានគោរព។ ឲ្យដូនតាម៉ែឪ បងប្អូន មហាជនជុំវិញដឹង ទុកជាពេញច្បាប់ ហើយសន្មតអ៊ីចឹង។

[០៩:១៤:៤២]

**ស៖** ចាស--

**ឆ៖** សូមអស់។

**ស៖** ចាស សូមអរគុណ។ លោកជម្រាបអម្បាញ់មិញ លោកថាក្នុងឆ្នាំ៧៥ គឺការរៀបការហ្នឹងមានទ្រង់ទ្រាយធំ មានគ្នាច្រើន ហើយច្បាប់ធូររលុង។ ខ្ញុំចង់ឲ្យៗលោកបញ្ជាក់ថា ទ្រង់ទ្រាយធំ ហើយច្បាប់ធូររលុង ធូររលុងរបៀបម៉េចលោក?

**ឆ៖** ធូរន័យថា គេស្នើឲ្យៗ មែនធូររលុងអាណាធិបតេយ្យ កុំតឹងពេក។ គេស្នើយល់ព្រមទាំងពីរហើយ សងខាងហើយឲ្យគេទៅ។ ហើយឲ្យទៅ គឺយើងយល់ព្រមឲ្យមេកង មេឃុំរៀបចំ។

**ស៖** ចាស សូមអរគុណ។ អ៊ីចឹង ខ្ញុំសូមសួរលោកបន្តថា លោកជម្រាបអង្គជំនុំជម្រះអម្បាញ់មិញថា គូដែលរៀបការសុទ្ធតែគេយល់ព្រម។ ចាស ហើយខ្ញុំចង់សួរថាដែលការទាំងគូៗ គេយល់ព្រមទាំងអស់គ្នា ឬក៏មានការចាប់បង្ខំដែរ?

[០៩:១៦:០៨]

**ឆ៖** ត្រង់ហ្នឹងខ្ញុំក្ដាប់អត់បាន។ មិនមានឃើញបង្ខំមុខព្រួញខ្ញុំ។ សុទ្ធតែហៅសួរទាំងសងខាង។ ប៉ុន្តែឃើញខ្វះខាតត្រង់ ស្នើហើយយល់ព្រមក្នុងសំបុត្រ ហើយប្រាប់មេកង មេឃុំ ត្រួតពិនិត្យ។ ត្រង់គ្រប់ថ្ងៃដែលរៀបចំពិធីហ្នឹង ប្រាំមួយ ប្រាំពីរថ្ងៃរៀបចំពិធី។ ពិនិត្យមើលល្អិតត្រង់ថា ឃុំសួរផ្ទាល់ខ្លួនអស់នៅ។ ពេលមកដល់ពិធីរៀប ក្នុងនាមផ្នែកស្រុកនិងផ្នែកអង្គការ គឺសួរថែម។ សួរថែមមក ខ្លះក៏ឆ្លើយតាមសម្រួល និងមានខ្លះគាត់ឆ្លើយរដិបរដុប។ វាអ៊ីចឹងដែលខ្ញុំថា មួយចំនួនតូចក៏វាអត់ទាន់ជ្រះស្រឡះ។ បើអត់ទាន់ជ្រះស្រឡះអ៊ីចឹង ទោះចង់មិនចង់ គេថាយើងចាប់បង្ខំហើយ។ ហ្នឹងមួយ។ ពីរ ដូចធ្វើពិធីឲ្យឃុំធ្វើតាមក្រុមៗ ប្អូនដប់នាក់ៗ។ ច្រើនឃុំ ហៅអាបងទៅធ្វើដែរទៅ។ បងហ្នឹងគឺសំដៅ ខុមគាត់ស្រី ជាម៉ែ ហើយកូនក្រមុំគាត់ទាំងអស់។ កូនក្រមុំទាំងអស់នៅជាមួយគាត់ហ្នឹងឯង រាប់រយ រាប់ពាន់។ បើគាត់រួមធ្វើដែរ ១០ឃុំ ១២ឃុំ មកមូលនៅមួយកន្លែង វាមិនធំ បើគាត់កុំចូល បើបំបែក មកធ្វើតាមឃុំ អាហ្នឹងវាតូច។ ហើយដល់១២ បើឃុំ១០០ ដប់ពីរ មិន១០០០ជាង។ មួយឃុំ១០នាក់ ១២ឃុំជាង១០០ហ្នឹង ទ្រង់ទ្រាយធំហ្នឹង សូមជម្រាបអ៊ីចឹង។ ប្រធាននារីកងៗហ្នឹង បងធ្វើៗ ធ្វើអធិបតី។ ដល់វាញ្ញ

អ៊ីចឹង គ្នាធ្វើហើយ។ ដល់ធ្វើទៅ វាទ្រង់ទ្រាយធំទៅ។

[០៩:១៨:៣៨]

**ស៖** ចាស សូមអរគុណ។ ចាស អ៊ីចឹង រាល់ការការរៀបការហ្នឹង ដែលលោកសង្កេតឃើញ លោកតាមរយៈប្រធានកង។ លោកឲ្យប្រធានកង ឲ្យទៅសួរសាមីខ្លួនពេញចិត្ត ឬក៏មិនពេញចិត្តអ៊ីចឹង។ ចុះឪពុកម្ដាយ ឬក៏អាណាព្យាបាលរបស់គេហ្នឹង តើគេមានការឯកភាពទទួលយក ដូចថាឲ្យកូនគេមានគូស្វាមីជាមួយអ្នកផ្សេងហ្នឹងដែរកន្លងមក លោកដែលបានជ្រាបបញ្ហាហ្នឹងទេ?

**ឆ៖** បញ្ហាហ្នឹង ខ្ញុំក៏បានរួមចំណែកធ្វើជាមួយ។ ពេលធ្វើរួមអ៊ីចឹង មកដល់ខ្ញុំហៅសួរថែម មិនជឿថាអ្នកនោះសួរច្បាស់ហើយ ហៅសួរថែម។ សួរទៅព្រមៗ ឲ្យអត់ អត់មាន ដែលក្នុងពេលសួរហ្នឹងអត់មាន។ គ្រាន់តែរាងចង់ថាអត់ផង មិនចង់ថារាងស្ទាក់ស្ទើរ។ ដល់អ៊ីចឹងឃើញក្នុងចិត្តថា ច្បាស់ជាខ្លាចហើយ ថាទេទៅខ្លាច។ មិនថាទេ ហាក់ដូចជាមិនពេញចិត្ត។ ខ្ញុំថា បង្ខំឲ្យថាតែម្ដង។ បើមានអ៊ីចឹងខ្ញុំដកទុកក្រោយ។ អាហ្នឹងទាល់តែខ្ញុំចូលរួមបានធ្វើជាមួយបង ខុម ហ្នឹង។ ឯងទៃទៀត វាអាចមាន គេធ្វើតាមមន្ទីរគេនៅឆ្ងាយ ក្នុងព្រៃ ជាក្រុមប្អូនដប់នាក់ អីយ៉ាងម៉េច អាហ្នឹងក្ដាប់អត់បានទេ សូមជម្រាប។ ក្រែងវាមានតែគាត់ត្រង់ហ្នឹង។ អ្នកឃ្លាតឆ្ងាយ វានៅជិតមេ គេនោះមានមេដែរ មេនោះសម្ភុតអាម៉េច អាហ្នឹងខ្ញុំក្ដាប់អត់បានទេ។

**ស៖** ចាស សូមអរគុណ។ ចាស អ៊ីចឹងខ្ញុំចង់ជម្រាបសួរលោកបន្តថា ពិធីរៀបការហ្នឹង ចង់សួរថាតើគេធ្វើតាមប្រពៃណីខ្មែរយើងដូចជាមានការស្ដាប់លោកសូត្រមន្ត សែនចងដៃ កាត់សក់អីៗ...។ល។ មានបានធ្វើរបៀបជាអ៊ីចឹងដែរលោក?

**ឆ៖** អត់ធ្វើទេ កាលនោះភ្លេងក៏មិនដឹងមាននៅឯណាទេ បាត់អស់ហើយ។ គឺមានពិធីគោរពវិញ្ញាណក្ខន្ធ ប្រកាសហេតុ គោរពវិញ្ញាណក្ខន្ធ ហើយអញ្ជើញគូទី១ និងទី២ មកបង្ហាញមុខ ហើយយកកៅអីឲ្យអង្គុយ មកបង្ហាញហើយ សាមីខ្លួនមានយោបល់ទទួលព្រម មិនព្រម។ សាមីខ្លួនទទួលឯកភាពយល់ស្របព្រមយកគ្នាជាគ្រួសារហើយ អង្គុយទន្ទឹមគ្នាហ្នឹង។ ហៅមួយទៀតមក ហៅមក។ គូទី២ចាប់អារម្មណ៍ហើយមានយោបល់បញ្ចេញយោបល់ហើយ ទៅអង្គុយ ទី៣ ទី៤ រហូតអស់។ ហើយចប់ប្រកាសហេតុ ចប់ពិធីហ្នឹង ប្រធានអង្គប្រជុំឲ្យពរ ណែនាំ ជូនពរគូស្វាមីទាំងអស់ ហើយនិងសមាជិកដែលចូលរួមជូនពរដល់គូស្វាមីថ្មីទាំងអស់។ ពិធីបញ្ចប់ជប់លៀងម្ហូបបាយតាមលទ្ធភាពដែលមាន ជាបបរ ជាបង្អែម ឬជាបាយ។

[០៩:២៣:២៨]

**ស៖** ចាស សូមអរគុណ។ អ៊ីចឹងខ្ញុំចង់សួរលោកបន្តថា ភាគច្រើនពិធីហ្នឹងច្រើនចាប់ផ្តើមនៅពេលយប់ ឬក៏ពេលណាដែលលោក ពិធីរៀបការហ្នឹង?

**ឆ៖** ពិធីរៀបការនេះ រៀបចំពេលថ្ងៃ ថ្ងៃព្រឹកអ៊ីចឹង ទម្រាំចប់ពិធីរសៀល ម៉ោងមួយ ម៉ោងអីហ្នឹង ទៅហូបបាយហើយ។

**ស៖** ចាស អរគុណ។ អ៊ីចឹងក្រោយពេលដែលចប់ពិធីហើយ តើគូស្វាមីភរិយាមួយៗហ្នឹង គេទៅសម្រាកនៅទីណាដែរ? គេមានធ្វើជារោងសម្រាប់ឲ្យមួយគូៗស្នាក់នៅ ឬក៏ម៉េចដែរលោក?

**ឆ៖** សូមបញ្ជាក់ថា ផ្ទះណានៅមានបងប្អូនម៉ែឪជិត ឲ្យទៅផ្ទះម៉ែ ឪពុកម្តាយ ទៅគោរពឪពុកម្តាយផង បងប្អូនជុំវិញហ្នឹងផង ស្គាល់ផ្ទះម៉ែឪផង ហើយដេកនោះទៅ។ ហើយឲ្យច្បាប់ការងារមួយរយៈមិនកំណត់ទេកាលនោះ ស្រេចមេកងគេកំណត់ អន់ណាស់ក៏ ៧ថ្ងៃទៅកន្លះខែដែរ ឲ្យនៅផ្ទះជួបជុំម៉ែឪ។

**ស៖** ចាស អរគុណ។ លោកដែលធ្លាប់សង្កេតឃើញ ឬក៏ដែលធ្លាប់បានដឹងព័ត៌មានតៗគ្នាថានៅពេលយប់ហ្នឹងមានឈ្លបលប ដូចថាតាមដានគូស្វាមីភរិយាដែលរៀបការថ្មីថ្មោងហ្នឹង លោកមានបានដឹងទេ លោកមានបានជ្រាបបញ្ហាហ្នឹងដែរ?

[០៩:២៥:៤០]

**ឆ៖** អត់ដែលបានដឹងច្បាស់លាស់ទេ ប៉ុន្តែក្រោយៗមក ចេះតែឮហុយៗ ដូចគាត់ថាអ៊ីចឹង ថាឈ្លបលបស្តាប់ លបស្ទី។ ប៉ុន្តែអារឿងហ្នឹង តាមខ្ញុំយល់ មិនមែនមានកងឈ្លបឯណាមកពិនិត្យអ្នកការថ្មីម៉េច អត់ទេ។ រឿងអ៊ីចឹង ប្រធាននារីហ្នឹង ដូចជាម៉ែ គ្រប់គ្រង៥០ ឬ១០០នាក់ ការកូនហើយ ចង់ដឹងកូនហ្នឹង វាចុះដំណេកគ្នាអត់ ម្ល៉ោះហើយប្រើនារីគ្នាឯងហ្នឹង ទៅស៊ើបស្តាប់ទៅ។ វាមិនមែនមានមនុស្សប្រុសណាទៅនៅកន្លែងនារីហ្នឹងទេ។ ជំនាន់នោះ គេចាត់តាំងច្បាស់លាស់ កងបុរស កងនារី។ ហើយបើកងនារីហ្នឹង ការកូនស្រីឯងហើយហ្នឹង កូនស្រីដេកកន្លែងហ្នឹងហើយ នារីគេមានកន្លែងណា គេរៀបចំកន្លែង។ អំមិញខ្ញុំឆ្លើយថាអត់។ អត់ជាទូទៅ ប៉ុន្តែដោយឡែកៗគឺវាមាន។ គេដកបន្ទប់នេះមួយ ពីរ បីនាក់ តាមជាក់ស្តែងឲ្យទៅអ្នកដែលការថ្មីនៅក្នុងហ្នឹង អ្នកក្រៅ គេទៅវាល។

**ស៖** ចាស អរគុណលោក។ ចុះបើ ឆ្លងតាមការអង្កេត បើឃើញថាក្នុងចំណោមគូទាំងអស់ហ្នឹង មានគូខ្លះមិនត្រូវរ៉ូវគ្នា មិនព្រមរួមដំណេកជាមួយគ្នា។ តើគូហ្នឹងទទួលរងនូវទារុណកម្មអ្វីខ្លះដែរ

លោកមានបានដឹងដែរ?

**ឆ៖** ខ្ញុំអត់ទេ។ អត់បានដឹងទេ។

**ស៖** ចាស អរគុណ។ ខ្ញុំចង់សួរលោកបន្តថា លោកមានប្រសាសន៍អំមិញ ជម្រាបអង្គជំនុំជម្រះថា ក្រោយពេលការហើយ អាចរស់នៅជាមួយគ្នាជាប្តីប្រពន្ធបានពីមួយអាទិត្យ ទៅកន្លះខែ បន្ទាប់មកបែកគ្នាទៅកងចល័តផ្សេង។ អ៊ីចឹងខ្ញុំចង់សួរថា ក្រោយពេលដែលបែកគ្នាទៅតាមកងចល័តផ្សេងៗហ្នឹង តើរយៈពេលប៉ុន្មានខែ ប៉ុន្មានថ្ងៃដែលបានជួបគ្នាវិញហ្នឹង? ហើយការជួបគ្នាម្តងៗហ្នឹង មានរយៈពេលប៉ុន្មានថ្ងៃដែរ ដែលឲ្យរស់នៅជាមួយគ្នាក្រោយពេលបែកគ្នាហើយហ្នឹង?

[០៩:២៨:១៣]

**ឆ៖** សូមជម្រាបថា ពី៧ថ្ងៃ ទៅដល់១៥ដប់ថ្ងៃ ការហើយហ្នឹងឲ្យសម្រាកនៅក្រោយ។ ឯរយៈពេលពីថ្ងៃហ្នឹង ទៅមកម្តងទៀតនោះ អត់កំណត់ទេ។ អ្នកហ្នឹងធ្វើយោធា ទាហាន ទៅមេកង ព្រំដែន ឬទៅច្បាំង ហើយទៅបាត់ទៅ។ កាលណាមានឱកាស គេសុំមេកងគេមកលេង ជួនទៅបាន២០ថ្ងៃ កន្លះខែ ជួនពីរបីខែ។ សុំមកលេងបានមួយអាទិត្យ គេមកមួយអាទិត្យ សុំ១០ថ្ងៃ បាន១០ថ្ងៃ គេមក មកជួបគ្រួសារ ដឹងកន្លែងនៅណាៗហើយ។ ហើយសុខទុក្ខធម្មតា គេផ្ញើសំបុត្រទៅគ្នា តាមអ្នកដំណើរ អ្នកជូនគ្រាប់រំសេវហ្នឹង គេដឹងគ្នា មិនមែនអត់ទេ។

**ស៖** ចាស អរគុណ។ អ៊ីចឹង ដែលលោកជ្រាបហ្នឹង លោកជ្រាបតែតំបន់សហករណ៍របស់លោកទេណា លោកអត់បានជ្រាបទូទៅ ទូទាំងប្រទេសទេ មែនដែរទេ?

**ឆ៖** បាទ នេះខ្ញុំនិយាយតែក្នុងគ្រួសារ និងតំបន់របស់ខ្ញុំ។

**ស៖** ចាស អរគុណ។ ចុះលោកដែលធ្លាប់សង្កេតមើល នៅក្នុងការរៀបការជាគូ ឬក៏ជាហ្វូងៗហ្នឹង តើប្រជាពលរដ្ឋ ឬក៏ឪពុកម្តាយមានការសប្បាយចិត្តទេ នឹងអង្គការដែលធ្វើពិធីឲ្យ ដោយថាមិនមានបានធ្វើតាមប្រពៃណី ដូចគ្រាន់ថាតែហៅអង្គុយកៅអីទល់មុខគ្នាឡើងប្តេជ្ញាតាមអង្គការ ហើយមិនមានការចូលរួមពីឪពុកម្តាយ លោកដែលបានសង្កេតឃើញថាតើប្រជាពលរដ្ឋគាត់មានការសប្បាយចិត្តនឹងការធ្វើឡើងរបស់អង្គការហ្នឹងទេ?

[០៩:៣០:៣៥]

**ឆ៖** ត្រង់នេះសូមឆ្លើយពីរ។ មួយទស្សនៈផ្ទាល់ជាក្នុងនាមជាមនុស្សជាតិ ឆ្លើយថាចង់ មិនចង់អន់ចិត្តខ្លះហើយ ខ្លួនខ្ញុំក៏អ៊ីចឹង កូនខ្ញុំយកទៅការ ខ្ញុំអត់បានរួម ខ្ញុំអន់ចិត្តដែរ។ ខ២ ឆ្លើយថាកាលនោះមតិ

លេចមួយចំនួនមិនអន់ចិត្ត ដែលគាត់ទុកចិត្ត ថា ហ៊ឺះ! ការកូនអញ។ ហ្នឹងដែលនាំឲ្យខ្ញុំមានវិសោធ ការកូនអញហើយ ស្អែងរកកូនក្រមុំច្រើនណាស់។ ខ្ញុំដោះថាកូនក្រមុំ យាយខុមទេ ខ្ញុំធ្វើតាមតែយាយខុម។

**ស៖** ចាស សូមអរគុណ។

**ឆ៖** សូមបន្ថែមមួយម៉ាត់ទៀត។ មួយទៀត ទស្សនៈមហាជនថា “បានអង្គការការឲ្យគ្រាន់បើហើយ រុងរឿងហើយ” វាមានន័យអ៊ីចឹង។

**ស៖** ចាសៗ សូមអរគុណ។ ចុះចំពោះទស្សនៈឪពុកម្ដាយ ឬក៏សាច់ញាតិ ឬក៏សាមីខ្លួនផ្ទាល់ដែលមានមានការមិនពេញចិត្តនោះ សួរថាតើពួកគាត់ប៉ានប្រឆាំងនឹងអង្គការទេក្នុងសម័យហ្នឹង?

**ឆ៖** កាលនោះអត់មានប្រឆាំងទេ តែគ្រាន់តែមានការតស៊ូ មកប្រាប់កង ជួនកាលប្រាប់ដល់ខុម អ្នកជិត អ្នកដែលមិនប៉ានទៅ។ ប្រាប់បន្តៗគ្នាថា “ខ្ញុំអត់ពេញចិត្តនឹងអ្នកហ្នឹង ខ្ញុំពេញចិត្តអ្នកមួយនោះ” មានជាអ៊ីចឹងៗមិនច្រើនប៉ុន្មានទេ។ ដល់អ៊ីចឹងក៏ពិគ្រោះគ្នា ឥឡូវបើនេះ ឯងលែងគ្នាទៅ ដល់ស្រាប់លែងគ្នាសួរទាំងពីរនាក់ព្រមឲ្យលែង សម្រួលតាមសតិអារម្មណ៍គេ មានធ្វើអ៊ីចឹង។

**លោកស្រី ស៊ីន សុវ៉ែន៖**

ចាស សូមអរគុណ។ លោកប្រធាន ខ្ញុំអស់សំណួរហើយៗពេលនេះ ខ្ញុំប្រគល់តួនាទីឲ្យសហការីខ្ញុំឆ្លើយបន្ត។ ចាស សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ សូមអញ្ជើញ!

[០៩:៣៣:៣២]

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

សូមអរគុណលោកប្រធាន។ ជម្រាបសួរលោកប្រធាន លោក លោកស្រីចៅក្រម។

**សួរដោយលោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

**ស៖** ជម្រាបសួរលោកសាក្សី ខ្ញុំឈ្មោះម៉ារី ហ្គីរ៉ូដ៍ ខ្ញុំជាមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីដែលតាំងខ្លួននៅក្នុងសំណុំរឿងនេះ។ ខ្ញុំមានសំណួរមួយចំនួនដើម្បីសួរទៅកាន់លោកពាក់ព័ន្ធនឹងជីវិតនៅក្នុងសហករណ៍ លក្ខខណ្ឌ<រស់នៅ>នៅក្នុងសហករណ៍នៅស្រុកត្រាំកក់។ កាលពីរថ្ងៃកន្លងទៅនេះ លោកនិយាយពីមុខងាររបស់លោកនៅត្រាំកក់ ជាពិសេសរបៀបដែលលោកគ្រប់គ្រងទៅលើការមកដល់អ្នក១៧មេសា លោកគ្រប់គ្រងបញ្ហារបបអាហារ និងការរស់នៅ។ ឥឡូវនេះ ខ្ញុំចង់សួរសំណួរមួយចំនួន

ទៅកាន់លោកពាក់ព័ន្ធនឹងមុខងារ <និងការទទួលខុសត្រូវ>របស់លោកនៅសម័យនោះ។ សំណួរទី១ ដែលខ្ញុំចង់សួរលោក គឺខ្ញុំចង់ឲ្យលោកពន្យល់ជូនអង្គជំនុំជម្រះថា តើអ្នកណាជាអ្នកសម្រេចបង្កើតកងការងារនៅក្នុងសហករណ៍<ក្នុងស្រុកត្រាំកក់>? ហើយនិងបង្កើតយ៉ាងម៉េច? យើងបានស្តាប់ឮសក្ខីកម្មជាច្រើនតាំងពីពេលចាប់ផ្តើមសវនាការនោះ យើងយល់ថាមានកងកុមារ កងស្ត្រី កងចល័ត កងពិសេស កងផ្សេងៗ។ អ៊ីចឹង ខ្ញុំចង់ដឹងថាការបង្កើតកងទាំងអស់ហ្នឹងគេធ្វើឡើងដោយរបៀបណា? ហើយអ្នកណាជាអ្នកសម្រេចបង្កើតនោះ នៅស្រុកត្រាំកក់?

**លោក ពេជ្រ ជឹម៖**

**ឆ៖** សូមជម្រាបពីសហករណ៍ស្រុកត្រាំកក់។ នាំមកធ្វើ តាម៉ុក មកណែនាំឲ្យភូមិ ឃុំធ្វើ គាត់ណែនាំផ្ទាល់។ ប៉ុន្តែសួរថា ភូមិ ឃុំ ស្រុក ខ្ញុំផ្ទាល់ក្តីចេះសហករណ៍ហ្នឹងខ្លឹមសារម៉េច អត់ដឹងអីទេ ឲ្យធ្វើតែម្តង។ ឲ្យរៀបចំទាំងអស់ ដាំបាយមួយកន្លែង ប៉ុណ្ណឹង។ ពីមុនថារៀបមួយភូមិ បាយម្តុំ មួយកន្លែង មួយភូមិបាយមួយកន្លែង មួយភូមិបាយមួយកន្លែង។ ឃុំទាំង១០ភូមិ បាយ១០កន្លែង។

**ស៖** សូមអរគុណលោក។

[០៩:៣៦:២៤]

**ឆ៖** ក្រោយមកទៀត តាម៉ុក គាត់ថា "មួយឃុំមួយកន្លែងទៅ!"។ មិនមែនមួយភូមិមួយកន្លែងទេ និយាយរួមមួយឃុំឆ្នាំងបាយមួយទៅ ធ្វើអត់កើត។ អ៊ីចឹងយកគំរូ អ្នកណាធ្វើបាន មួយឃុំធ្វើបានមួយកន្លែង អាហ្នឹងសហករណ៍គំរូ។ ណាមួយឃុំធ្វើបានបីបួនកន្លែង អាហ្នឹងបន្ទាប់។ ចាប់ធ្វើ ធ្វើរុះៗចុះមានអ្នកណាធ្វើជាង អ្នកណាចេះ រៀនធ្វើ។ ប្រជាជនក៏ទាស់ ជំនាស់ថាអ៊ីចេះ ថាអ៊ីចុះ ឥឡូវជួយធ្វើទាំងអស់គ្នា បើអង្គការថាធ្វើអ៊ីចឹងហើយ កើតម៉េចយកអ៊ីចឹង។ ហ្នឹងរឿងវិធីធ្វើៗដោយខាងលើដាក់ឲ្យធ្វើ គឺធ្វើតែម្តង។ ឲ្យដាំបាយហូបហ្នឹងគឺគេសំដៅបាយមួយកន្លែងហ្នឹង ចំណេញពេលវេលា សល់មនុស្សទៅធ្វើការបានច្រើន ធ្វើចុងភៅមួយចំនួនទៅ ហើយសល់កម្លាំងយកទៅធ្វើការ។ ការងារហ្នឹងការបង្កបង្កើនផល ការលើកទំនប់ ប្រឡាយ ភ្លឺស្រែហ្នឹង ហើយជួយរឿងកសិករ រឿងអី។ សូមឈានចូលថា ចុះរៀបកង រៀបអីយ៉ាងម៉េច។ ដល់ធ្វើអ៊ីចឹង កុមារវាមានមួយផ្នែក មានយុវ័នធំជាមេក្លាប់វា នាំទៅធ្វើការទៅ តាមរយៈហ្នឹងអប់រំនៅផ្លូវល្អ។ កុមារី មានយុវនារីប្រាប់ទៅ ហើយនារីពេញវ័យអាហ្នឹងមេ ចៅហ្វាយស្រុកអស់ហើយ ហើយមេកងស្រុកក្តាប់ទៅធ្វើការ។

[០៩:៣៨:៤៥]

ហើយកងចល័តប្រុស ដែលចាស់ៗនៅលើកទំនប់ ភ្លឺស្រែ បង្កើនផល ធ្វើស្រូវ ធ្វើស្រែ ខ្ញុំក្តាប់ខាងហ្នឹង។ មេកងទាំងអស់មួយស្រុក ហ្នឹងកងចាស់ៗហ្នឹង គេយកទាំងអស់ហើយ។ បង្កបង្កើនផល ធ្វើស្រែ ទប់ទំនប់។ សូមបញ្ជាក់ជូនថា បង្កើនផលហ្នឹងគឺដាំដំឡូងមី និងបង្កើនផលពីររដូវ ដីស្រុកត្រាំកក់ ខ្ញុំធ្វើបាន។ និយាយដដែល កុំថាឲ្យខ្ញុំអំនួតបន្តិច ប៉ុន្តែជម្រាបឲ្យច្បាស់ សូមអត់ទោស ខ្ញុំធ្វើបាន។ បាន៣តោន ហើយដី២៥០០០ហិកតា នៅចាំ។ ធ្វើបាន៣តោន។ ក្រៅពីនោះ ដីមុខភ្នំ ដីព្រៃៗហ្នឹង ចលនាដាំដំឡូងមីទាំងអស់ បានជាង១០០០ហិកតា អត់ចាំ ដូច១៥០០ហត្ថ(ហិកតា)។ ដំឡូងមីហ្នឹងបានឲ្យសហករណ៍ហូប។ ដល់កន្លែងផ្សេងអត់ តំបន់២៥ ទៅសុំឲ្យ។ ឲ្យពូជស្រូវ ឲ្យដំឡូងមីពីរឡានអីចឹងទៅ។ តំបន់១៥ ទៅសុំ ឲ្យដំឡូងមី ឲ្យពូជស្រូវ ឲ្យស្រូវពូជ ស្រូវចំណីទៀត(ស្រូវហូបហ្នឹង) មួយឡានពីរឡានអីចឹងទៅ។ ឯខាងខ្ញុំ ហូបបាយ អើមានពេលបបរវាវអីខ្លះ ប៉ុនដល់ហើយលៃលកស្រូវទៅ ឡើងបាយរឹងទាំងអស់។ មិនដល់រឹង ក៏ត្រឹមបាយទន់ មិនមែនបបរវាវទេ។ ហ្នឹងរៀបតាមកងអីចឹង កុមារ កុមារាកុមារី យុវជន យុវនារី កងផលិត បង្កើនផល។ ហើយមេឃុំ គោងហើយ រៀបចំធ្វើ។ មានទឹកមានស្រូវ តែមានទឹកមានស្រូវហើយ។ ហើយដល់សព្វឃុំ មើលរាល់ថ្ងៃ អត់ៗ ធ្វើអត់បានទេ តឹងត្រង់ហ្នឹង ប៉ុន្តែថាទៅធ្វើ បាបអីគេ អត់ទេ។ ថាតឹងដើម្បី ភ័យខ្លាច ប៉ុន្តែធ្វើ។ ធ្វើទៅបានហូបឆ្អែតទៅ បាត់ខឹង យល់។ ហ្នឹងសូមអស់។

[០៩:៤១:៤៦]

**ស៖** សូមអរគុណ។ លោកនិយាយថា វិន័យតឹងរ៉ឹងហ្នឹង លោកចង់មានន័យថាម៉េចដែរ?

**ឆ៖** តឹងរ៉ឹងហ្នឹង គឺថាមិនធ្វើមិនបាន។ ថា “ខំធ្វើ អត់ធ្វើអត់បានទេ!” ថាអីចឹង។ មិនមែនជាវិន័យប្រកាសអីចឹង មាត្រា១, ២ អីទេ ប៉ុន្តែយើងនិយាយជាមាត់នៅក្នុងៗសមរភូមិ ក្នុងកន្លែងធ្វើការថា “ខំធ្វើអ្នក!” អីចឹង។ តឹង ហៅតឹងមាត់ តឹងសម្តីហ្នឹង ពាក្យសាមញ្ញទេ។

**ស៖** សូមអរគុណ។ អម្បាញ់មិញនេះ លោកនិយាយអំពីកងកុមារ និងកងយុវជន<នៅក្នុងស្រុក>របស់លោក។ អីចឹង<>ការបង្កើតកងហ្នឹង ចេញពី តាម៉ុក មែនទេ? <បើអីចឹងមែន តើ>គេមានពន្យល់មូលហេតុទេ? ហេតុអីបានជាបង្កើតជាកងកុមារ កងយុវជនអីចឹង?

**ឆ៖** ហេតុដែលគេបង្កើតជាកង ដើម្បីក្តាប់កម្លាំង។ យុវជនគេដឹងយុវជនគ្នាគេមានប៉ុន្មាននាក់ ហើយកុមារដឹងកុមារមានប៉ុន្មាននាក់។ នារីៗក្រមុំហ្នឹង មានប៉ុន្មាននាក់។ សុខភាពយ៉ាងម៉េច អីយ៉ាងម៉េច ត្រូវព្យាបាលយ៉ាងម៉េច ឈឺយ៉ាងម៉េច អីយ៉ាងម៉េច យល់។ ពេលធ្វើការ ទៅប៉ុន្មាន នៅផ្ទះ នៅចាំ

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

កន្លែងប៉ុន្នាន។ ហើយមេគេមើលអ៊ីចឹង។ បើគ្នា២០០នាក់ ឃើញមុខធ្វើការតែ៥០ គេដឹងចំនួន មើលតែបញ្ជីហ្នឹង គេដឹងហើយ។ ហ៎! ដល់អ៊ីចឹងគេសួរមេកងហ្នឹងហើយ ទៅណា មូលហេតុអី។ ចុះបើអត់មានមេកង ទៅសួរអ្នកណា។ ទាល់សួរគ្រប់ផ្ទះ បានឃើញ។ លុះមក កង មេកង ក្រុម ទាំងកុមារ យុវជន នារីទាំងអស់ហ្នឹង ដើម្បីក្ដាប់កម្លាំង ដើម្បីរៀបរយកម្លាំង ដើម្បីៗរៀបរយកម្លាំង ក្ដាប់កម្លាំង ដើម្បីធ្វើការ រហ័ស លឿន ហើយខ្លាំង ទាន់សភាពការណ៍។

[០៩:៤៤:៤៥]

**ស៖** សូមអរគុណ។ លោកឆ្លើយថា លោកចាំបាច់ត្រូវដឹងថា អ្នកណាខ្ជិល។ អ៊ីចឹង ខ្ញុំចង់ដឹងថា តើអ្នកដែលគេចាត់ទុកថា ខ្ជិលនុ៎ង គេធ្វើយ៉ាងម៉េចដែរចំពោះពួកគាត់?

**ឆ៖** អ្នកខ្ជិលគឺអប់រំ ណែនាំបង្ហាញទៅ។ មិនមែនចេះតែក្ដៅទាំងអស់ទេ។ ណែនាំបង្ហាញ ចុះបើគ្នាឈឺ មើលជាក់ស្ដែង ចុះគ្នាឈឺ ឈឺគ្នាចង់មិនចង់ បើអត់ទៅ ធ្វើការអត់កើត។ ដូចនេះ បើមេកងឆ្លាតល្អិតអត់សព្វទៅវា ហើយយើងជឿតាមទៀតទៅ ក៏វាបានល្អ។ បើមេកងអត់ឆ្លាត អត់ប្រសព្វ ជួនមានអនុកងទៀត វារាងមុខមាត់ទំនាស់គ្នាអីទៅ យើងនឹងចុះតាមដានផង។ វាមិនអាចមានទំនាស់នៅក្នុងហ្នឹង។ ហ្នឹងកន្លងមក ដឹកនាំ ខ្ញុំអ៊ីចឹង ទទួលហើយ លបចុះពិនិត្យដល់កន្លែង។ ទទួលហើយ រឿងហើយ លបចុះដល់កន្លែង។ ដល់កន្លែង បើឃើញដូចមេកងរាយហ្នឹងល្អ បើខុសពីមេកងរាយ អាហ្នឹងរឿងផ្សេងទៀត។ អប់រំៗឲ្យយល់មាគ៌ាទៅ យើងល្អនឹងគ្នា រីករាយគ្នា កុំធ្វើអ៊ីចឹង វាមានប្រកាន់គ្នា ខឹងគ្នា នាំទំនាស់។ វាជាល្អទេ មិនមែនឲ្យភ័យទេ។ សូមអស់។

**ស៖** សូមអរគុណ។ លោកនិយាយអំពីវិធានការវិន័យដែលត្រូវអនុវត្តចំពោះអ្នកខ្ជិលច្រអូស។ អ៊ីចឹង លោកអាចផ្ដល់ឧទាហរណ៍បានទេ ថាតើការអនុវត្តវិធានការហ្នឹងយ៉ាងម៉េចដែរ អាចមានដល់ថ្នាក់ចាប់ខ្លួន "អ្នកខ្ជិល" ហ្នឹងទេ?

[០៩:៤៧:០៣]

**ឆ៖** សូមជម្រាប ខ្ញុំនិយាយហ្នឹងក្នុងរង្វង់រួមមន្ទីរក្រសួងផ្សេងៗជុំវិញស្រុក ទាំងប្រុស ទាំងស្រី ទាំងមេកង។ មិនមានចាប់ទេ មិនឲ្យចាប់ទេ បើតឹងណាស់ ត្រូវយកបុគ្គលហ្នឹងមកជួបផ្ទាល់។ ព្រោះយល់ឃើញថា ខាងលើមានពិសោធខ្ពស់ មើលឃើញថាច្រើនជាង និយាយត្រូវចំ ហើយបើដកមកលើខ្ពស់ដាច់អ៊ីចឹង មើលទៅ យើងឃើញប្រហោងឯក្រោមច្បាស់ បើទុកអត់ឃើញប្រហោងទេ។ ហ្នឹងសូមជម្រាបប៉ុណ្ណឹង ហើយសម្រួលទៅ ប្រាប់ត្រង់ៗទៅ អ៊ីចេះមួយអ៊ីចេះពីរទៅ។ ជួនអត់ឲ្យទៅហ្នឹងវិញទេ

នៅជិតនេះហើយ។ ធ្វើការជាមួយគេខាងណោះទៅ។ ឲ្យទៅវិញ ខ្លាចវាទាស់ទៀត ហ្នឹងបើវាមានទំនាស់គំនុំគ្នា។ ហើយទុកនៅខាងផ្សេង ប្រើផ្សេងទៅ ហើយចាត់តាំងធ្វើផ្សេងទៅ។ វាល្អ ដំឡើងថ្នាក់ទៅទៀតទៅ។ ប៉ុនបើយើងមិនបានចុះមើលអីចឹង គឺតាមមួយម្តង ពីរដង បីដង ផ្ទុះហ្នឹង យើងចេះតែយល់ព្រមដល់ថ្នាក់ចាប់ហើយ។ យល់ព្រម ដោយៗ ទោះរាយការណ៍ ដោយគ្រាន់តែឮ ភ្នែកមិនឃើញទេ។ ហ្នឹងការដឹកនាំពិសោធមក។ ជម្រាបជូនអីចឹង។

**ស៖** សូមអរគុណ។ ពេលខ្លះលោកនិយាយថា លោកចុះទៅមើលក្នុងកងហ្នឹងផ្ទាល់តែម្តង <គឺចុះទៅពិនិត្យស្ថានភាពក្នុងកងទាំងនោះ>។ អីចឹង តើលក្ខខណ្ឌការងារ<>នៅតាមកងនីមួយៗហ្នឹងមានលក្ខណៈល្អប្រសើរ<សមរម្យដែរ>ទេ? ឬក៏ថាតើបន្ទុកការងារកងខ្លះធ្ងន់ ឬក៏កងខ្លះមិនសូវធ្ងន់ ឬក៏ធ្ងន់ដូចគ្នាអីចឹង ខ្ញុំចង់ឲ្យដឹងថាតើលក្ខខណ្ឌការងារនៅតាមកងនីមួយៗនោះ យ៉ាងម៉េចដែរ?

**ឆ៖** ខ្ញុំជម្រាបពិសោធ បើមានរឿងអីចឹង ខ្ញុំចុះពិនិត្យ។ អីចឹង មេកងអត់នៅទេ។ មេកងទៅធ្វើការអស់ ខ្ញុំដើរមក ឈៀងចូលបន្តិចទៅ ជួបម្នាក់ពីរ ខ្ញុំស្រង់សម្តីម្នាក់ពីរ សួររឿងហ្នឹង។ អានេះម៉េចអានោះម៉េច។ បានតែបួនប្រាំនាក់ មតិបួនប្រាំ ខ្ញុំបូកសរុបឃើញបញ្ហាឲ្យហើយ។ អាហ្នឹងចលនាប្រាប់ការជាក់ស្តែង។ ដំណឹងដែលនៅមូលដ្ឋានពិត គឺត្រូវហើយ អត់ខុស។ ទោះតែឃើញថា មេកងហ្នឹងខុសក៏ខ្ញុំសម្រួល អត់បន្ទោសមេកង។ គេហាត់គេ គេថាបន្តិចទៅកុំខឹង ឧទាហរណ៍អីចឹង។ ហើយឯងនេះមានធ្វើមេគេ យើងធ្វើកូន គេណែនាំធ្វើទៅ បើឈឺប្រាប់ថាបងអើយខ្ញុំឈឺហើយ អីចឹងទៅហ្នឹងសម្រួលដោះស្រាយអីចឹង។

[០៩:៥០:៣៧]

**ស៖** សូមអរគុណលោកសាក្សី ក៏ប៉ុន្តែ ខ្ញុំចង់ដឹងអំពីលក្ខខណ្ឌការងារ ឧទាហរណ៍ដូចថា ចំនួនម៉ោងធ្វើការដែលតម្រូវឲ្យ<សមាជិកនានា>ធ្វើការដើម្បីសម្រេចផែនការនោះ <ដែលគេដាក់ឲ្យរូបលោក<>ជាអ្នកទទួលខុសត្រូវ<។> អីចឹង ខ្ញុំចង់ដឹងថាតើលោកមានអារម្មណ៍ថាប្រជាជនធ្វើការច្រើនធ្វើការធ្ងន់ពេក ឬក៏លោកគិតថា<លក្ខខណ្ឌ>ការងារ ទាំងអស់ហ្នឹងគឺ<សមល្មមហើយ>មិនធ្ងន់ធ្ងរអីទេ?

**ឆ៖** សូមបញ្ជាក់ ខ្ញុំអំមិញរៀបនិយាយចូល ប៉ុន្តែវាភ្លេចចំណុចហ្នឹង។ ពីលក្ខខណ្ឌការងារ គឺបានផលប្រហែលៗគ្នា ទោះវាលើសខ្វះគ្នាបន្តិចបន្តួច ក៏ថាជាធម្មតានៃច្បាប់ធម៌ មនុស្សខ្លះខ្លាំង ខ្លះខ្សោយ ខ្លះសកម្មខ្លាំង ខ្លះមធ្យម។ ខ្លួនយើងម្នាក់ៗដល់ពិសោធទៅឃើញ។ ខ្លះលីបាវមួយរួច ខ្លះលីការ៉ុង

មួយមិនរួច។ ខ្លះមិនថាមួយ កន្លះក៏គ្នាលើកមិនរួចដែរ គឺធម្មជាតិ។ ដល់យល់ឃើញអ៊ីចឹង ទៅ រួមគ្នាធ្វើទៅកុំទាស់គ្នាកំប៉ិកកំប៉ុក ហ្នឹងក្នុងនាមខ្ញុំ ខ្ញុំដោះស្រាយអ៊ីចឹង ប៉ុនបើខ្ញុំសម្រេចអ៊ីចឹងវាអ៊ីចឹង ហើយសម្រួលអ៊ីចឹងហើយ មិត្តខុម ក៏គាត់ឯកភាពតាមពូទៅ។ គាត់ហៅខ្ញុំពូ ខ្ញុំបងគាត់។ ឯកភាពតាម។ អ៊ីចឹងសូមប៉ុណ្ណឹង។ ឯលទ្ធផលតិចច្រើនអីមើលកម្លាំងការងារ មើលផលឲ្យធ្វើចុះជាប់ បាយ ថ្នាំពេទ្យ រស់នៅសម្រាកដេក ដេកយ៉ាងម៉េច អត់អង្រឹងធ្វើរានដេក ដំបូល កងហ្នឹងទៅធ្វើខ្លះ ដកខ្លះទៅកងស្បូវធ្វើដំបូលជ្រក ខ្លះទៅល្អួសឈើមកធ្វើរនាប ធ្វើបង្គោល ធ្វើរានដេកទៅ។ គ្នាទើបមក គ្នាអត់ទាន់មានអង្រឹង ដោះស្រាយអ៊ីចឹងវាអត់ស្ងួវបានផលល្អ។ សូមជម្រាបប៉ុណ្ណឹងសូមអស់។

[០៩:៥៣:២៧]

**ស៖** សូមអរគុណលោកសាក្សី។ យើងបានស្តាប់ឮសាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីជាច្រើន ជាពិសេសដើមបណ្តឹងរដ្ឋប្បវេណីពីរនាក់ដែលធ្វើការនៅក្នុងកងកុមារនៅស្រុកត្រាំកក់<។> ពួកគាត់ពន្យល់ថាលក្ខខណ្ឌការងារនុ៎ង លំបាកមែនទែនពីព្រោះថាពេលនោះ ពួកគាត់មានអាយុត្រឹមតែ៨ ទៅ៩ឆ្នាំទេ។ អ៊ីចឹងនៅពេលដែលលោកនៅត្រាំកក់នោះ លោកមានដែលចុះមើលកងកុមារទេ<?> ហើយលោកដឹងទេថាលក្ខខណ្ឌការងារនៅក្នុងកងកុមារត្រឹមត្រូវទេ អាចទទួលយកបាន<ទេសម្រាប់លោក>?

**ឆ៖** សូមជម្រាបចុះ ត្រង់កន្លែងហ្នឹងមិនដឹងបានចុះ ឬមិនបាន ច្រើនណាស់ មានច្រើនណាស់។ កាលទៅគុសនោះចុះគុស កងកុមារ កងនារីហ្នឹង នារីគេមានផ្លូវចុះដោយនារី កុមារ។ ច្រើនជួបមេៗកុមារហ្នឹងហៅមកប្រជុំរួម។ ហើយណែនាំផែនការដាក់ចុះទៅ។ ប៉ុនកុមារមិនមានអីប្រើច្រើនទេ ប្រើតែធ្វើជី ហើយរៀន – ជីទន្រ្ទានខែត្រ បោចទន្រ្ទានខែត្រស្រាលៗលីយកមកដាក់រណ្តៅ។ ហើយពេលទំនេររៀន។ ប៉ុនការខ្វះខាត កុមារមិនខ្វះទេ ខ្វះខាតមេកង។ មេកងហ្នឹងខ្វះមកពីខ្ញុំៗ ខ្ញុំមើលវាមិនអស់មេកងហ្នឹងក៏វាអត់ស្ងួវចេះ អាហ្នឹងឃើញអ៊ីចឹង។

[០៩:៥៥:២០]

**ស៖** សូមអរគុណលោកសាក្សី។ ខ្ញុំចង់ឲ្យលោកឆ្លើយតបទៅនឹងសក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណីមួយរូបដែលគាត់បានមកផ្តល់សក្ខីកម្មនៅមុនពេលចូលឆ្នាំខ្មែរយើងនេះ គាត់នៅក្នុងកងកុមារនៅឃុំលាយបូរ ស្រុកត្រាំកក់ គាត់ឈ្មោះ <អ៊ឹម> វណ្ណៈ។ គាត់បានផ្តល់សក្ខីកម្ម<ចំពោះមុខអង្គជំនុំជម្រះ> ឯកសារ E1/288.1 គឺនៅប្រហែលជាម៉ោង ១៣:៤៤នាទី ខ្ញុំសូមអានសក្ខីកម្មរបស់គាត់ពេលនោះគាត់មានអាយុ៩ឆ្នាំ អ៊ីចឹងចង់ឲ្យលោកឆ្លើយតប៖ “គេឲ្យពួកខ្ញុំទៅជីកដី សែងដីប្រឡាយចាប់

ពីម៉ោងប្រាំមួយ<ព្រឹក> ទៅដល់ម៉ោងដប់មួយកន្លះ<ថ្ងៃត្រង់> ហើយបើពួកខ្ញុំធ្វើមិនហើយ គេ<មិន> ឲ្យហូបបាយទេ ពីព្រោះគេដាក់កុមារកំណត់ហ្នឹង ឲ្យគ្នា១០នាក់ហ្នឹងរែកដីឲ្យហើយ ចំនួន១០ម៉ែត្រគូប តែជួនកាលទៅយើងធ្វើបាន ជួនកាលធ្វើមិនបាន។ បើកាលណាដីទន់ទៅ ពួកខ្ញុំក៏ធ្វើបានក្នុងថ្ងៃ ទល់យប់ ហ្នឹង។ បើថាដីហ្នឹងរឹងទៅ ខ្ញុំធ្វើមិនបានទេ។ ហើយបើធ្វើមិនបានទេ គេមិនឲ្យហូបបបរទេ"។ អ៊ីចឹង លោកសាក្សី ខ្ញុំចង់ឲ្យលោកឆ្លើយតបទៅនឹងសក្ខីកម្មរបស់គាត់នេះ ពីព្រោះថាយើងមានសាក្សីនិងដើម បណ្តឹងរដ្ឋប្បវេណីជាច្រើន ដែលគាត់ពន្យល់ថាលក្ខខណ្ឌកាលហ្នឹង គឺថាពិបាកណាស់។ អ៊ីចឹងលោក មានបានកត់សម្គាល់ឃើញរឿងហេតុ ដូចដែលគាត់បានរៀបរាប់ហ្នឹងទេ នៅពេលដែលលោកនៅ ត្រាំកក់នោះ?

[០៩:៥៧:០០]

**ឆ៖** មិនដែលជួប។ មិនដោះទេ ប៉ុន្តែមិនដែលជួបរឿងអ៊ីចឹង។ ថាម៉ោងពីព្រឹកទល់ម៉ោងដប់ មួយដណ្តប់ ព្រឹកឡើងស្រស់ស្រូប ហើយម៉ោងមួយដណ្តប់ថ្ងៃ ហូបបាយ ធម្មតាប៉ុណ្ណឹង ពេលធម្មតាដូច គ្នា ប៉ុន្តែខ្ញុំជឿថាវាមានប្រហោង មានឆកល្វែង។ ធម្មតាអ្នកដែលក្តាប់កុមារហ្នឹង ក៏វាវិធីពិសោធដឹកនាំ ដែរ ហើយបើដឹកនាំទៅមិនបាន ក៏មកប្រាប់មេច្បាស់លាស់ទៅ ចេះតែសង្កត់គេឲ្យគ្រប់ផែនការ អាហ្នឹង ខុស។ ហើយដល់មេមិនដឹង ស្មានតែស្រួលហើយ ការងារច្រើន ដើរម៉េចនឹងសព្វ។ ហើយគិតថា រឿង កុមារមានរឿងអី តែពីរមុខហ្នឹង តែប្រមូលជី ហើយនិងរៀនអក្សរ។ អក្សរហ្នឹង មានក្តារ មានអីណា ដាក់ក្តារមួយរៀនទាំងអស់គ្នា។ យកដីកណ្តេងសរសេរលើហ្នឹង គ្មានក្តារខៀនឯណា។ ដីភក់ៗហ្នឹង ចុះ អត់ហើយ ដល់គាត់ តាមមើលគាត់ចង់បានគុណសម្បត្តិច្រើនពេក ក៏គាត់ឲ្យគ្នាខំទៅ មិនមើលឈឺ មើលអី។ ប៉ុន្តែបើឃើញ បើដឹងរឿងទាន់ ដោះស្រាយ។ ប៉ុន្តែខំយ៉ាងណាក៏មិនអស់ដែរ ឆកល្វែង។ សូម អស់។

**សះ** អ៊ីចឹង លោកគិតថារបបហូបចុកហ្នឹង គ្រប់គ្រាន់ទេសម្រាប់អ្នកធ្វើការនៅក្នុងស្រុកត្រាំកក់ ហ្នឹង?

[០៩:៥៩:១៨]

**ឆ៖** របបហូបចុកនោះ មិនខ្វះ ប៉ុន្តែអត់ឆ្អែត ឆ្លើយអ៊ីចឹង។ អត់ឆ្អែត ចង់ឲ្យឆ្អែត ទាល់តែរកអី ថែម ព្រោះអង្ករបប។ ហើយមានដំឡូងឡើយ យកមកវិញហើយ អត់ដឹង យកទៅវាយចាក់ចែកគ្នា ស្ងោរឲ្យវាហូបថ្ងៃៗ តូចៗហ្នឹង កុមារហ្នឹង។ ប៉ុន្តែតាមមើល ដូចមិនសូវមាន បើឃុំធ្វើមាន បើក្នុងនាម

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ស្រុកធ្វើឲ្យប្រមូលយក គ្រាន់តែណែនាំឃុំឲ្យយកចែកគ្នាទៅ។ ចែកតាមសហករណ៍ សហអី មិនស្រួល ភ្លេចកុមារក៏មិនដឹង។ អត់ស្រូវ ស្រូវ អង្ករវាស្មើរហ្នឹង គឺដំឡូងមីជាងមួយពាន់ហាត្ថ(ហិកតា)ហ្នឹង។ ចែកទៅក្រៅ ចែកហើយ ប៉ុន្តែខ្លួនឯងជួនវាខ្វះ ភ្លេចថាខ្លួនឯង។ សូមជម្រាបអ៊ីចឹង។ រវល់ការខ្លួនយើង រវល់ខ្លាំងពេក ភ្លេចហូបបាយ គិតតែភៀវ។ សុំអស់។

**ស៖** សូមអរគុណ។ នៅថ្ងៃទី០១ នៃសវនាការនេះ លោកបានឆ្លើយដូចតទៅ ខ្ញុំសូមដកស្រង់៖ "យើងចង់ធ្វើ<ឲ្យបានច្រើន>ពេក អ៊ីចឹងហើយ យើង<ធ្វើខុស ហើយយើង>ទៅជាធ្វើឲ្យប្រជាជនហ្នឹង<មិនទុកចិត្ត>ទៅវិញ។ <លោកសាក្សី> អ៊ីចឹង នៅពេលណាដែរ ដែលលោកមានអារម្មណ៍ថាៗ<បានធ្វើខុសជាសម្ពហភាព>នុះ? អ៊ីចឹង នៅពេលដែលលោកទៅដល់ត្រាំកក់ភ្លាមនុ៎ង លោកមានអារម្មណ៍ថា ពួកលោកហ្នឹង<ប្រព្រឹត្តខុសគន្លងដែរទេ> ហើយធ្វើឲ្យប្រជាជនហ្នឹងមិនទុកចិត្ត ឬមានការសង្ស័យនុ៎ង?

[១០:០១:៣៦]

**ឆ៖** សូមជម្រាបថា ពាក់ព័ន្ធហ្នឹងគឺផ្ទាល់ខ្លួន ចុះភ្លាម និយាយសាដើមវែងបន្តិចចុះ។ រដ្ឋប្រហារមក សម្តេចចូលព្រៃមាគី។ ម្ល៉ោះហើយគ្រូបង្រៀននៅជនបទ ចូលទាំងអស់ហ្នឹង ជាង១០០នាក់តាកែវ សល់តែអ្នកអត់នៅមុនតំបន់ លន់ នល់ សល់នៅក្រៅ១០០ -- ១០៥នាក់ រត់ទៅនៅស្រុកត្រាំកក់ទាំងអស់ ព្រោះអីចូលច្បាំងទាមទារយកសម្តេចមកវិញ ហ្នឹងរណសិរ្ស។

នៅតាមភូមិសាស្ត្រស្រុកខ្មែរយើង ខ្មែរសម្ងាត់តស៊ូមក មានចលនាតស៊ូដែលគេៗចោទថា ខ្មែរក្រហម នៅកំពត។ នៅបាត់ដំបង គឺមានសំឡូត នៅស្វាយរៀង ហើយនិងព្រៃវែង មានស្រុកសូត្រ -- ប្រសូត្រ។ នៅតាកែវ មាន -- តាកែវ-កំពត មានស្រុកត្រាំកក់។ ហើយទូទាំងប្រទេស បងប្អូនតស៊ូនៅលើភ្នំ។ អ្នកតស៊ូដែលយើងហៅខ្មែរក្រហម នៅលើភ្នំ។ អ្នកតស៊ូនៅលើភ្នំ ចុះទៅជនបទទាំងអស់។ បក្សប្រកាស ជនបទទាំងអស់។ ឥឡូវគេរដ្ឋាភិបាល។ បក្សប្រកាសរៀបរយ រៀបចំរណសិរ្សដែលមានសម្តេចឪជាប្រធាន។ ហ្នឹងជាប្រធាន មានបង ខៀវ សំផន មានលោក ហ៊ូ នឹម, ហ៊ូ យន់។ ខ្ញុំចូលតាមហ្នឹង ខ្ញុំធ្វើទ ដើម្បីទាមទារសម្តេចរហូត។ ដល់រៀបចំអ៊ីចឹងហើយ ចុះមក។ អ្នកដែលនៅព្រៃ ទោះថ្នាក់ចង់មិនចង់ រាងញញើតៗ ខ្ញុំឃើញអ៊ីចឹង។ បានខ្ញុំថាមិនទុកចិត្តគ្នា។ ឃើញយើងអ្នកនៅក្នុងប្រទេសដែលពួករណសិរ្ស។ ចេះតែមើលលើ មើលក្រោមៗ ហើយយើងតែស្ងៀម ធ្វើតែមិនដឹង។ ឯអ្នកឯណោះឃើញដូចតែប្រយ័ត្នជាប់ ដូចមិនទុកចិត្តអីអ្នកនៅក្នុងប្រទេសសោះ។ ប្រយ័ត្នតែស៊ីចុក សំខាន់ដេក

ប្រយ័ត្នបំផុត។ ហ្នឹងការពារបដិវត្តន៍ ត្រូវតែប្រយ័ត្នការពារបដិវត្តន៍ គេលើកពាក្យស្លោក។ តាមរយៈហ្នឹងប្រជាជនគាត់ទៅមូលគ្នា រួមគ្នាធ្វើការហើយ។ ទៅគេ ហ៎! អ្នកនេះធ្វើជាមួយនេះ នេះធ្វើមួយនេះថ្នាក់នេះ បានធ្វើ។ បានអ៊ីចឹងគេធ្វើសន្និបាត ប្រកាសប្រាប់ គណៈស្រុក គណៈឃុំអីហ្នឹងទាំងអស់ហ្នឹង។ ហើយប្រជាជនគាត់មកហើយ មករកយើងហើយ មានរឿងអីគាត់មក បើមាន--

**ស៖** សូមទោស ខ្ញុំសូមកាត់ចម្លើយលោកសិន។ ខ្ញុំយល់ថា លោកចង់និយាយច្រើន<រឿងរ៉ាវពីមុនៗឲ្យចូលក្នុងបរិបទ> ក៏ប៉ុន្តែខ្ញុំមានពេលវេលាខ្លីណាស់លោក សូមអភ័យទោសផង។ ខ្ញុំគ្រាន់តែចង់ដឹងថាតើនៅសម័យនោះនៅពេលដែលលោកនៅត្រាំកក់នោះ លោកគ្រប់គ្រងទៅលើកងការងារ មើលទៅលើការហូបចុក ការរស់នៅ។ អ៊ីចឹងនៅពេលសម័យនុ៎ង លោកមានអារម្មណ៍ថា <លោកប្រព្រឹត្តខុស>ទេ? មានន័យថា <>គោលការណ៍<ទូទៅ ដែល>លោក<បានអនុវត្ត>ហ្នឹង <មិនដំណើរការមែនទេ>។ អ៊ីចឹងតើខ្ញុំយល់អ៊ីចឹងត្រឹមត្រូវ <ឬយល់ខុស> នូវចម្លើយរបស់លោក ដែលលោកឆ្លើយកាលពីថ្ងៃដំបូងនៃសវនាការយើងនេះ?

**ឆ៖** បាទ ខ្ញុំឆ្លើយវែង ដោយក្តាប់គោលខ្លីអំមិញអត់ទាន់ ឥឡូវសូមបែរមកវិញ។ ន៎ែ ភ្លេចទៀតហើយ។ បញ្ជាក់មកមើល៍!

**ប្រធានអង្គជំនុំ៖**

លោកស្រីមេធាវីតាំងសំណួរចុងក្រោយរបស់លោកស្រីសាជាថ្មីម្តងទៀត ព្រោះគាត់ភ្លេចសំណួរដែលលោកស្រីសួរហើយ។

[១០:០៧:២១]

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

ចាស លោកប្រធាន។

**សួរដោយលោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

**ស៖** លោកសាក្សី សំណួរខ្ញុំអម្បាញ់មិញនេះគឺថា នៅថ្ងៃដំបូងនៃសវនាការនេះ លោកបាននិយាយថា "យើងចង់ធ្វើឲ្យ<បានច្រើន>ពេក ក៏ប៉ុន្តែ<>យើង<ប្រព្រឹត្តខុសគន្លង>។ ធ្វើឲ្យប្រជាជនហ្នឹង<មិនទុកចិត្ត>មានការសង្ស័យទៅវិញ"។ អ៊ីចឹង ខ្ញុំចង់ដឹងថានៅឆ្នាំ៧៥ និង៧៦, <និងនៅដើមឆ្នាំ>៧៧ នៅពេលដែលលោកនៅត្រាំកក់នោះ <តើ>លោកមានអារម្មណ៍ថា <លោកបានដើរខុសផ្លូវហើយនៅ ឬមិនទាន់ទេ? អ៊ីចឹង តើលោកធ្លាប់មានអារម្មណ៍ថា>គោលការណ៍<ដែល>លោក<បានអនុ

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

វត្ត>នោះ <ហើយ>ព្រឹកមិញនេះលោកនិយាយ<ពីការបែងចែកការងារនៅក្នុងកង សម្ងហនីយកម្ម> អ៊ីចឹង<តើ>លោកយល់ថា កាលនុ៎ងគោលការណ៍របស់លោកហ្នឹងគឺថា មិនអាចដំណើរការបានទេនៅពេលនោះ?

**លោក ពេជ្រ ជឹម៖**

**ឆ៖** សូមបញ្ជាក់ថា កាលនោះ ឃើញដើររីករាយជាប់ហើយ ប្រជាជនរីករាយ ហើយគាត់ពេញចិត្ត១នឹងមាគ៌ារណសិរ្សហ្នឹង។ ហើយធ្វើទៅគាត់ជ្រះថ្លា ពេញចិត្ត។ មានមួយ១ដែលគេមិនពេញ ដោះស្រាយការដែលគេមិនពេញចិត្តហ្នឹង ធ្វើមីទ្ទិង ពន្យល់ក្នុងមីទ្ទិង។ ដោះស្រាយអ៊ីចឹង។ មាន តែមានតិច ៩០ភាគរយវាទៅ ប៉ុន្តែ បួនប្រាំភាគរយទំនាស់ អាហ្នឹងមីទ្ទិងដោះស្រាយ។ ហើយពន្យល់ប្រាប់ច្បាស់ក្នុងមីទ្ទិងហ្នឹង ចលនាបដិវត្តន៍វាទៅហើយ ៩០ភាគរយវាទៅហើយ យើងម្នាក់ពីរចង់ជំទាស់ អន្តរាយទេ កសាងខ្លួនទៅល្អជាង។ ខ្ញុំប្រាប់ត្រង់១អ៊ីចឹង។ អ្នករៀនសូត្រក្រោយ១វាថា ខ្ញុំនិយាយល្អ ប្រាប់ត្រង់ គេយកពិសោធហ្នឹងទៅធ្វើតាមទាំងអស់គ្នា។ សូមអស់។

**ស៖** សូមអរគុណលោកសាក្សី ខ្ញុំនៅសល់សំណួរ<ចុងក្រោយ>ពីរទៀត។ អម្បាញ់មិញនេះលោកនិយាយអំពីល័ក្ខខ័ណ្ឌការងារ និងការរៀបចំការងារជាកង១ <ដែល>លោក<ធ្វើរបាយការណ៍ទៅថ្នាក់លើ>ដើម្បី<ព្យាយាម>រកមើលថា តើបញ្ហាយ៉ាងម៉េច មានគុណវិបត្តិយ៉ាងម៉េចខ្លះ។ អ៊ីចឹងខ្ញុំចង់ដឹងថា តើលោកធ្វើរបាយការណ៍ទៅថ្នាក់លើនោះ របាយការណ៍ហ្នឹងជារបាយការណ៍ប្រភេទណាខ្លះ? ហើយលោកធ្លាប់ដាក់នៅក្នុងរបាយការណ៍ហ្នឹង ព័ត៌មានខុស<>ដើម្បី<លាក់បាំងពី>ស្ថានភាពពិតនៅក្នុងកងហ្នឹងទេ?

[១០:១០:២៥]

**ឆ៖** សូមជម្រាបថា រាយការណ៍ បញ្ជាក់សភាពការណ៍។ សភាពការណ៍ដឹកនាំយ៉ាងម៉េចហើយ? សភាពការណ៍ខ្លាំងទំនាស់ស្មុគស្មាញមានយ៉ាងណា ដោះស្រាយហើយយ៉ាងម៉េច មិនទាន់ដោះស្រាយយ៉ាងម៉េច ហើយវិធានការទៅមុខទៀត។ ហ្នឹងខាងសភាពការណ៍ ហើយខាងសេដ្ឋកិច្ច បើធ្វើស្រែ ប្រមូលផលស្រូវ។ ចម្ការកៅស៊ូ អាហ្នឹងប្រមូលទឹកជ័រ បានទឹកជ័រច្រើន ឬតិច។ បើទឹកជ័រនៃចម្ការកៅស៊ូ វា៧០ភាគរយនៃសេដ្ឋកិច្ចប្រទេស។ ហើយអ៊ីចឹងរាយការណ៍បញ្ជូនទៅលើតាមថ្នាក់។ ព្រោះធម្មតារាយការណ៍ហើយ ឲ្យលើកហេតុផលហើយ វិធានយ៉ាងម៉េច ហើយបានវិធានយ៉ាងណាហើយ គេមើលត្រង់វិធាន ហើយគេជួយមកត្រង់វិធានការហ្នឹង។ យើងថែមទៅមុខត្រូវធ្វើអីទៀត បាន

អប់រំបន្ត។ ខ្វះស្បៀង បង្កើនផលធ្វើស្រែ ដាំដំឡូង។ ទាស់គ្នា អប់រំ បំបែកគ្នា។ ដោះស្រាយអ៊ីចឹង។ ហើយបើទាស់គ្នាខ្លាំង ដោះស្រាយមិនចេញ សុំជូនមកលើ។ លើមានយល់ដោះស្រាយ។ ប៉ុណ្ណឹង។ ប៉ុន្តែមិនងាយជូនទេ ខាងលើការងារច្រើនណាស់ យកការងារល្អិតទៅឱ្យហ្នឹង គាត់មិនដឹងជាងយើងដែលនៅក្រោមទេ។ ប្រៃល្វីងជូរចត់ គឺយើង។ ខ្ញុំអត់សួរជូន ជម្រាបត្រង់។ តែភ្លាមលើៗ លើបល់ ស្រះអែស្រះអុអីច្រើនហ្នឹង នាំតែស្មុគស្មាញកាន់តែខ្លាំង។ អ៊ីចឹងសូមអស់ប៉ុណ្ណឹង។

[១០:១២:៤៦]

**ស៖** សូមអរគុណសាក្សី។ សំណួរចុងក្រោយ លោកនិយាយអំពីស្ថានភាពស្មុគស្មាញ។ អ៊ីចឹងខ្ញុំចង់ដឹងថាតើស្ថានភាពបែបណា<>ដែលលោកត្រូវរាយការណ៍ថ្នាក់លើនោះ?

**ឆ៖** សូមជម្រាប រាយការណ៍ចង់បញ្ជាក់មិនបានទេ អត់អស់ ប៉ុន្តែគួររាយការណ៍ តែមួយសភាពការណ៍។ សភាពការណ៍ក្នុង ផ្ទៃក្នុងយើង សភាពការណ៍ខាងក្រៅ ពីក្រៅ។ ពីសភាពការណ៍ប្រជាជន តើចលនាប្រជាជនហ្នឹង តាមយើងទៅ ស្រុះនៅ? ឬក៏មានទំនាស់ ថាស្រុះប៉ុន្មានភាគរយ? ៧០ភាគរយទៅហើយ ទំនាស់តែ៣០ភាគរយ។ ទំនាស់បានដោះស្រាយអ៊ីចេះមួយអ៊ីចេះពីរ ត្រង់ហ្នឹង។ សភាពការណ៍សេដ្ឋកិច្ចអ៊ីចឹងទៀតទៅ។ សភាពការណ៍ផ្សេងៗទៀត រាយហើយវិធានការៗអ៊ីចឹង។ ហ្នឹងរបបធ្វើការងាររបស់ខ្មែរក្រហមអ៊ីចឹង។ បើយើងមិនឱ្យច្បាស់អ៊ីចឹង ខាងលើចាប់អត់ជុំទេ។ ដល់វាអ៊ីចឹងហើយ យើងកំពុងតែដោះស្រាយអ៊ីចេះ ហើយទៅមុខទៀត យើងធ្វើអ៊ីចេះ សុំយល់។ សូមអស់។

**លោកស្រី ម៉ារី ហ្គីរ៉ូដ៖**

សូមអរគុណលោកសាក្សី ខ្ញុំគិតថាម៉ោងខ្ញុំគឺអស់ហើយ។ អ៊ីចឹង ខ្ញុំសូមអរគុណលោកប្រធាន។ សូមអរគុណលោកសាក្សីដែលបានឆ្លើយទៅនឹងសំណួររបស់ខ្ញុំ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ ឥឡូវនេះដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅ រហូតដល់ម៉ោងដប់មួយ ខ្វះម្ភៃប្រាំនាទី សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សី និងអ្នកជំនាញដល់សាក្សីរូបនេះ នៅក្នុងអំឡុងពេលឈប់សម្រាក និងឱ្យអញ្ជើញគាត់ រួមទាំងមេធាវីប្រឹក្សាសាក្សីមកកាន់កន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការ នៅវេលាម៉ោងដប់មួយ ខ្វះម្ភៃប្រាំនាទី។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១០:១៥ នាទី ដល់ម៉ោង ១០:៣៦ នាទី)*

[១០:៣៦:៤០]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ មុននឹងផ្តល់វេទិកាជូនទៅមេធាវីការពារក្តី ចង់សួរទៅអស់លោក លោកស្រីចៅក្រម តើមានសំណួរអ្វីចង់សួរដល់សាក្សីរូបនេះដែរឬទេ? បើមានសូមអញ្ជើញបាទ។

សូមអញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍!

**ការតាំងសំណួរដោយចៅក្រម**

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

**ស៖** បាទ លោកសាក្សីខ្ញុំមានសំណួរមួយចំនួនសួរបន្តទៅទៀត ជាពិសេសសួរទាក់ទងទៅនឹងក្រុមគ្រួសាររបស់លោក។ តើលោកមានជាប់សាច់ឈាមអ្វីនឹង តាម៉ុក ដែរឬទេ?

**លោក ពេជ្រ ជឹម៖**

**ឆ៖** ជាប់ខ្លះ តែឆ្ងាយដែរហើយ។ វាឆ្ងាយ មិនមែនបងប្អូនបង្កើត ឬជីដូនមួយ ឬក៏បងប្អូននោះទេ។

**ស៖** អ៊ីចឹងលោកស្គាល់ តាម៉ុក តាំងពីពេលណាមក?

**ឆ៖** ពីក្មេង ឃើញស្គាល់ម្តង។ គាត់បួសហើយគាត់សឹក គាត់ទៅផ្ទះខ្ញុំ ទៅគោរពម្តាយខ្ញុំ។ គាត់ហៅម្តាយខ្ញុំមីង។ ទៅគោរពសំពះ ខ្ញុំឃើញគាត់ ស្គាល់ត្រឹមហ្នឹង ហៅតាជឿន មិនមែនតាម៉ុកទេ។ ម៉ែខ្ញុំថា “ហៅគេបងទៅ” ហើយហៅគាត់បងទៅ។ ចម្ងាយហ្នឹងធ្វើបុណ្យធ្វើទានអីប្រាប់គ្នាទៅវិញទៅមក ពីដូនតាមកអ៊ីចឹង។ ឯទទួលការអប់រំនយោបាយអត់ទេ។ ខ្ញុំរៀនសាលា ជំនាន់ពីដើមហៅសាលាបារាំង នៅវត្តថ្លុកជ្រុំ ឃ្លាតពីត្រពាំងធំវិញ អត់នៅត្រពាំងធំទេ។ នៅថ្លុកជ្រុំ រៀនមកសាលាបារាំងអង្គការ ហើយមកភ្នំពេញតែម្តង។ ហើយគាត់បួស ថ្នាក់បួស។ រៀនសាលាបាលី។

[១០:៣៩:៣៦]

**សៈ** សូមអរគុណ។ បើសិនជាខ្ញុំមិនច្រឡំទេ តាម៉ុក គឺជាក្មួយរបស់ម្ដាយរបស់លោក។ តើត្រឹមត្រូវដែរឬទេ?

**ឆះ** មិនមែនក្មួយបង្កើតទេ ក្មួយជីដូនមួយ ដូចឆ្ងាយដែរហើយ។ ត្រឹមត្រូវមែន។

**សៈ** បាទ ឥឡូវយើងចូលមកនិយាយអំពីបងប្អូន<បង្កើត>របស់លោកវិញម្ដង។ លោកបាននិយាយថាលោកមានបងប្អូនប្រាំមួយនាក់ ហើយលោកបាននិយាយថាលោកមានបងប្អូនប្រុសពីរនាក់ឈ្មោះ ពេជ្រ គិត ហើយនិង ពេជ្រ ណូ ហើយអ្នកទាំងអស់នោះសុទ្ធតែធ្វើការនៅក្រោមរបបកម្ពុជាប្រជាធិបតេយ្យ មានតំណែងធំ។ <មានសាក្សីម្នាក់បានប្រាប់ថា>លោកមានបងប្អូនម្នាក់ទៀតឈ្មោះតាគូ ហើយដែលឈ្មោះហ្នឹង គេៗហៅថា “តា<ស្រម៉ូម>” ផងដែរ។ តើលោកមានបង<>ប្រុសម្នាក់ឈ្មោះ<ស្រម៉ូម>ហ្នឹងដែរឬទេ? <>

**ឆះ** ដឹងតែគាត់ឈ្មោះ គូ មានមែន។ បងគូនេះ ភ្លោះជាមួយបងគិត បងភ្លោះ។ បន្ទាប់ពីបងភ្លោះហ្នឹងទៅបងស្រី – បងស្រីមួយ ហើយខ្ញុំ។ ឥឡូវខ្ញុំ ៧៩ ហើយ ម្ដាយជាងរយ ហើយបើមាននៅហ្នឹង បងស្រីទាំងអស់ ប៉ែតហើយ ស្លាប់អស់ហើយ ស្លាប់អស់ឆ្នាំទៅ បងបន្ទាប់។ ធ្វើបុណ្យឲ្យគាត់ហើយ នៅតែខ្ញុំទេ។

**សៈ** តើ គូ នៅរស់ដែរឬទេ? ឬក៏គាត់ស្លាប់ហើយ? បើស្លាប់នោះស្លាប់ក្នុងកាលៈទេសៈណាដែរ?

[១០:៤២:០៦]

**ឆះ** បងគូ ស្លាប់យូរណាស់ហើយ កាលណោះខ្ញុំនៅរៀន។ ពីសម័យសង្គម ខ្ញុំនៅរៀនភ្នំពេញ ន៏៦៨ មានការតឹងតែងរវាងផ្ទៃក្នុងប្រទេស ខ្មែរក្រហម ហើយខ្ញុំនៅរៀននៅភ្នំពេញ។ គេរកចាប់គាត់នៅនឹងភូមិឋានហ្នឹងរកចាប់។ គាត់រត់ចោលស្រុកអស់ទៅ ហើយខ្ញុំនៅរៀន មិនដឹងគាត់ទៅណា ទៅរកនៅឯណាឃើញ។ ប្រហែលមួយឆ្នាំបានឮដំណឹងថា -- ទៅហ្នឹង យកប្រពន្ធគាត់ទៅ ថាទៅរកស៊ីនៅកំពង់សិលា ជិតបន្ទាយទាហាន ហើយគាត់ស្លាប់ហើយ។ មានប្រវត្តិថាគាត់ទៅនោះមានម្នាក់ចូល ចូលធ្វើខ្មែរក្រហមជាមួយ មានកាំភ្លើងកាប៊ីនមួយដើម។ ថ្ងៃមួយដល់នាំគ្នាពីរនាក់ហ្នឹងដើរកាត់ព្រៃទៅ ចូលភូមិចាស់ ហេវទឹកដូង ហើយបេះដូងស៊ី ហើយដល់ឡើងខ្ញុំគ្រុន ដល់ខ្ញុំគ្រុនគាត់ឡើងខ្លួនគាត់ កាំភ្លើងនៅនឹងគល់ហ្នឹង អ្នកដែលទើបតែចូលហ្នឹងយកកាំភ្លើងបាញ់ផ្លូង ឡើងដល់ក ក៏ពង្រួលចុះ បាញ់មួយផ្លូងហ្នឹងខុស រុលមកទៀត ដល់ពាក់កណ្ដាលដង វាបាញ់មួយគ្រាប់ទៀតផ្លូងត្រូវធ្លាក់មកដីហ្នឹង។ គាត់

ស្លាប់ទៅ។ ខ្មោចកាលនោះមិនដឹងគេយកទៅណាទេ ប៉ុនឮដំណឹងហុយៗមិនច្បាស់ថា គេយកទៅដាក់ចោលនៅតាមផ្លូវ ដាក់ថាខ្មែរក្រហមថាឈ្មោះស្រម៉ូមហ្នឹង ដាក់នៅនឹងថ្នល់ជាតិហ្នឹង ដាក់ផ្សាយ អ៊ីចឹង។ ហើយគាត់មានកូនប្អូននាក់ ស្រីពីរ ប្រុសពីរ។ ប្រុស សម័យខ្មែរក្រហមហ្នឹង សម័យប្រាំឆ្នាំ បញ្ជូនមកបាត់ដំបង តាម៉ុក យកមក បាត់ទៅ បាត់លុះតឡូវ អត់ឃើញ។

**ស៖** បាទ លោកសាក្សី។ ខ្ញុំគិតថា គួរតែឈប់ប៉ុណ្ណោះហើយ ពីព្រោះថាយើងមានពេលវេលាតិច។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

លោកប្រធាន ខ្ញុំ<សូមការអនុញ្ញាត>ផ្តល់ឯកសារមួយសន្លឹកទៅសាក្សី ដែលមានសរសេរឈ្មោះលោកសាក្សី ហើយនិងរហស្សនាមរបស់គាត់ផងដែរ។ បើសិនជាលោកប្រធានអនុញ្ញាត ខ្ញុំសូមប្រគល់ក្រដាសទៅសាក្សីលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត។

[១០:៤៦:១១]

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

<ខ្ញុំសូម>ជូនដំណឹងចំពោះភាគី បុគ្គលនៅ<>លើក្រដាសនេះគឺគាត់មានលេខ <2-TCW-822> គឺជាសាក្សីដែលនឹងមកផ្តល់សក្ខីកម្ម<ក្នុងពេលឆាប់ៗ>។

**ស៖** លោកសាក្សី តើលោកស្គាល់ឈ្មោះដែលមានសរសេរនៅលើក្រដាសហ្នឹងដែរឬទេ? ហើយខ្ញុំសូម<>កុំឲ្យលោកនិយាយ អានឈ្មោះគាត់ ប្រាប់ឈ្មោះគាត់ឲ្យគេដឹង លោកស្គាល់បុគ្គលរូបហ្នឹងដែរឬទេ? សូមលោកឆ្លើយម្តងទៀត ពីព្រោះអម្បាញ់មិញនេះ មីក្រូអត់ទាន់បើកទេ។

**លោក ពេជ្រ ជឹម៖**

**ឆ៖** ស្គាល់។

**ស៖** តើគឺជាមនុស្សដែលជាប់សាច់ឈាមអ្វីនឹងលោកដែរឬទេ? ហើយបើសិនជាមានជាប់សាច់ឈាមនោះ សាច់ឈាមអ្វីដែរ? ហើយលោកសព្វថ្ងៃនេះ នៅតែមានទំនាក់ទំនងជាមួយគាត់ដែរឬទេ?

**ឆ៖** ដាច់ការទំនាក់ទំនង។ ត្រូវជាសាច់ឈាម ប៉ុន្តែអត់សូវទាក់ទងគ្នា គាត់កំបុតកំបុយពេក។ ជាប្អូនថ្លៃ។ ប៉ុន្តែការកូនមិនហៅ អានោះក៏មិនហៅ ដល់ខាងនេះអត់ហៅដែរ។ ត្រឹមប៉ុណ្ណឹង ជួបមាត់រក

មាត់។ អស់។

[១០:៤៨:២៧]

**ស៖** បាទ សូមអរគុណ។ សាក្សី <2-TCW-822> បាននិយាយដូចតទៅនេះ៖ អំពី តាគូ បងរបស់លោកថា គាត់ហ្នឹងត្រូវបានគេបាញ់សម្លាប់ ហើយ<គេ>កាត់<ក្បាល>ចោលនៅពេលដែលគាត់ឡើងបេះដូង។ បន្ទាប់មក គេ<យក>ក្បាលរបស់គាត់ទៅឲ្យសម្តេច នៅពេលដែលសម្តេចទៅសម្ពោធនៅព្រៃទប់។ បាទ នេះនៅក្នុងឯកសារ E319.1.31 នៅចម្លើយ<៣២>។ តើអ្វីដែលខ្ញុំអានអម្បាញ់មិញនេះ វា<ដូច>គ្នានឹងការចង់ចាំរបស់លោកដែរឬទេ? គឺថាបងរបស់លោកហ្នឹងត្រូវបានគេកាត់ក្បាលចោល ហើយបន្ទាប់មក <គេយកឲ្យ>សម្តេច<នៅក្នុងពិធី>សម្ពោធ<មួយ អ៊ីចឹងមែនទេ>?

**ឆ៖** ស្រប ស្របគ្នា ថាបើនិយាយឲ្យដូចបេះបិទ វាមិនដូច ប៉ុន្តែរឿងវាអ៊ីចឹង។

**ស៖** បាទ ឥឡូវខ្ញុំចូលទៅនិយាយប្រធានបទមួយផ្សេង ខ្ញុំសូមសួរលោកថា តើលោកមានស្គាល់បុគ្គលម្នាក់ ដែលឈ្មោះ រៀល សន<>ដែរឬទេ? គឺជា -- គាត់ គឺជាបុគ្គលម្នាក់ដែលជាអនុប្រធានមន្ទីរពេទ្យនៅស្រុកត្រាំកក់។

**ឆ៖** ស្គាល់ ប៉ុនមិនដែលនៅជាមួយទេ។ ទៅមក ឃើញគាត់នៅជាមួយ ខុម ហៅប្រើចុះឡើងនៅហ្នឹងយូរ។ ក្រោយមកឃើញនៅក្នុងពេទ្យ ប៉ុន្តែតែចាត់អីទៅណា ចាត់ចែងប្រើអី អត់មានទៅកាត់មុខគាត់ទេ គាត់ក្តាប់ខ្លួនគាត់ហើយ។

**ស៖** លោកសាក្សី តើអ្នកណាជាមានសិទ្ធអំណាចក្នុងការតែងតាំងកម្មាភិបាល <រួមមាន> ប្រធានភូមិ<>ឬក៏មេឃុំ ឬក៏ជាមេកង ឬក៏ប្រធានពេទ្យជាដើមនោះ? អ៊ីចឹង ខ្ញុំចង់សួរលោកថា តើការងារតែងតាំងនេះជាបន្ទុករបស់អ្នកណា? តើជា១ថ្នាក់ស្រុក ឬក៏ថ្នាក់តំបន់ ឬក៏អាជ្ញាធរផ្សេងទៀតជាទទួលបន្ទុកខាងការចាត់ តែងតាំងមនុស្សនេះ?

[១០:៥១:៤៥]

**ឆ៖** ថ្នាក់ស្រុក គឺស្រុកគេចាត់តាំង។ ចាត់តាំង គេយករាយការណ៍ទៅស្នើតំបន់ ឬថាមុនចាត់តាំងស្នើយោបល់ ពិគ្រោះហើយគាត់ឯកភាព។ ហើយឈ្មោះ សន នេះទៅនៅនឹងគាត់។ យូរទៅ ឃើញគាត់ចាត់តាំងទៅ មិនដឹងគាត់បានស្នើតំបន់ ឬអត់ទេ។ ខ្ញុំឃើញអ៊ីចឹងហើយ ក៏ស្របតាមហ្នឹងទៅ មិនបានមានពិគ្រោះគ្នាក្នុងគណៈទាំងអស់ អត់ទេ។ ប្រើអ៊ីចឹងទៅក៏ ដំណើរធម្មតា អត់ទំនាស់សតិអារម្មណ៍នឹងគ្នាទេ។

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ស៖** តើមានសេចក្ដីណែនាំជាក់លាក់អ្វីទេទាក់ទងនឹងការតែងតាំងកម្មាភិបាល? ហើយជាពិសេសនោះ តើកម្មាភិបាលដែលគេតែងតាំងនោះ ត្រូវមាន "ប្រវត្តិល្អ" គឺថាត្រូវតែជាក្នុងវណ្ណៈណាមួយ ជាសមាជិកនៃវណ្ណៈណាមួយ<ដែរឬទេ> ហើយតើវណ្ណៈនោះជាវណ្ណៈអ្វីដែរ?

**ឆ៖** ច្បាប់តែងតាំងតាមមាគ៌ារបស់បក្ស ល្អិតណាស់។ ឈរលើវណ្ណៈអ្នកក្រ កម្មករ កសិករសំដៅហ្នឹង។ ប៉ុនឈរលើវណ្ណៈកសិករហ្នឹង ខ្លឹមសារដែលខ្ញុំយល់គឺសំដៅមិនចាយធំ មិនខ្ជះខ្ជាយ សន្សំសំចៃ មិនលោភលន់ មិនដណ្ដើមយករបស់គេមកធ្វើជារបស់ឯង...។ល។ ហ្នឹង គេរើសគោលជំហរអ៊ីចឹង។ ឯមានធាតុ កូនកសិករពិត កសិករដែលល្អ ស្មោះត្រង់ ស្គាល់មេ ស្គាល់បា ស្គាល់បងប្អូន ស្គាល់សាច់ញាតិក្នុងស្រុក ដឹងខុសដឹងត្រូវ មិនព្រហើនកោងកាច មានសមត្ថភាព--

[១០:៥៥:៥៩]

**ស៖** លោកសាក្សី ខ្ញុំសូមឲ្យលោកឆ្លើយខ្លីៗ ព្រោះថាយើងមានពេលវេលាតិចណាស់។ បាទ ខ្ញុំមានសំណួរបន្ថែមមួយទៀតទាក់ទងប្រធានបទនេះ។ ខ្ញុំចង់ដឹងថា នៅពេលដែលគេតែងតាំង<បុគ្គលិក>ពេទ្យនោះ តើគេចាប់អារម្មណ៍ថា តើបុគ្គល<ទាំង>នោះត្រូវតែទទួលបានការបណ្ដុះបណ្ដាល<ផ្នែកពេទ្យ>ជាមុនដែរឬទេ? ឬក៏គេចាប់អារម្មណ៍តែថា ពីរឿងប្រវត្តិរូបបុគ្គលនោះ តើ<ពួក>គាត់មានប្រវត្តិរូបល្អ ឬអាក្រក់តែប៉ុណ្ណឹងទេ?

**ឆ៖** ក្នុងការចាត់តាំងនេះ តាមខ្ញុំឃើញប្រវត្តិរូបអត់សូវពិនិត្យទេ។ ពិនិត្យទៅសាច់ការគាត់ចេះពេទ្យ ហើយដល់នៅយូរៗទៅលើកទៅ។ នេះវាមិនទាន់ត្រូវមាគ៌ាណាដែរ ខុសដែរ។ សូមអស់។

**ស៖** បាទ សូមអរគុណ។ ឥឡូវ ខ្ញុំសូមអានចម្លើយរបស់លោក រៀល <សន> មួយចំនួនដែលត្រូវបានស្ដាប់នៅថ្ងៃទី១៧, ១៨ មីនា <ឆ្នាំនេះ> នៅក្នុងសវនាការនេះ។ ហើយគាត់បាននិយាយអំពីកិច្ចប្រជុំមួយ<ចំនួន>ដែលគាត់បានចូលរួម<>។ អ៊ីចឹង ខ្ញុំសួរលោកថា តើលោកធ្លាប់បានចូលប្រជុំ <>ឬក៏បានធ្វើជាគណៈអធិបតី<ក្នុងកិច្ចប្រជុំថ្នាក់ស្រុកដែល>លោក រៀល <សន> បានចូលរួមជាមួយនឹង<>មេឃុំ ហើយនិង<ថ្នាក់ដឹកនាំ> មេតំណែងផ្សេងទៀតនៅក្នុងស្រុកហ្នឹង? ហើយសិនជាអ៊ីចឹងមែនតើនៅក្នុងកិច្ចប្រជុំនោះមាននិយាយអ្វីខ្លះ? <មានគោលបំណងអ្វីខ្លះ?>

[១០:៥៧:០១]

**ឆ៖** អត់ចាំ។ ប្រជុំស្រុកមានពេទ្យនេះ រៀបចំចាត់តាំង អត់មាន។ អត់ដែលបានធ្វើ អាចគាត់ធ្វើ ហើយខ្ញុំនៅសមរភូមិ។ ចុះខាងក្រោម ចុះកន្លែងផ្សេង ឬនៅតាមប្រឡាយ ព្រោះការងារចែកគ្នា មិន

ងាយធ្វើបានមូលទាំងអស់គ្នាទេ។ សូមអស់។

**ស៖** លោក រៀល <សន> បាននិយាយពីកិច្ចប្រជុំមួយចំនួនដែលមានការចេញសេចក្តីណែនាំទាក់ទងនឹងការបោសសម្អាត។ ដោយជាក់លាក់តែម្តង គាត់បាននិយាយពីកិច្ចប្រជុំ<លើកទី>មួយដែលប្រហែលជាបានប្រព្រឹត្តទៅនៅមុនថ្ងៃទី១៧ មេសា ឆ្នាំ១៩៧៥ បន្តិច។ គាត់បានឆ្លើយនៅ<ក្នុងសវនាការ>ថ្ងៃទី១៨ មីនា ឆ្នាំ២០១៥ ប្រហែលជាម៉ោង១៥:០៨ គឺឯកសារ E1/279.1 គាត់បានឆ្លើយដូចតទៅនេះ <ខ្ញុំសូមដកស្រង់៖> "តាជឹម បានចេញសេចក្តីណែនាំ ដែលខ្ញុំបានរៀបរាប់ប្រាប់ គាត់បានប្រកាសថាទាក់ទងតែស្រុកត្រាំកក់តែប៉ុណ្ណោះ។ អ្នកដែលត្រូវបានគេជម្លៀសនោះ នឹងត្រូវប្រមូលផ្តុំនៅតាមវត្ត នៅតាមភូមិ និងតាមឃុំនៃស្រុកត្រាំកក់។អាស្រ័យហេតុដូច្នេះហើយបានជាគេកោះហៅប្រធានភូមិ មេឃុំទាំងអស់ឲ្យចូលរួមក្នុងកិច្ចប្រជុំនេះ។ ពួកគាត់ទាំងអស់នេះត្រូវតាមដានអ្នកជម្លៀស ហើយត្រូវមើលឲ្យដឹងថា តើអ្នកណាជាអតីតមន្ត្រីរដ្ឋការ ឬក៏យោធា លន់ នល់"។

[១០:៥៩:០៣]

ហើយនៅក្នុងសវនាការនេះដែរ រៀល <សន> បាននិយាយពីកិច្ចប្រជុំមួយទៀត ហើយគាត់និយាយពាក្យពេចន៍នេះនៅម៉ោង<១៥:១៦:២៦>វិនាទី "នៅក្នុងកិច្ចប្រជុំទី២នេះ តាជឹម បានចេញ -- ដាក់ផែនការដដែលទៀត នៅពេលនោះអ្នកដែលគេជម្លៀសមកនោះនៅតាមឃុំ តាមភូមិទាំងអស់ ហើយគាត់បានសុំឲ្យប្រធានភូមិ ហើយនិងមេឃុំតាមស្រាវជ្រាវក្នុងចំណោមអ្នកដែលគេជម្លៀសមកនោះ ដើម្បីឲ្យដឹងថា តើអ្នកណាជាអតីតយោធា <ឬជាមន្ត្រីរពាក់>ស័ក្តិ<ក្នុងជួរកងទ័ព> លន់ នល់ ឬក៏ដើម្បីឲ្យដឹងថា តើពួកគេនោះជាអតីតមន្ត្រីរដ្ឋការដែលមានឋានៈខ្ពង់ខ្ពស់ ដោយចាប់ផ្តើមពី<អភិបាលរងក្រុង>ទៅ។ បើសិន<>មានករណីនេះ ត្រូវតែបោសសម្អាតពួកនេះទាំងអស់នេះ។ គឺមេភូមិ មេឃុំ ហើយនិងប្រធានឈ្លបដែលត្រូវអនុវត្តគោលនយោបាយនេះ"។ អ៊ីចឹង ខ្ញុំអានពាក្យសម្តីរបស់ រៀល <សន> ជូនលោកស្តាប់ហើយ អ៊ីចឹងខ្ញុំសុំយោបល់ពីលោកវិញ។ តើលោកយល់យ៉ាងណាដែរ អំពីការលើកឡើងរបស់ រៀល <សន> នេះ?

**ឆ៖** សូមបញ្ជាក់ នេះផ្សាយផែនការរបស់ខាងលើ។ បើយើងទទួលហើយមិនផ្សាយ យើងខុស។ គឺផែនការខាងលើ ឲ្យពិនិត្យឡើងវិញ សល់ប៉ុន្មានអីប៉ុន្មាន ហើយរាយការណ៍ជូន ថាឲ្យទៅចាប់ ហើយគំនិតប៉ុនត្រឹមខ្ញុំមិនមានទេ។ សូមជម្រាប។

[១១:០១:២១]

**ស៖** តើលោកទទួលផែនការនេះពីអ្នកណា? ហើយផែនការនេះ បានផ្សព្វផ្សាយនៅពេលណាដែរ? ហើយជាផែនការអ្វីដែរ ជាក់លាក់នោះ?

**ឆ៖** សូមជម្រាប ថ្ងៃហ្នឹង ខុម ប្រជុំ មិនមែនតែខ្ញុំទេ។ សន និយាយហ្នឹងមិនត្រឹមត្រូវទេ។ ខ្ញុំគ្រាន់តែចូលរួម ប្រធានបក្សគេប្រជុំ។ រឿងធំ អាហ្នឹងបក្ស ប្រធានបក្ស។ ខ្ញុំក៏និយាយថែមតាមសាវាចរហ្នឹង មតិហ្នឹង។ ខុម ក៏និយាយ។ ឲ្យពូបន្ថែមទៀត ខ្ញុំក៏និយាយជាមួយគ្នា។ មិនមែនអត់ទេ ផ្សាយៗផែនការ។ បានធ្វើអ៊ីចឹងមែន ប៉ុន្តែអត់មានប្រមូលទេ ប៉ុនផ្សាយផែនការអ៊ីចឹង។ សូមអស់។

**ស៖** តើលោកបានដឹងអំពីផែនការនេះនៅពេលណា? តើនៅមុនថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥ ដូចដែលលោក រៀល <សទន> បានលើកឡើង ឬក៏នៅពេលក្រោយ ឬក៏ក្រោយយូរមកហើយ <ឬទើបតែក្រោយបន្តិចទេ ទើប>លោក<បាន>ដឹងរឿងនេះ?

**ឆ៖** រឿងនេះក្រោយ១៧ មេសា យូរខែ ប្រហែលបីបួនខែ ហើយដឹងពី ខុម។ ខុម យកផែនការមក មកប្រជុំផ្សាយប្រាប់។ ដឹងតាមប្រធាន – ប្រធានបក្ស។

[១១:០៣:២២]

**ស៖** បាទលោកសាក្សី ខ្ញុំសូមអានអ្វីដែល រៀល <សទន> បានលើកឡើង។ គាត់បានឆ្លើយថា៖ “គឺ<ផែនការនេះកើតឡើង>នៅពេល<ដែលប្រជាជន>ជិតត្រូវបានគេជម្លៀស <ឬស្ថិតក្នុងដំណាក់កាលនៃការជម្លៀស>”។ <អ៊ីចឹង> លោក<ចង់>និយាយថា <>លោក រៀល <សទន> នេះ ច្រឡំហើយ<មែនទេ> ឬក៏លោកនៅចាំថាលោកធ្លាប់បានទទួលបញ្ជាដែលត្រូវបានបញ្ជូនមកឲ្យលោកនោះមុនថ្ងៃទី១៧ មេសា?

**ឆ៖** ស្តាប់អត់ទាន់ៗ ជាន់ពេក។ ឆ្លើយមិនចំ។

**ស៖** អម្បាញ់មិញនេះ ខ្ញុំនិយាយថាសាក្សី រៀល <សទន> បានប្រាប់ថានៅពេលប្រជុំលើកទី១ មុនថ្ងៃ១៧ មេសា គេបានប្រាប់ថា អ្នកជម្លៀសទាំងអស់នឹងត្រូវបានប្រមូលផ្តុំនៅតាមវត្ត តាមភូមិហើយនិងតាមឃុំនៃស្រុកត្រាំកក់ហ្នឹង ហើយត្រូវតាមដានអ្នកជម្លៀស<>ទាំងអស់<នោះ> ហើយជាពិសេសហ្នឹង គឺត្រូវតាមដានឲ្យដឹងថាតើអ្នកណាជាអតីតមន្ត្រីរដ្ឋការ ឬយោធា? រៀល <សទន> ក៏បាននិយាយផងដែរ ថាមានកិច្ចប្រជុំទី២ នៅពេលក្រោយមកទៀត ដែលបទបញ្ជាដដែលនេះត្រូវបានដាក់ចេញ។ ខ្ញុំសួរថា បើតាមការចង់ចាំរបស់លោកនោះ តើមានកិច្ចប្រជុំតែម្តង ឬក៏មានពីរដង? ហើយបើមានតែម្តងនោះ តើកិច្ចប្រជុំនោះ ប្រព្រឹត្តឡើងមុនថ្ងៃ១៧ មេសា ឬក៏ក្រោយថ្ងៃ១៧មេសា?

**ឆ៖** តាមខ្ញុំចាំប្រជុំមានតែម្តងទេ ហើយក្រោយថ្ងៃ១៧ មេសា មុនអត់ទេ។

**ស៖** តើបទបញ្ជាហ្នឹងមានខ្លឹមសារជាក់លាក់យ៉ាងម៉េចដែរ ពីព្រោះថា លោក វៀល <សន> នោះបាននិយាយថាចេញបញ្ជាឲ្យបោសសម្អាត។ គឺបានន័យថា កម្ទេចប្រភេទមនុស្សដូចជា មន្ត្រីរដ្ឋការ <ជាន់ខ្ពស់> ឬក៏អតីតយោធាលន់ នល់ ជាដើមនេះ?

**ឆ៖** កាលនោះ ខុម យកផែនការហ្នឹងពីតំបន់មក មកផ្សាយអ៊ីចឹង។ ផ្សាយប៉ុនយើងផ្សាយប្រាប់ខុម។ ខ្ញុំបានចូលរួម។ តែមិនមានឃើញបោសសម្អាត មានឃើញហៅនរណាឡើង សួរបញ្ជាក់ថាអស់ឬនៅ? ថាអស់ហើយ មានអ្នកណាមាននៅ យកអស់ហើយ គេយកថ្ងៃ១៧ មេសា អស់ហើយតាមផ្លូវ។ និយាយត្រង់ៗអ៊ីចឹង មាននៅណាទៀត។ អ៊ីចឹងរកមើលទៅ ខុម គាត់ថារកមើលទៅក្រែងមាន។ សុំអស់។

**ស៖** បាទលោកសាក្សី អ៊ីចឹងអ្នកដែលគេប្រមូលផ្តុំទាំងអស់នោះ តើមានរឿងអ្វីកើតឡើងចំពោះពួកគាត់ ហើយជោគវាសនារបស់ពួកគាត់នោះ យ៉ាងណាដែរ?

**ឆ៖** គិតឃើញថា បើគេប្រមូលមែន ពួកហ្នឹងវាអស់អនាគតហើយ។ ជោគវាសនាវាអន្តរាយ។ ហ្នឹងផ្ទាល់ខ្លួនខ្ញុំ គិតឃើញអ៊ីចឹងតាំងពីហ្នឹងមក។

[១១:០៨:០៩]

**ស៖** បាទ ឥឡូវនេះ ខ្ញុំសូមរៀបរាប់ពាក្យពេចន៍របស់សាក្សីមួយទៀត គឺសាក្សី <2-TCW-822> នៅក្នុងចម្លើយរបស់គាត់គឺឯកសារ E319.1.2 ចម្លើយ២៧ ដែលនិយាយអំពីលោក គាត់និយាយដូចតទៅនេះ គាត់ថា៖ "តាជឹម បានបង្កើតស្ថាប័នអំណាចនៅខែមិថុនា <ឬ>កក្កដា ឆ្នាំ១៩៧០ ហើយខ្ញុំឃើញ មានការចាប់ខ្លួនជាច្រើនក្នុងទ្រង់ទ្រាយធំ<ចាប់តាំងពីថ្ងៃនោះមក។ នៅថ្ងៃមួយ> ខ្ញុំឃើញ<គេ>នាំមនុស្សទៅ ហើយខ្ញុំបានចោទសំណួរទៅអ្នកដែល<នាំមនុស្ស>ទាំងអស់<ហ្នឹង> សួរគាត់ថាទៅណា? <ពួកគេ>ឆ្លើយថា យើងទៅជួបអង្គការ។ ថ្ងៃបន្តបន្ទាប់មកទៀតនោះ ខ្ញុំដឹងថាមនុស្សដែលខ្ញុំបានឃើញទាំងអស់នោះត្រូវបានគេចាប់ខ្លួន ហើយអ៊ីចឹងទៅខ្ញុំលែងចោទសំណួរទៅ<ពួកគេ>ទៀត<ហើយ>។ ហើយអ្នកដែលគេចាប់ខ្លួនទាំងអស់នោះជាអតីតគ្រូបង្រៀន ហើយនិងមន្ត្រីរដ្ឋការ"។ តើលោកយល់យ៉ាងណាដែរអំពីពាក្យពេចន៍ទាំងអម្បាលម៉ានអម្បាញ់មិញដែលខ្ញុំបានអានជូននេះ?

**ឆ៖** សម័យនោះតឹង តឹងតែងណាស់ ខ្ញុំរកតែសុំលាឈប់។ សាន ក៏លាឈប់។ សុំចេញ។ ខុម អត់ឲ្យឈប់ទុកតែខ្ញុំមួយ។ ឯនាំមនុស្សជូនអ៊ីចេះអ៊ីចុះអត់មានទេ។ បើខ្លួនរកឈប់ រកច្រកចេញដែរ ថា

ឱ្យនាំគេអត់ទេ។ មានពីឃុំគេបញ្ជូនមក ហើយយើងបញ្ជូនបន្តទៅ មាន។ ប៉ុនលក្ខណៈដែលឃើញថាមានប្រហោងហ៊ាន ហ៊ានជួយ បើអត់ប្រហោង ខ្លួនឯងភ័យដែរ។ សានក៏បាត់ ខ្ញុំក៏បាត់ គ្រូបង្រៀន ១០៥នាក់ហ្នឹង ខ្ញុំហើយនិង សាន គ្រប់គ្រង។ បាត់ទាំងអស់ នៅអឿនមួយ – នៅពូអឿន ធ្វើជាមួយខ្ញុំ។ ប៉ុនគេសម្រាកគេទៅផ្ទះៗទេ មិនមែនសុទ្ធតែគ្រូបង្រៀនត្រូវគេចាប់ នៅរស់ៗរាល់ថ្ងៃហ្នឹង ខ្លះរត់រហូតមកភ្នំពេញមក។

**ស៖** បាទ នៅពេលដែលលោកនិយាយថាពួកគាត់ទាំងអស់នោះបាត់ខ្លួននោះ លោកចង់និយាយថាយ៉ាងម៉េច? តើមានរឿងអ្វីកើតឡើងចំពោះគាត់ទាំងអស់គ្នាហ្នឹង?

[១១:១១:២៤]

**ឆ៖** លោកគ្រូទាំងអស់ ១០៥ ហ្នឹង – ១០៥ នាក់ហ្នឹងបាត់ហ្នឹងគឺ អាគេអត់ប្រើ សូមជម្រាបឱ្យច្បាស់។ គេអត់សួរប្រើ គេថា អ្ហឺ! លោកគ្រូឱ្យទៅផ្ទះទៅ! ពួកនេះទៅផ្ទះទៅ ពួកនោះទៅផ្ទះទៅ។ ខ្ញុំទៅផ្ទះដែរ។ "ហ៉េ! អត់ឱ្យទេ" បងខុមថាអ៊ីចឹង។ សាន ទៅណា? ធ្វើការងារផ្សេងបាត់ទៅ ទៅផ្ទះដែរទៅ។ បានន័យថា ៧២ គោលជំហរវណ្ណៈ តស៊ូវណ្ណៈ កសិករ កម្មករ ទទួលដឹកនាំ ចុះយើងអនុធន តស៊ូបានធ្វើកើត តស៊ូអត់បានត្រូវតែខ្ចាតចេញ។ អានេះដឹងខ្លួនធាតុឯងអ៊ីចឹងទៅ គ្រូសុំមកផ្ទះមក អ្នកណាក៏សុំមកផ្ទះដែរ។ ចង់ន័យថា មកផ្ទះទៅវាសុខ ខ្លាច នៅហ្នឹងធ្វើខុសធ្វើត្រូវអីទៅមានទោសទៅ មកនៅផ្ទះរកស៊ីជាមួយប្រពន្ធ។ ហើយមិនមានចាប់អី គ្រូយកទៅសម្លាប់ទៅអី អត់មានទេ ខ្ញុំការពារកាលហ្នឹង ខ្ញុំការពារអត់មានចាប់អ្នកណាមួយសោះ ប៉ុនបើគេទៅភ្នំពេញទៅអី ទៅរកប្រាក់ខែខាងលន់ នល់ទៅ មានទៅបានបួនប្រាំនាក់។ តែបើថាគ្រូទាំងអស់មានចាប់ អត់មានទេ។

**ស៖** អ៊ីចឹងនៅក្រោមរបបកម្ពុជាប្រជាធិបតេយ្យ មនុស្ស<>អាចផ្លាស់ទីដោយសេរីអាចទៅភ្នំពេញហើយអាចកាន់មុខតំណែងខ្លួនឯងឡើងវិញ <>អ៊ីចឹងឬ លោកចង់និយាយអ៊ីចឹងឬ?

**ឆ៖** លោកស្ដាប់អត់ទាន់ ដល់សម្រាកមកផ្ទះអ៊ីចឹងគេមានឱកាសមានច្រកចេញ ៗផ្លូវវងវឹតទៅដើរចូលព្រៃទៅៗឡើងត្រាំខ្នាមក ជិះឡានហ្នឹងពេញហើយ ប៉ុនបើចេញមកគេចាប់បានងាប់។ អាហ្នឹងកម្រិតតស៊ូដល់ហ្នឹង ហើយខ្ញុំបើចេញ បើទៅក៏មានប្រាក់ខែស៊ីវិញ ប៉ុនចុះបើកូនប្រពន្ធនៅផ្ទះ ទៅរស់តែឯងម៉េចកើត ត្រូវគិតរកច្រកចេញហើយ សម័យតស៊ូ ៧២ កាលហ្នឹង។ សូមអស់ហើយ សូមខ្លីៗ។

**ស៖** លោក<សាក្សី ឆ្នាំ១៩៧២ ជាឆ្នាំសំខាន់ ប៉ុន្តែវានៅក្រៅវិសាលភាពនៃកិច្ចពិភាក្សានេះ។> ខ្ញុំសូមឱ្យលោកឆ្លើយនឹងខ្ញុំចាប់ពីថ្ងៃទី១៧ មេសា ឆ្នាំ១៩៧៥។ <ខ្ញុំចង់សួរថា> នៅ<ថ្ងៃទី១៧ មេសា>

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឱ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ឆ្នាំ១៩៧៥ នោះ <តើមានបញ្ហាឲ្យ>មានការចាប់ខ្លួន ហើយមានការបោសសម្អាតដែរឬទេ? ហើយអ្នកណា<ដែលត្រូវបានគេបោសសម្អាត>? ខ្ញុំមិនចាប់អារម្មណ៍នឹងឆ្នាំ១៩៧២ នោះទេបាទ។ លោកសាក្សី លោកអាចឆ្លើយនឹងសំណួរនេះដែរឬទេ? ឬក៏លោកមិនចង់ឆ្លើយនឹងសំណួរនេះទេ?

[១១:១៥:៤៨]

**ឆ៖** ឆ្លើយអត់ច្បាស់ មិនឃើញថាមានចាប់ ខ្ញុំអត់ដែរឃើញ។ ខ្ញុំក៏អត់ដែលធ្វើ ប៉ុន្តែបញ្ហា៧៥ នេះ ភ្លេចអ៊ីចេះ មានស្លាប់។ កងឈ្លបការពារខាងមុខ ឈ្លបមានស្រុកមួយក្រុម ឈ្លបឃុំ ១២ក្រុម ព្រោះ១២ឃុំ។ កងហ្នឹងការពារមកភូមិមុខអង្គតាសោម តាកែវ តាំងពីស្រែរនោងទៅ។ បើមានចាប់បានពីមុខមក រស់តិចណាស់ ហើយបើពីក្រោយចូលទៅ--

**ស៖** លោកសាក្សី អម្បាញ់មិញលោកបាននិយាយថា មានមនុស្សដែលត្រូវបានគេប្រមូលផ្តុំ ហើយជោគវាសនារបស់ពួកគាត់<រង>មហន្តរាយ<>។ តើ<ពួក>គាត់ទាំងអស់នោះត្រូវបានគេប្រមូលផ្តុំនោះ ដោយ<អនុលោមទៅតាម>ផែនការ <មែន ឬមិនមែន>។ តើផែនការនោះ ជាផែនការត្រូវកម្ទេចអ្នកដែលគេប្រមូលផ្តុំនេះដែរឬទេ? សូមលោកឆ្លើយថា បាទ ឬក៏ មិនទេ បានហើយ?

**ឆ៖** មិនទេ។

**ស៖** អ៊ីចឹងហេតុអ្វីក៏លោកថា ស្ថានភាពនៅពេលនោះជាស្ថានភាពអន្តរាយទៅវិញ?

**ឆ៖** ដល់និយាយវែងទៅបានស្តាប់បាន ព្រោះហៀបដល់នោះ កាត់។ និយាយហ្នឹង ក្នុងនាមលោកគ្រូហ្នឹង ដល់គ្រូហ្នឹង ឧបមាថា អនុធនទាំងអស់ហ្នឹសម្រាក អង្គការឲ្យសម្រាក ខ្ញុំទៅសួរ ខុម--

[១១:១៨:១៥]

**ស៖** លោកសាក្សី <ខ្ញុំសូមកាត់ចម្លើយរបស់លោក> ខ្ញុំមិនចាប់អារម្មណ៍នឹងក្រុមគ្រូទាំង១០៥នាក់នោះទេ ដែលលោកនិយាយក្នុងឆ្នាំ១៩៧២។ ខ្ញុំចង់ចាប់អារម្មណ៍ទៅលើអ្វី ទៅលើមនុស្សដែលគេបានឃុំខ្លួននៅ<ក្រោយ>ថ្ងៃទី១៧ <ខែមេសា> ឆ្នាំ១៩៧៥។ តើលោកយល់ច្បាស់ដែរឬទេ ខ្ញុំមិនចាប់អារម្មណ៍ក្រុមគ្រូនោះទេ ខ្ញុំចាប់អារម្មណ៍លើអ្នកជម្លៀសនៅក្នុងឆ្នាំ១៩៧៥ ថ្ងៃទី១៧ មេសា។ បើសិនជាលោកមិនចង់ឆ្លើយទេ លោកឆ្លើយថា មិនចង់ឆ្លើយទៅចុះ?

**ឆ៖** បាទ អត់បាន។ ខ្ញុំឆ្លើយអត់កើត វាអត់ច្បាស់ ចង់សួរសង្កត់យ៉ាងម៉េច?

**ស៖** ខ្ញុំគិតថា ខ្ញុំសួរអំមិញនេះច្បាស់ហើយ ខ្ញុំមិនដឹងថាសួរយ៉ាងម៉េចឲ្យច្បាស់ជាងហ្នឹងទៀតទេ។ ឥឡូវខ្ញុំសូមបន្តទៅសំណួរថ្មីមួយទៀត។ លោកសាក្សី រៀល <សន> គាត់បានឆ្លើយដូចតទៅនេះ៖

នៅក្នុងកិច្ចប្រជុំនៃគណៈស្រុកនោះ គាត់ត្រូវបានគេសួរអំពីមូលហេតុដែលមានមនុស្ស<ជាច្រើន>ឈឺនៅក្នុងមន្ទីរពេទ្យដែលគាត់គ្រប់គ្រង គឺថាមានជំងឺហើម ហើយនិងរាគរូស។ ហើយគាត់បានឆ្លើយថាស្ថានភាពនេះ បណ្តាលមកពីខ្វះជីវជាតិអាហារូបត្ថម្ភ ហើយនៅពេលដែលគាត់ឆ្លើយយ៉ាងដូច្នេះ ប្រធានស្រុក មេស្រុកនោះបាននិយាយមកគាត់វិញថា ពាក្យពេចន៍របស់គាត់ទាំងអស់នេះ វាជាការប្រឆាំងនឹងសហករណ៍ ជាការវាយប្រហារទៅលើសហករណ៍ហើយ។ គាត់បានឆ្លើយថា នៅពេលនោះ <>គាត់មិនប៉ានធ្វើសំណើអ្វី ដើម្បីឲ្យមន្ទីរពេទ្យនោះ មានស្បៀងអាហារប្រសើរនោះទេ។ ហើយលើសពីនេះទៅទៀត គាត់បានស្នើទៅ<>ជាច្រើន<ដង> ប៉ុន្តែមិនដែលមានចម្លើយអ្វីមកវិញទេ។ ចម្លើយរបស់គាត់ហ្នឹង គាត់ឆ្លើយនៅក្នុងសវនាការ គឺប្រតិចារឹកលេខ E1/278.1 ពីម៉ោងដប់ ១០:៤៧:៣៩ ទៅដល់ម៉ោងដប់១០:៥៣:២៤<វិនាទី>។ តើលោកចាំទេ តើលោកមានចាំថាកាលនោះលោកមានការព្រួយបារម្ភ ថាហេតុអ្វី -- មានព្រួយបារម្ភថាហេតុអ្វីបាននៅមន្ទីរពេទ្យមានអ្នកជំងឺច្រើន ហើយ<បារម្ភពីស្ថានភាពជំងឺ ហើយថា តើមនុស្សទាំងអស់>ហ្នឹងមានអាហារហូបចុកគ្រប់គ្រាន់ដែរឬទេ? លោកមានការព្រួយបារម្ភបែបហ្នឹងដែរឬទេ នៅពេលនោះ?

**ឆ៖** មាន ៗ។

[១១:២១:៣៧]

**ស៖** តើលោកគិតយ៉ាងណាដែរ អំពីអ្វីដែលលោក វៀល <សន> បាននិយាយនោះ គឺថានៅពេលដែលគាត់និយាយប្រាប់ពីស្ថានភាពនោះទៅលោកនោះ គេបានប្រាប់ថាការនិយាយដូច្នេះ គឺជាការវាយប្រហារលើសហករណ៍ហើយ?

**ឆ៖** កាលនោះ ឮដំណឹងហើយខ្ញុំអត់បានចុះផ្ទាល់ទេ បានវិធានការដោះស្រាយរកអង្ករឲ្យឃុំនៅជិតជាប់ហ្នឹង។ អង្ករ បន្លែ យកទៅជូន ប៉ុន្តែលទ្ធផលមិនដឹងយ៉ាងណា ខ្ញុំអត់បានទៅពិនិត្យថែម។ អ៊ីចឹង បានវិធានការដឹងរឿងហ្នឹង រឿងអ្នកពេទ្យឈឺ គ្រប់កន្លែងពេទ្យទាំងអស់។ អ្នកជំងឺ គឺថែបំប៉នចំណី។ ហើយសភាពនុ៎ង យល់ថាបងប្អូនចង្អៀត ស្អុកស្អាញ លំបាកណាស់ ភ័យហើយ បើមានអ៊ីចឹងយើងអត់គិតគូរ។ នេះអ្នកទទួល ត្រូវរួម ត្រូវតែគិតគូរដោះស្រាយ។ សុំអស់។

**ស៖** ខ្ញុំមានពេលវេលាខ្លីណាស់លោកសាក្សី។ ខ្ញុំសូមចូលទៅប្រធានបទថ្មីទៀត។ បាទ ខ្ញុំចង់ឲ្យលោករៀបរាប់ឆ្លើយថា <កាលនោះ> តើមានគោលនយោបាយទាក់ទងទៅនឹងការសង់ទំនប់ទប់ទឹក <អាងស្តុកទឹក>និងការជីកប្រឡាយអីដែរឬទេ? គឺជាគោលនយោបាយ<ដើម្បីឲ្យមានប្រព័ន្ធ>ស្រោច

ស្រប<ប្រសើរជាងមុននៅ>ទូទាំងប្រទេស។ តើលោកធ្លាប់បានទទួលសេចក្តីណែនាំយ៉ាងដូច្នេះដែរឬទេ ? ហើយបើមាននោះ តើអ្នកណាជាអ្នកដាក់សេចក្តីណែនាំទាំងអស់នេះ មកលោក?

[១១:២៣:៤២]

**ឆ៖** ណែនាំជាមាគ៌ា មាន ដល់យើងរៀនមាគ៌ា យើងយកមាគ៌ាហ្នឹងទៅអនុវត្ត។ ដល់ឃើញកន្លែងណាធ្វើទំនប់កើត ធ្វើប្រឡាយកើត ស្នើខាងលើ។ ខាងលើយល់ព្រម ទៅធ្វើ តែប៉ុណ្ណឹង។ ដី កាលនោះលែងនិយាយពីណា១ តែភូមិសាស្ត្រធ្វើទំនប់កើត វាធ្វើទៅ ដីរួមសមូហភាពអស់ហើយ។ អត់យកអាហ្នឹងធ្វើទំនប់ ឯងចង់បានយកខាងនោះវិញទៅ។ វាត្រូវដោះស្រាយអ៊ីចឹង។ អស់។

**ស៖** តើលោកមានតួនាទីជាក់លាក់<អ្វី>ដែរក្នុងការអនុវត្តគោលនយោបាយនេះ? នៅថ្ងៃទី១ ដែលលោកមកឆ្លើយនៅទីនេះ លោកនិយាយថាលោកមិនបានចូលរួមប្រជុំនៅក្នុងគណៈ<>ស្រុកទាំងអស់ទេ ព្រោះថាលោកត្រូវចល័តទៅតាមការដ្ឋាននានា។ អ៊ីចឹង តើតួនាទីរបស់លោក គឺត្រូវមើលការដ្ឋានទាំងអស់នៅក្នុងត្រាំកក់ ឬក៏យ៉ាងណា?

**ឆ៖** សូមបញ្ជាក់ ខ្ញុំមិនមែនថាមិន១ចូលរួមប្រជុំក្នុងរួមស្រុកទាំងអស់ទេ ថាមានពេលខ្លះខានប្រធានអនុញ្ញាតឲ្យខាន។ ថាថ្ងៃនេះមិនបាច់មកក៏បាន មកគ្នាប៉ុណ្ណេះ បែកទៅធ្វើខាងនោះ ព្រោះការងារវាច្រើន។ បញ្ជាក់រឿងច្រើនហួរហែមកប៉ុន្មានថ្ងៃហើយ ត្រង់ហ្នឹង សូមបញ្ជាក់ប៉ុណ្ណឹង។ ឯផែនការច្បាស់លាស់ ពិគ្រោះគ្នាក្នុងស្រុក ក៏ព្រមឲ្យធ្វើត្រង់ហ្នឹង តំបន់ក៏ព្រម ភូមិភាគមក តែតំបន់ព្រមធ្វើហើយព្រោះគាត់យកខ្លឹមសារហ្នឹង ហើយគូរប្លង់ឲ្យ ក្រដាសសៀវភៅហ្នឹងគូរដាក់គោល១ គូសប្លង់ឲ្យធ្វើយ៉ាងម៉េចអីយ៉ាងម៉េច។ ធ្វើដោយគំនិត រួមគ្នាបីបួននាក់ហ្នឹង ខាងស្រុកហ្នឹង មិនមានបច្ចេកទេសវិជ្ជាអីខ្ពង់ខ្ពស់អីណា អត់ទេ វាស់ទឹកដីយក គ្រាន់តែកម្ពស់ដីយកតាមផែនទី មើលត្រូវហូរទៅណា មើលខ្សែលេខដីដាក់ទៅ ធ្វើតែអ៊ីចឹងទៅ ហៅថាធ្វើវាវរក។ ដល់ធ្វើកើតបានថា "អ្ហែ! បាន *អាំងស៊ីងញ៉ើ* ណាមកវាស់ប្រឡាយពីពកវែកមកត្រាំកក់?" ខ្ញុំថា *អាំងស៊ីងញ៉ើ* ហ្នឹងទាហាន១អ្នកបួស ព្រោះគាត់ចេះវាស់ គាត់ចេះផែនទីដែរ។ មើល ធ្វើទៅកែវាខ្លះ អីខ្លះអ៊ីចឹងទៅ។ សូមអស់។

[១១:២៧:១១]

**ស៖** តើការអនុវត្តផែនការនេះទាក់ទងទៅនឹង<ការដ្ឋាន>ច្រើន<ទេ?> តើលោកអាចផ្តល់ទីតាំងការដ្ឋាន<សំខាន់១>នៅក្នុងស្រុកត្រាំកក់<បាន>ដែរឬទេ? ឧទាហរណ៍ដូចជា ទំនប់មួយដែលត្រូវបានសាងសង់នៅខ្ពបត្របែក <តើការដ្ឋាននេះ>ជាការដ្ឋានសំខាន់ជាងគេ<នៅស្រុករបស់លោកមែន

ទេ?>

**ឆ៖** ទំនប់ខ្ពបត្របែកនេះគឺត្រង់ហ្នឹងព្រៃៗ ហើយអូរត្របត់ហ្នឹងមានអន្លង់ថ្លុកជ្រៅៗ ហើយពាក្យខ្មែរហៅថា ខ្ពបៗនោះ។ ហើយខាងទួលខាងលិច ទួលខាងកើត ទួល។ ក៏ពិគ្រោះតំបន់ៗយល់ព្រម ហើយគាត់ស្នើទៅ តាម៉ុក យល់ព្រមក៏ធ្វើ។ ឯប្រឡាយមកកាត់មកហ្នឹង រាវរកទេអាហ្នឹង រាវរកដោយស្នានផ្អែកលើផែនទី និងកម្ពស់ដី។ ឯការប៉ះពាល់មាន មានភូមិនៅក្នុងហ្នឹង ខ្ញុំភ្លេចហើយផ្ទះប៉ុន្មាន ប៉ុន្តែរុះចេញមកនៅខាងវាល លើៗខ្នងទំនប់បណ្ដោយមកលិច។ ហើយតាមប្រឡាយមកបុកផ្ទះភូមិ ទៅចំតាមួយអានោះ ឃុំសំរោងមកទល់ឃុំគុស។ ហើយខាងហ្នឹងងាកៗ ចុចតិចៗងាក។ មួយចំហ្នឹង ឲ្យគាត់នៅក្បែរហ្នឹងរុះរើជួយធ្វើគាត់។

[១១:២៩:២៥]

**ស៖** លោកសាក្សីចំនួនមនុស្សដែលធ្វើការនៅតាមការដ្ឋានទាំងអស់នេះ លោកប៉ាន់ប្រមាណថាមានរាប់<រយ>នាក់ ឬក៏ពាន់នាក់ ឬក៏រាប់ម៉ឺននាក់? យើងមានសាក្សីម្នាក់គឺលោក សូត្រ សាំង ដែល<>គាត់បានឆ្លើយថាគាត់ធ្លាប់ធ្វើការនៅខ្ពបត្របែក គាត់បាននិយាយថាមានមនុស្សរាប់ម៉ឺននាក់ដែលធ្វើការនៅទីនោះ<>។ តើលោកយល់យ៉ាងណាដែរ អំពីចម្លើយរបស់ សូត្រ សាំង នេះដែលគាត់ថា មានអ្នកធ្វើការនៅទីនោះរាប់ម៉ឺននាក់ឯណោះ?

**ឆ៖** សូមជម្រាប មួយហៅកងចល័ត ណែនរឹង មានមេកងរួមក្ដាប់នៅហ្នឹង។ មិនមែនខ្ញុំធ្វើមេកងទេ។ ហ្នឹងមាន៨០០០ ស្រីប្រុសនោះ។ មេកងខាងស្រីមួយ មេកងខាងប្រុសមួយ។ ខ្ញុំទៅនាមគ្រាន់តែប្រជុំ មីទ្និង អប់រំ ជំរុញធ្វើ បានប៉ុណ្ណឹង ហើយម្ចាស់ការតាមឃុំ។ ឃុំទាំង១៤ កាលខ្ញុំនៅហ្នឹងឃុំ *(ឮមិនច្បាស់)* ស្រុកត្រាំកក់។ ឃុំ១៤ យកពីខាងឈូកខ្សះ។ ឃុំ១៤ មួយកងៗមកទៀត ទៅធ្វើភ្លាមច្រើនអ៊ីចឹងមែន។ ហ៎ក! មេកងខាងស្រុក កងខាងឃុំ កងស្រុកពីរ វា “ក, ខ” ប្រុសស្រីទៅ ប្រុសស្រីហ៎ក! ជួនយុវជន ជួនយុវនារី ហើយឃុំក៏អ៊ីចឹងទៀត។ មីទ្និង អប់រំអីហ្នឹងនៅហើយ។ មីក្រុមកទាំងអស់ហើយ ហើយបានបែកកងតូចៗនេះទៅ។ អ៊ីចឹង ថៅហ្វាយស្រុកមិនមែនមកក្ដាប់កងតូចៗបានទេ។ ក្ដាប់តែមេទេ ហើយដោះស្រាយអង្ករ ខោអាវ។ ជួនដេរៗទៅ ដឹកយកទៅ អ្នកណាដើរចែកឲ្យៗ។ ថ្នាំពេទ្យ។ ថ្នាំអត់ចេះធ្វើផង ក្រណាស់ថ្នាំ។

[១១:៣២:២៣]

**ស៖** លោកសាក្សី ខ្ញុំសូមអានចម្លើយរបស់សាក្សី 2-TCW-822, គឺE319.1.32 <ត្រង់>

ចម្លើយ៦៣ គាត់និយាយថា៖ "នៅក្នុងឆ្នាំ១៩៧២ ប្រជាជននៅក្នុងស្រុកកោះអណ្តែតបាន<>ភៀសខ្លួន <ទៅ>វៀតណាម ហើយក្រោយមក តាម៉ុក ក៏បានយកវៀតណាមដែលរស់នៅប្រទេសកម្ពុជាទៅដូរ មនុស្សទាំងអស់នោះឲ្យត្រឡប់មកវិញ។ មានម្តង តាម៉ុក បានដូរខ្មែរ ឲ្យត្រឡប់មកវិញចំនួន៩០នាក់ ហើយក៏ប្រគល់ឲ្យទៅតាជឹម ដើម្បីឲ្យជួយ<រែកដី>ជីកប្រឡាយនៅខ្ពកត្របែក។ តាជឹម ថាខ្មែរទាំង ៩០នាក់នោះ ចេះតែលួចពេក ហើយក៏យកអ្នកទាំងអស់នោះទៅសម្លាប់ចោលទៅ។ មួយខែក្រោយមក តាម៉ុក ក៏មកមើលខ្មែរទាំង៩០នាក់នោះ ដោយនិយាយជាមួយ តាជឹម ថា ឯណាមនុស្ស? តាជឹម ឆ្លើយ ថា វ៉ៃចោលអស់ហើយ ព្រោះលួចពេក។ តាម៉ុកហ្នឹង គាត់<ស្រែកគំហក>ខ្លាំងៗដាក់ តាជឹម ថា <"ស្មានតែងាយរកមនុស្ស?> មុខឯងហ្នឹងរកមនុស្សបានទេ។ អញខំរកមនុស្សឲ្យមកជួយធ្វើការ ម៉េច យកគេទៅសម្លាប់អ៊ីចឹង។ មុខអ្នែងហ្នឹងរកមនុស្សបាន?"។ តើលោកមានចាំឧបទ្ទវហេតុហ្នឹងទេ ទាក់ទងទៅនឹងមនុស្សទាំង៩០នាក់ហ្នឹង ដែលត្រឡប់មកពីវៀតណាមវិញ ដែលត្រូវបានសម្លាប់នៅពេល ដែលគេបានបញ្ជូនឲ្យពួកគាត់ទាំងអស់នោះ ទៅធ្វើការនៅទំនប់ខ្ពកត្របែកនោះ?

[១១:៣៤:៤១]

**ឆ៖** មិនបានរឿង មិនដែលមានជួបរឿងអ៊ីចឹងទេ។ សូមបដិសេធ អត់ដឹង។ ហើយរឿងអ្នក កម្ពុជាក្រោមមកនៅស្រុកត្រាំកក់ ជារឿងតំបន់។ ត្រាំកក់ ទៅល្វេកអីឆ្ងាយម្ល៉េះ ឆ្លងទ្រាំង គិរីវង់ កោះ អណ្តែត ទៅយកណា។ រឿងតំបន់ គេយកមក។ តំបន់គេដោះស្រាយ។ អ្នកមិនដឹងចេះតែនិយាយតាម តៗគ្នាទៅក៏អត់ត្រូវ។ ខ្ញុំមិនទទួល ពាក្យហ្នឹងអត់ទទួល។ មិនដែល ទាំងដែល តាម៉ុក យកមកឲ្យខ្ញុំអ៊ីចឹង អត់។

**ស៖** បាទ ខ្ញុំមានសំណួរចុងក្រោយ<ដោយសារយើងជិតដល់ម៉ោងហើយ>។ តើលោកមានចាំ ធ្លាប់បានឃើញថ្នាក់ដឹកនាំមកធ្វើទស្សនកិច្ចនៅស្រុកត្រាំកក់ដែរឬទេ? ជាពិសេស គឺមកមើលសហ- ករណ៍ ហើយនិងការដ្ឋានការងារ? លោកមានចាំមានពិធីមួយដែលមានការផ្តល់រង្វាន់ទង់បដិវត្តន៍ គេ ហៅទង់កិត្តិយស ឲ្យ<នរណាម្នាក់>នៅត្រាំកក់ហ្នឹងដែរឬទេ?

**ឆ៖** ទង់កិត្តិយស ខ្ញុំជម្រាបជូនខ្លី បានរួមនិងបានទទួល ក្នុងនាមស្រុកត្រាំកក់ គឺប្រគល់ដាក់មុខ ខ្ញុំហ្នឹងឯង។ ក្នុងនាមឲ្យកម្មាភិបាលទាំងអស់រួមគ្នា មិនមែនឲ្យបុគ្គលទេ ប៉ុនអត់ចាំទេ អត់ចាំថ្ងៃខែ។ ទង់ហ្នឹង៧៦ ហើយឬក៏៧៥ទេ ក្រោយរំដោះ។ បានស្រុក -- សុំសាឡើងវិញ ខ្លីពេក។ បានត្រាំកក់ បាន ស្រុកប្រសូត្រថ្មី បានស្រុកសំឡូត មួយកម្ពុជាបានបីហ្នឹង។ មេដាយមាស ដោយឆ្លងកាត់ច្បាំងហ្នឹងមក

ខំធ្វើស្រូវបានចិញ្ចឹមខ្លួនឯងគ្រាន់ ហើយចិញ្ចឹមកងទ័ពថែមទៀត។ ឯបាត់ដំបងដែលស្រូវដីខ្លាញ់ អត់បាន។ អាហ្នឹងប៉ុណ្ណឹង។

[១១:៣៨:០៣]

**ស៖** បាទ ខ្ញុំសុំការបំភ្លឺមួយ។ តើថ្នាក់ដឹកនាំ<>ដែលទៅនោះ<មាននរណាខ្លះ? តើអ្នក> មកផ្ដល់រង្វាន់នោះ ទង់កិត្តិយសនោះ <មាន>អ្នកណាខ្លះ ហើយក្រៅពីពិធីហ្នឹង មានការធ្វើទស្សនកិច្ចអីផ្សេងទេ ដូចជាដើរទៅមើលការដ្ឋាននានានៅស្រុកត្រាំកក់ជាដើមនេះ?

**ឆ៖** ការផ្ដល់រង្វាន់នោះ មានតែតាម៉ុក អត់មាននរណាមកទេ។ អាហ្នឹងឆ្នាំនោះ ជាន់ទំនប់បាក់ផង។ ខ្ញុំទប់ទំនប់ហើយ វិលមកវិញចប់សន្និបាត ប្រគល់រង្វាន់ហ្នឹង។ ខ្ញុំចេញបីថ្ងៃ ចេញពីសាលា ទឹកកំពុងតែជន់នេះ បាក់ ទប់ឈ្នះ កម្លាំង៨០០០ ដាក់ដីសងខាង តែមួយព្រឹបឈ្នះ ៥នាទី ទឹកហ្នឹងចាក់ដីផុចបាត់ឈឹង។ ក្បាច់គិតក្បាច់ស្រី គិតៗទៅឃើញ ធ្វើទៅ។ ដាក់ឈើតាមទឹក ដោត យកស្លឹកត្នោតទៅបាំងៗ ដាក់គ្រីបៗ ទឹកធាក់វិញវឹង ចាក់ដីពីបឡើងខ្ពស់ហួស ជាន់ទៅឈ្នះបាត់។ ប៉ុនមុនធ្វើយកដីគរសងខាងឲ្យច្រើន។ ស្ទូមអស់ហើយ។

**ស៖** ដើមបណ្ដឹងរដ្ឋប្បវេណីពីរនាក់បានមកផ្ដល់សក្ខីកម្មនៅទីនេះ បាននិយាយថាមានមេដឹកនាំពីរនាក់គឺ នួន ជា និង ខៀវ សំផន បានទៅធ្វើទស្សនកិច្ចនៅតាមការដ្ឋាន នៅពេលដែលពួកគាត់កំពុងតែ<ដឹកប្រឡាយ>។ តើលោកមានចាំពីទស្សនកិច្ចរបស់លោក ខៀវ សំផន ហើយ នួន ជា នៅស្រុកត្រាំកក់ដែរឬទេ?

[១១:៤០:២៧]

**ឆ៖** ដឹងថាមានគាត់ទៅ ប៉ុនរកនឹកថាទៅជួបគាត់ត្រង់ណា នៅកន្លែងណារកនឹកអត់ឃើញភ្លេច ហើយក៏ -- គាត់ទៅមើល -- ដឹងអ្នកនាំទៀត ឈ្មោះ សេនៗនាំ គាត់ទៅមើលសហករណ៍ មើលគ្រប់ ប៉ុន្តែថាជូនដើរចុះឡើង ខ្ញុំអត់មានជូន រកនឹកមិនឃើញ។ ហើយក៏ថ្ងៃទៅហ្នឹង ខ្ញុំជាប់ការងារនៅខាងមុខ អត់បានមកក្រោយ គេចែកគ្នា ប៉ុន្តែមិនទំនងអត់មក។ អ៊ីចឹងស្រពេចស្រពិល ប៉ុនគាត់ទៅមានទៅ។

**ស៖** លោកនិយាយអំមិញថា "គាត់ហ្នឹង" អ្នកណាគេគាត់ហ្នឹង? លោកនិយាយគាត់ហ្នឹងសំដៅលើ នួន ជា? សំដៅលើ ខៀវ សំផន ឬសំដៅលើអ្នកណាផ្សេងទៀត?

**ឆ៖** គឺលោក នួន ជា និង លោក ខៀវ សំផន ពិតជាមានទៅមែន។ ប៉ុនគ្រាន់ខ្ញុំបញ្ជាក់ថា ខ្ញុំជូន

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ទៅណាមកណា អត់ នឹកអត់ឃើញ វាភ្លេចអីយ៉ាងម៉េច ប៉ុនគាត់ពិតជាមានទៅពិនិត្យស្រុកត្រាំកក់។

**ស៖** បាទលោកសាក្សីសូមអរគុណច្រើន។ បាទ ខ្ញុំសូមអភ័យទោសផងដែរ ដែលខ្ញុំបានសួរសំណួរលើសពេលវេលាបន្តិច។ សូមអរគុណលោកប្រធាន ខ្ញុំអស់សំណួរហើយ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ឥឡូវនេះដល់ពេល សម្រាកថ្ងៃត្រង់ហើយអង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅ រហូតដល់ម៉ោងមួយនិងសាមសិបនាទីរសៀលនេះ សូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សី និងអ្នកជំនាញ ដល់សាក្សីរូបនេះ នៅក្នុងអំឡុងពេលឈប់សម្រាក និងឲ្យអញ្ជើញគាត់ រួមទាំងមេធាវីប្រឹក្សាសាក្សីមកកាន់កន្លែងផ្តល់សក្ខីកម្មនៅបន្ទប់សវនាការនេះ នៅវេលាម៉ោងមួយ និងសាមសិបនាទីរសៀលនេះ។

បង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំង នាំខ្លួនលោក ខៀវ សំផន ទៅកាន់បន្ទប់រង់ចាំខាងក្រោមសាលសវនាការនេះ និងបង្គាប់ឲ្យនាំខ្លួនគាត់ត្រឡប់ចូលរួមសវនាការនៅក្នុងបន្ទប់សវនាការនេះវិញ នៅរសៀលនេះ ឲ្យបានមុនម៉ោងមួយ និងសាមសិបនាទី។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១១:៤៣ នាទី ដល់ម៉ោង ១៣:៣១ នាទី)*

[១៣:៣១:២៣]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

បាទ អង្គជំនុំជម្រះបន្តកិច្ចដំណើរការនីតិវិធីសវនាការ ហើយនៅរសៀលនេះ ដោយសារមេធាវីប្រឹក្សាសាក្សី មឿន សុវណ្ណ មានធុរៈ ត្រូវជំនួសដោយមេធាវី ម៉ម រិទ្ធា។

លោក ពេជ្រ ជឹម អង្គជំនុំជម្រះអរគុណលោកដែលបានលោកសហការ ហើយឆ្លើយតបនឹងសំណួររបស់ភាគី និងចៅក្រមអង្គជំនុំជម្រះក្នុងរយៈពេលកន្លងមកនេះ បានយ៉ាងល្អ ដោយសារលោក

មានការសហការ និងប្រឹងប្រែងខិតខំឆ្លើយតបរាល់សំណួរដែលបានសួរ ហើយតទៅនេះ ខ្ញុំមានសំណួរមួយចំនួនតូចទេ ដើម្បីសួរបញ្ជាក់ចំពោះលោក។

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** កាលពីព្រឹកមិញនេះ លោកបានឆ្លើយចុងម៉ោង មុនសម្រាក គឺលោកបានឆ្លើយថា "ស្រុកត្រាំកក់ បានទទួលនូវទង់ក្រហមកិត្តិយសជាស្រុកគំរូ ក្នុងចំណោមបីស្រុកនៅទូទាំងកម្ពុជាប្រជាធិបតេយ្យ"។ យើងចង់ដឹងថា តើលោកដឹងទេកត្តាអ្វីខ្លះដែលនាំឲ្យស្រុកត្រាំកក់បានទទួលទង់ក្រហមកិត្តិយសជាស្រុកគំរូនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ កាលពីពេលនោះ?

[១៣:៣៣:៣៦]

**លោក ពេជ្រ ជីម៖**

**ឆ៖** សុំមានយោបល់ សូមគោរពលោកប្រធាន និងអស់លោកទាំងអស់។ សូមលើកពីហេតុដែលនាំឲ្យស្រុកត្រាំកក់ បានជាឈ្មោះជាគំរូនៅក្នុងតំបន់ គឺហេតុមានច្រើនដែរ ប៉ុន្តែសូមលើកតែបី៖ ១) មានកម្លាំងល្អ មានច្រើន ហើយល្អ ឧបត្ថម្ភដល់ចលនាបដិវត្តន៍ ទាំងកម្លាំងទ័ព ទាំងកម្លាំងប្រជាជនទាំងកម្លាំងស្នូលជាកម្មាភិបាល។ ២) ប្រជាជនភាគច្រើន គឺស្រទាប់កណ្តាល ហើយក្រ ខាងក្រោម ហើយមានលក្ខណៈស្មោះត្រង់ជាមួយនឹងបដិវត្តន៍ ជំហរស្មោះត្រង់។ ៣) កត្តាទី៣ គឺសេដ្ឋកិច្ច ជាស្រុកក្រ ដីអន់ ប៉ុន្តែបានផលលើសស្រុកដែលខ្លាញ់ក្នុងប្រទេស។ ហ្នឹងទាក់ទងដល់ប្រជាជន ហើយកម្មាភិបាលទាំងអស់ក្នុងស្រុក ជ្រះស្រឡះហើយ ខំធ្វើៗម្តង ពីរដង ធ្វើបានពីរដងក្នុងមួយឆ្នាំ ហើយមានរួមផ្សំដំឡូង។ ទៅៗជាគ្រាន់ខ្លួនឯង ដោយរហូតឧបត្ថម្ភទូទាំងប្រទេសសម័យនោះ។ ហេតុផលបីហ្នឹងដែលខ្ញុំសូមលើកជូនអង្គប្រជុំ។ សូមអស់។

**ស៖** បាទ អរគុណលោក ពេជ្រ ជីម។ ខ្ញុំចង់ដឹងមួយទៀតថា តើនៅក្នុងស្រុកត្រាំកក់ទាំងមូលកាលពីសម័យនោះ គោលរបបនៃការបែងចែកទៅឲ្យប្រជាពលរដ្ឋហូបចុក តើធ្វើការបែងចែកស្មើៗគ្នាគ្រប់សហករណ៍ទាំងអស់ ឬក៏វាអាស្រ័យទៅលើសហករណ៍នីមួយៗបានផលច្រើន ឬក៏បានផលតិចទទួលគោលរបបនៃការហូបចុកសអាស្រ័យទៅលើមូលដ្ឋាននៃឃុំ ឬក៏សហករណ៍នីមួយៗ?

[១៣:៣៧:០០]

**ឆ៖** កាលនោះ គោលរបបដូចគ្នា បីកំប៉ុង តាមខ្ញុំចាំ។ បីកំប៉ុង មួយកំប៉ុងបីនាក់។ ដល់បានរំដោះទូទាំងប្រទេស វាឡើងមួយកំប៉ុងប្រាំមួយនាក់ ប្រជាជនពាក់កណ្តាលម្នាក់កាលរំដោះ នៅតំបន់រំដោះក៏

ពាក់កណ្ដាល ស្មើគ្នានឹងតំបន់ខាងលោក លន់ នល់។ ហើយរបបហ្នឹងវាទ្វេមក ខ្ញុំជម្រាបជូនពីម្សិល ហើយ។

**សៈ** ចុះបន្ទាប់ពីការបង្កើតសហករណ៍ ហើយលោកបានលើកឡើងអំមិញ ដោយសារការទទួល ទង់កិត្តិយស ទង់ក្រហមកិត្តិយសជាស្រុកឈានមុខហ្នឹងដោយសារកត្តាជាច្រើន បីកត្តាសំខាន់ ហើយនៅក្នុងនោះគឺបានស្រុកដែលមានដីជីវជាតិអន់ តែទទួលបានផលច្រើន។ សួរថា តើដែលគោលរបបនេះ ដល់ពេលដំណាក់កាលដែលបានផលច្រើនអ៊ីចឹង តើការបែងចែកទៅសហករណ៍ក្នុងការហូបចុកដូចជា អង្ករជាអីប្រចាំថ្ងៃ ជីវភាពប្រចាំថ្ងៃនោះ តើដូចៗគ្នាទេ គ្រប់ឃុំទាំងអស់ ដែលចំណុះឲ្យស្រុកត្រាំកក់?

[១៣:៣៨:៤៤]

**ឆៈ** សូមបញ្ជាក់ជូន គឺរបបកាលនោះគឺកំណត់ដូចគ្នាទាំងអស់។ ដូចឃុំ(ក) មានរបបប៉ុណ្ណឹង ហើយ ឲ្យពិនិត្យស្រូវមានប៉ុនណា បើខ្វះ ចាំថែមឲ្យ។ ឃុំ(ខ) ក៏អ៊ីចឹងដែរ ពិនិត្យស្រូវទៅរបបប៉ុណ្ណឹង បានប៉ុន្មាន ខ្វះថែមឲ្យ។ គ្រប់ទាំងអស់ទាំងគ្រប់ឃុំ ធ្វើអ៊ីចឹង។ ហើយបើពិនិត្យទៅ គ្នាខ្វះត្រូវតែថែមឲ្យ អ៊ីចឹង។ ហើអាហ្នឹងយកពីឃុំ មិនមែនស្រុកមានស្រូវឯណាផ្សេងទេ មានតែយកពីឃុំដែលលើសទៅឲ្យ ឃុំដែលខ្វះ។ ហើយត្រៀមជូនទៅកន្លែងផ្សេងដែលអត់ដែរ ដាច់ពេលមកដែរហ្នឹង ទៅយកឃុំ ស្រូវ ដែលកន្លែងលើស យើងដឹងជាចំនួនហើយ ឃុំនេះលើសប៉ុន្មានតោន ឃុំនេះលើសប៉ុន្មានតោន យើងដក ស្រូវហ្នឹងទៅជូនកន្លែងផ្សេងទៀត។

**សៈ** បាទ អរគុណ។ ហើយការដែលលោកបានលើកឡើងថា របបហូបហ្នឹងគឺស្មើភាពគ្នាទាំង នៅក្នុងទូទាំងស្រុកត្រាំកក់។ សំណួរសួរថាតើបុគ្គលណា ឬក៏ស្ថាប័នណាដែលមានភារកិច្ចក្នុងការ កំណត់គោលរបបឲ្យការទទួលហូបចុកហ្នឹងដូចៗគ្នានៅគ្រប់ឃុំទាំងអស់ ឬក៏គ្រប់សហករណ៍ចំណុះឲ្យ ស្រុកត្រាំកក់? បុគ្គលណា ឬក៏ស្ថាប័នណាដែលជាអ្នកកំណត់របប គោលរបប?

[១៣:៤០:២៥]

**ឆៈ** កាលនោះពិគ្រោះគ្នាក្នុងគណៈកម្មការស្រុក ហើយស្នើយោបល់តំបន់ថា យើងឲ្យហូបស្មើ ប្រហែលៗគ្នាទៅ បើមិនជួយអ៊ីចឹងឃុំដទៃខ្វះ អត់ហើយៗគាត់ព្រម ក៏ពិគ្រោះគ្នាក្នុងគណៈកម្មការស្រុក យោងតាមការណែនាំរបស់តំបន់ ក៏ធ្វើអ៊ីចឹង។

**សៈ** បាទ អរគុណ។ ហើយសំណួរ -- ចម្លើយដែលលោកឆ្លើយនឹងសំណួររបស់សហមេធាវីនាំ មុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីព្រឹកមិញ ថានៅទូទាំងស្រុកត្រាំកក់ហ្នឹងមានដីបង្កបង្កើនផលចំនួន

២៥០០០ហិកតា ហើយក្នុងមួយហិកតាបាន៣តោន ហើយមួយឆ្នាំអាចធ្វើតាមពីរដងនៅតំបន់ខ្លះ។ ខ្ញុំយល់អ៊ីចឹងត្រឹមត្រូវទេ លោកបានឆ្លើយតបទៅមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីកាលពីព្រឹកមិញ?

**ឆ៖** បាទ ត្រឹមត្រូវហើយ។

[១៣:៤១:៤២]

**ស៖** សំណួរបន្តគឺថាអ៊ីចេះ តាមដែលលោកឆ្លើយតបអំពីគោលរបបនេះ គឺកាលពីដំបូងដើមរដូវច្រូតកាត់ គឺរបបហូបបាយ ដល់ពេលបន្ទាប់មកគឺអាចបាយលាយដំឡូង ហើយបន្ទាប់មកគឺបបរ ដែលលោកប្រើថាបបរខាប់គួរសមដែរ។ ប៉ុន្តែសាក្សីមួយចំនួនបានឆ្លើយថា បញ្ជាក់ថាបបរនោះគឺរាវៗទេ ហើយហូបមិនគ្រប់គ្រាន់ទេ។ សំណួរសួរថាក្នុងដី២៥០០០ហិកតា ហើយមួយហិកតាបាន៣តោនយ៉ាងតិច ពីព្រោះបើសិនជាធ្វើពីរដង វាអាចដល់៦តោន ហើយជាប់ជាស្រុកគំរូទៀត ស្រុកទទួលទង់កិត្តិយសទៀត។ សំណួរថាហេតុអ្វីបានជានៅក្នុងរដូវនៃការហូបចុកមានការវិវត្តន៍ប្រែប្រួលពីរបបពេលខ្លះហូបបាយ ពេលខ្លះហូបបាយលាយដំឡូង ហើយពេលខ្លះហ្នឹង គឺហូបបបរ មានហេតុផលយ៉ាងម៉េចទៅ?

**ឆ៖** សូមបញ្ជាក់ជូន លទ្ធផលនេះគឺគិតឆ្នាំ៧៦ លទ្ធផលដែលជូនខាងលើ។ ឯពីមុនវាមានខ្វះមានលើសមានខ្វះមែន នេះ -- ឯដល់៧៦ គឺគិតតាមរបបហ្នឹង។ អស់ហើយមានអី។

**ស៖** អ៊ីចឹងបានន័យថាឆ្នាំ៧៦ហ្នឹង ប្រជាពលរដ្ឋនៅក្នុងស្រុក ទូទាំងស្រុកត្រាំកក់ហ្នឹងគឺបានទទួលគោលរបបក្នុងការហូបបាយពេញមួយឆ្នាំទល់មួយឆ្នាំ ឬក៏យ៉ាងម៉េច?

**ឆ៖** ៧៦, ៧៧ មកមុខមកហូបពេញហើយបាយ។ ទោះក៏វាកន្លែងណាខ្វះ ក៏ដកថែមថយភ្លាមទាន់ៗ ពីឃុំណាអត់ទៅ ក៏ទាញពីឃុំគ្រប់បង្គ្រប់ៗ អាចមានមួយពេល ពីរពេលអីលៃមិនទាន់ហ្នឹងអាចមាន ប៉ុន្តែជាទូទៅគឺហូបបាយឆ្អែត។

[១៣:៤៤:១៦]

**ស៖** ហើយបើតាមដែលបទពិសោធន៍របស់លោកដែលលោកធ្លាប់ធ្វើជាគណៈកម្មាធិការស្រុកមួយរយៈពេលទាំងជាសមាជិក ទាំងជាលេខាស្តីទី តើនៅក្នុងស្រុកត្រាំកក់ក្នុងមួយរដូវ ឬក៏មួយឆ្នាំហ្នឹងមានសល់ ភោគផលស្រូវសម្រាប់បញ្ជូនមកឲ្យមជ្ឈិមដែរឬទេ?

**ឆ៖** កាលនោះមាន។ ប៉ុន្តែខ្ញុំអត់ចាំចំនួនទេ មជ្ឈិមខ្វះ សុំឲ្យជាស្រូវ ប៉ុន្តែភាគច្រើនឲ្យជាអង្ករកិនអង្ករឲ្យ។ ឲ្យទាំងមជ្ឈិម ឲ្យទាំងពួកតំបន់ផ្សេងៗទៀត ដែលអត់រត់ទៅរក ដល់ផ្ញើរម៉ានឲ្យផ្ញើរហ្នឹង

តិចច្រើនឲ្យអីឲ្យ។ វ៉ាល់ឡានតែម្តង មួយឡានពីរឡាន ដំឡូងមួយឡានពីរឡាន ទាំងស្រូវពូជ ទាំងស្រូវហូប ឲ្យបងប្អូនយកទៅហូប ចែកបានប៉ុន្មាន តិចប៉ុណ្ណឹង បានចេះតែជូនទៅ។

**ស៖** បានជាយើងសួរបញ្ជាក់លើចំណុចនេះ ព្រោះសាក្សី ក៏ដូចជាដើមបណ្តឹងរដ្ឋប្បវេណីជាច្រើនបានអះអាងថាការហូបចុកមិនគ្រប់គ្រាន់ទេ។ អ៊ីចឹងហើយបានជាមានការលួចៗ ទាំងកុមារ ទាំងមនុស្សចាស់ហ្នឹង លួចអ៊ីចឹង ហើយមានការចាប់យកទៅធ្វើទារុណកម្ម ដាក់ពិន័យអីផ្សេងៗ។ នេះបានជាយើងចង់សួរបញ្ជាក់ពីបញ្ហានេះឲ្យច្បាស់លាស់លើគោលរបបហូបនេះ។ តើលោកមានមូលដ្ឋានអីទេដែលអះអាងថាការហូបចុកហ្នឹង គឺគេហូបបាយតាំងពី៧៦, ៧៧ ហើយជាហូរហែក្រោយមក ហូបបាយពេញមួយឆ្នាំៗទល់មួយឆ្នាំតែម្តងនោះ នៃសហករណ៍ទាំងឡាយនៅក្នុងស្រុកត្រាំកក់?

[១៣:៤៦:២៦]

**ឆ៖** ខ្ញុំនិយាយនេះ មិនមែនថាបាយរឹងនេះទេ បាយបបរគោក ប្រៀបធៀប ហូបឆ្អែតហើយ ពីមុនមានការខ្វះខ្លះ មានឈឺមានអី គេខ្លះមែន ប៉ុន្តែដល់ចូល៧៧ – ៧៦ ប្រមូលផល ដល់៧៧ ហូបស្រូវថ្មីហ្នឹង។ បានច្រើនៗមិនប៉ានហូបទាំងអស់ច្រើនទេ ព្រោះកន្លែងផ្សេងវាអត់ដែរ។ អ៊ីចឹង ជូនហូបតាមសមរម្យៗ ហើយមួយខែធ្វើហូបពិសេសម្តងៗ ហៅថា “មីទ្និងមហាហូប”។ ហើយសហករណ៍ទាំងអស់ធ្វើនំ ហើយមកមូលគ្នាមួយកន្លែង រែកនំមក ដូចបុណ្យកឋិនអ៊ីចឹង។ នំអីក៏មានដែរ នំបញ្ចុក បាយសម្ល ម្ហូបអីគ្រប់មុខ។ សហករណ៍ធ្វើមក ជូនហូបទាំងអស់ ហើយដែលឃ្លានជាងគេ បងប្អូនមកថ្មី មានម្នាក់គាត់ហូបដល់សន្លប់ ខ្ញុំភ័យហើយ ដួលស្តូកតាមផ្លូវ វិលមកកន្លែងវិញ។ ដល់ទៅមើលទៅ បានជួយលើកដាក់ថែ កោសខ្យល់កោសអី ធ្វើសរសៃឲ្យទៅ ដឹងខ្លួនវិញ។

**ស៖** បាទ អរគុណ ហើយជាបន្តទៅនេះ យើងនៅមានពីរសំណួរទៀតប៉ុណ្ណោះ ដែលពាក់ព័ន្ធជាមួយនឹងឯកសារ ទី១ គឺE3/401 ហើយនិងឯកសារទី២ គឺE319.1.18 ហើយកន្លែងដែលយើងខ្ញុំមានបំណងសួរលោក គឺមានដាក់ហាយឡាយ ហើយនិងដាក់ក្រដាសពណ៌នេះហើយ។

មន្ត្រីរដ្ឋបាលតុលាការយកឯកសារជាក្រដាសនេះ ទៅជូនសាក្សីពិនិត្យ!

យើងចាប់ផ្តើមសួរនូវឯកសារទី១មុន គឺE3/401។ បាទ ត្រង់ គឺជាឯកសារកិច្ចសម្ភាសន៍របស់សាក្សីគឺរបស់លោក នៅត្រង់ភាសាខ្មែរដែលមានលេខ ERN 00373478 និងភាសាអង់គ្លេសដែលមានលេខ ERN0038128។ ខ្ញុំអត់មានភាសាបារាំងទេ។ លោកៗ ពេជ្រ ជឹម សូមលោករកមើលមើល៍។ មានដាក់ហាយឡាយរួចហើយ ដាក់ហាយឡាយ និងដាក់ក្រដាសលឿងហ្នឹង។ បិតក្រដាសលឿងហើយ

នៅទំព័រក្រោយខាងគេបង្អស់។ លោកត្រូវបានកត់ត្រានូវចម្លើយ ដែលបានលោកបាននិយាយថា តាម៉ុក ក៏ធ្លាប់មានការណែនាំនៅក្នុងអង្គប្រជុំផងដែរ កុំឲ្យមានការសម្លាប់ផ្តេសផ្តាស។ លោកមើល តើលោក អាចមើលឃើញចម្លើយរបស់លោក ហើយឬនៅ?

**ឆ៖** ឃើញៗហើយ។

[១៣:៥០:៤១]

**ស៖** បាទ អរគុណ។ ពាក់ព័ន្ធនឹងប្រធានបទនេះ យើងសួរលោកពីរបីសំណួរ។ តើ តាម៉ុក បាន ចេញការណែនាំនេះនៅពេលណាលោកចាំដែរទេ?

**ឆ៖** អត់ចាំ។

**ស៖** នៅក្នុងអំឡុងពេលលោកធ្វើជាសមាជិកគណៈកម្មាធិការស្រុកត្រាំកក់ ឬក៏នៅក្នុងអំឡុង ពេលដែលលោកធ្វើជាលេខាស្តីទីស្រុកត្រាំកក់?

**ឆ៖** គាត់និយាយនេះមិនចាំឆ្នាំទៀត កាលទៅនិយាយៗ ហ្នឹងតាំងពីខ្ញុំនៅធ្វើសមាជិកស្រុក នោះ។ កូនគាត់ធ្វើលេខា ជូនគាត់ស្រែកប្រាប់កូនគាត់ទៅ របៀបរបបគាត់ជួបគ្នាថា "មកៗមូលគ្នា" សូមបញ្ជាក់ជូន។ "មកៗមកទាំងអស់គ្នាមក អ្នកចេះ មួយធ្វើនេះ ពីរធ្វើនោះ បីកុំសម្លាប់គេ" ហើយៗ ប៉ុណ្ណឹងទៅបាត់ទៅ។

**ស៖** បាទ អរគុណ។ ហើយតើលោកដឹងទេ ថាហេតុការណ៍ -- តើមានហេតុការណ៍អ្វីខ្លះបាន កើតឡើងនៅស្រុកត្រាំកក់ ទើបមានសេចក្តីណែនាំពី តាម៉ុក ដូច្នេះ?

**ឆ៖** ដូចខ្ញុំជូនឧទាហរណ៍ ក្រោយ ៧០ភ្លាម ៧២គឺ អ្នកណាចូលមកខ្លាំង បាត់ខ្លួន ហើយចេញ មកវិញក៏បាត់ កងទ័ព កងឈ្លប កាលនោះរើសចូលភ្លាមធ្វើភ្លាម មានមេមួយកុំអីហ្នឹងរើសថ្មី។ ខំទៅ មានមេម្នាក់ក្តាប់រួមក្នុងស្រុកក្នុងខេត្តហ្នឹង ដល់មេបន្ទាប់ៗក្រោម មិនដឹងមិនយល់អីប៉ុន្មាន។

**ស៖** យើងមិនចង់ដឹងពីហេតុការណ៍មុនឆ្នាំ -- ១៧ មេសា ៧៥ ទេ។ តើហេតុការណ៍ក្រោយ ១៧ មេសា ៧៥ កើតមានហេតុការណ៍នេះដែរឬទេ?

**ឆ៖** ក្រោយ ៧៥ គាត់ពីដើមមក គាត់ថាអ៊ីចឹងទៀត មានប្រជុំអ៊ីចឹងទៀត។ អាហ្នឹងជាការ ណែនាំ។

[១៣:៥៣:៥៦]

**ស៖** ចុះក្រោយ៧៥ ហ្នឹងលោកសង្កេតឃើញថា មានការ ហេតុការណ៍អ្វីកើតឡើងទេ ទើប

មានការណែនាំពីសំណាក់ តាម៉ុក ដូច្នេះ?

**ឆ៖** តាមអង្កេត ពិនិត្យទៅមាន។ មានហេតុការណ៍កើតឡើងប៉ះអាយុជីវិត បានហាមអ៊ីចឹងទៅ។ ជាទាហាន ហ្នឹងទាហានដូចគ្នា សូមបញ្ជាក់ខ្លីៗ។ ទាហាន ហ្នឹងទាហានដូចគ្នា មួយទាហាននៅទល់ មួយទាហានកងផ្សេង។ ហើយពីក្មេងមកមនុស្សស្គាល់គ្នា ខ្លះជីដូនមួយគ្នា មកដល់ចាប់យកបាត់ទៅ ហើយខ្ញុំទៅទប់ទល់ឯណាកាំភ្លើង គេកងទ័ពរៀបរយ។ ដល់ តាម៉ុក មកដឹងរឿងហ្នឹងក៏ប្រកាសអ៊ីចឹង។ ហើយកូនក្មួយតាម៉ុក ហ្នឹងមិនឆ្ងាយទៀត។

**ស៖** ហើយមានន័យថាម៉េចទៅការសម្លាប់មនុស្សផ្តេសផ្តាសហ្នឹង មានអត្ថន័យខ្លឹមសារវាយ៉ាងម៉េច ពាក្យថា "ការសម្លាប់ផ្តេសផ្តាសនេះ"?

[១៣:៥៥:៣៣]

**ឆ៖** តាមមើលគំនុំគ្នា អានោះមកពីសមរភូមិចាប់នេះបាត់ទៅ យកទៅបាត់ ស្រុកក៏អត់ប៉ាន អន្តរាគមន៍ ហើយខាង ញៀវ ខាងឃុំនេះក៏អត់មាត់ អត់ប៉ាន។ ខ្ញុំកាន់តែអត់ទៀតហើយ។

**ស៖** បាទ អរគុណ ហើយយើងមានពេលតិចតួច អ៊ីចឹងយើងចូលទៅឯកសារមួយទៀត គឺឯកសារ E319.1.18 គឺកិច្ចសម្ភាសន៍របស់លោកត្រង់ភាសាខ្មែរដែលមាន ERN00997048 និងភាសាអង់គ្លេសដែលមានលេខ ERN 01000689 a188 ត្រូវបានកត់ចម្លើយរបស់លោកថាលោកធ្លាប់បានទទួលលិខិតណែនាំពីភ្នំពេញ ប៉ុល ពត ក្នុងខែ សីហា ឆ្នាំ១៩៧៨ ឲ្យបញ្ឈប់ការសម្លាប់មនុស្សបន្តទៀត ហើយលិខិតចេញទៅគ្រប់ភូមិភាគទាំងអស់ ជាលិខិតដែលចេញជាលក្ខណៈទូទៅ។ លោកៗ ពិនិត្យឃើញហើយឬនៅចំណុចនេះ?

**ឆ៖** បានឃើញហើយ។

**ស៖** អរគុណនេះជាសេចក្តីដកស្រង់ត្រឹមត្រូវទេ ពីចម្លើយដែលលោកឆ្លើយតបទៅនឹងអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេតកន្លងមក?

**ឆ៖** សេចក្តីនេះគឺត្រឹមត្រូវហើយ។

[១៣:៥៧:៥៥]

**ស៖** បាទ អ៊ីចឹងសំណួរចុងក្រោយរបស់យើងគឺថា តើលោកបានទទួលបញ្ជានេះ នោះដោយរបៀបណា? ហើយនៅពេលណា? នៅទីកន្លែងណា?

**ឆ៖** បញ្ជានេះ ខ្ញុំទទួលពីលោក ប៉ុល ពត -- នៃ ពក – កែ ពក នៅភូមិភាគកណ្តាល។

**ស៖** ហើយនៅពេលណាដែរ លោក ពេជ្រ ជឹម? លោក ពេជ្រ ជឹម ឆ្លើយតើនៅពេលណាដែរ?

**ឆ៖** ទទួលក្នុងខែ៨ ឆ្នាំ៧៨។ អត់ចាំថ្ងៃទេ។

**ប្រធានអង្គជំនុំ៖**

បាទ ហើយសូមអរគុណលោកសាក្សី ហើយយើងមិនមានសំណួរអីបន្ថែមទៀតទេ។ ហើយជាបន្តទៅនេះ អង្គជំនុំជម្រះផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តី ដែលដំបូងនេះប្រគល់ជូនទៅលោកមេធាវីការពារក្តីលោក នួន ជា ដើម្បីមានឱកាសតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះ។

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។ សូមគោរពលោក លោកស្រីចៅក្រម។

**ការតាំងសំណួរដោយសហមេធាវីការពារក្តី**

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** ជម្រាបសួរលោក ពេជ្រ ជឹម ខ្ញុំឈ្មោះ វ៉ិចទ័រ កូប៉េ ជាមេធាវីអន្តរជាតិការពារ<ក្តី> លោក នួន ជា ហើយខ្ញុំមានសំណួរមួយចំនួន សួរទៅកាន់លោក។ ខ្ញុំសូមចាប់ផ្តើមសួរបន្តទៅនឹងសំណួរដែលលោកប្រធានទើបតែសួរលោកអម្បាញ់មិញ គឺសំណួរពាក់ព័ន្ធទៅនឹងស្ថានភាពចំណីអាហារ ម្ហូបអាហារ<នៅស្រុកត្រាំកក់>។ តើលោកដឹងទេ ថាមានគោលនយោបាយណាមួយ ឬក៏ការអនុវត្តគោលនយោបាយណាមួយនៅក្នុងឃុំ ដែលថាអាចមានលក្ខណៈខុសគ្នាដែរឬទេ ទាក់ទងទៅនឹងរបបអាហារសម្រាប់ប្រជាជនមូលដ្ឋាន និងសម្រាប់ប្រជាជនថ្មី <គឺប្រជាជន១៧ មេសា>?

[១៤:០១:០៤]

**លោក ពេជ្រ ជឹម៖**

**ឆ៖** បញ្ហារបបហ្នឹង គឺកំណត់រៀបរយដូចៗគ្នា។ ស្រុកសម្រេចឲ្យឃុំ ឃុំរៀបរយ ចែកបីនាក់មួយកំប៉ុងៗទាំងអស់ ដោយគិតជាចំនួន។ នេះជាគោលការណ៍ធ្វើអ៊ីចឹង។ ប៉ុន្តែដល់ហូបទៅ ចេះតែឮខ្លះឮមិនឆ្អែត ទប់ទល់នឹងការមិនឆ្អែតណាស់ ធ្វើ -- តំបន់ជួយ គាត់ថា ធ្វើមហាហូប ឲ្យហូបម្តងទៅ មួយខែពីរធ្វើម្តងៗ ដូចនេះ ហើយពិនិត្យនៅឃុំ ខ្ញុំចុះផ្ទាល់មើលទៅ មានលាក់ ហូប ឧបមា សហករណ៍ៗគេហូបពីរនាក់ទៅ ហើយប្រជាជនរំដោះថ្មីបីនាក់ទៅ អាចមានអ៊ីចឹង ពិនិត្យទៅ ឃើញមានអ៊ីចឹង។ ប៉ុន្តែទៅវ៉ៃ ទៅដំ ទៅម៉េចទៀត ចេះតែល្បងលោម ចេះតែខិតខំ មើល៍ ឈាមយើង ជាតិយើងតែមួយ មិនមានការណែនាំទេកាលណោះ។ ប៉ុន្តែកន្លែងណាដែលយើងមិនដឹង អាហ្នឹងជាការមិនដឹងហើយ វាចុះមិនសព្វ

ប៉ុន្តែជាក់ស្តែងគឺមានអ៊ីចឹង។ មានអាហារ ថ្នាក់មូលដ្ឋាន ហូបពីរកំប៉ុង ម្នាក់ពីរកំប៉ុង មិនមែនពីរកំប៉ុងម្នាក់ទេ ម្នាក់ពីរកំប៉ុង -- ពីរនាក់មួយកំប៉ុង ហើយនេះដល់បីនាក់មួយកំប៉ុង។ ហើយបើដាំបាយវាដាំបានហើយ ឯនោះដល់តែបបរ។ អាចមានអ៊ីចឹង ខ្ញុំត្រង់ហើយ ជម្រាបត្រង់ ខ្ញុំចុះពិនិត្យមើលឃើញអ៊ីចឹង កែលម្អដោយអប់រំនយោបាយណែនាំផ្ទាល់ៗ។

[១៤:០៣:៣០]

**ស៖** អ្វីដែលលោកកំពុងតែរៀបរាប់នេះ វាជាហេតុការណ៍ដែលកើតក្នុងពេលខ្លះ ឬក៏យ៉ាងណាតើវាជាគោលការណ៍<>ប្រឆាំងទៅនឹងគោល<នយោបាយ>ដែរឬទេ? <គឺ>គោល<នយោបាយដែល>ថា ម្នាក់ៗត្រូវមានរបបអាហារស្មើៗគ្នានោះ?

**ឆ៖** វាប្រឆាំង វាមិនដូច ខំប្រឹងឲ្យដូច វាមិនដូច។

**ស៖** លោករស់នៅក្នុងស្រុកត្រាំកក់<ខេត្តតាកែវ> ខ្ញុំគិតថាតាំងពីឆ្នាំ១៩៧០មកម្ល៉េះ <គឺ>មុនពេលលោកចូលរួមជាមួយបដិវត្តន៍ទៅទៀត។ តើលោកអាចធ្វើការប្រៀបធៀបរវាងស្ថានភាពចំណីអាហារសម្រាប់ប្រជាជន មុនការបង្កើតសហករណ៍ និងក្រោយការបង្កើតសហករណ៍<?> មានន័យថាតើស្ថានភាពរបបអាហារនេះ វាមានភាពប្រសើរឡើង ឬក៏អត់ទេមុនបង្កើតសហករណ៍ និងក្រោយបង្កើតសហករណ៍?

**ឆ៖** អាហារដែលមុនរៀបចំសហករណ៍ និយាយរួមបាយឯកជន មានទាន់ខ្វះទេ ដល់រៀបរួមខ្វះ ចោទ ដោះស្រាយគ្នា ជជែកគ្នា ប៉ុន្តែជជែកទៅចេញត្រឹមហ្នឹង នៅតែរៀបចំ នៅតែធ្វើដំណើរការអ៊ីចឹងទៅ។ សូមអស់។

**ស៖** តើលោកធ្វើការកត់សម្គាល់ពេលណាមួយបានទេ រវាង<>ឆ្នាំ១៩៧៥<និងឆ្នាំ១៩៧៩>។ ថាតើស្ថានភាពចំណីអាហារហ្នឹងត្រូវបានដោះស្រាយឲ្យប្រជាជនហូបបានគ្រប់គ្រាន់ដែរ ឬក៏អត់ទេ?

[១៤:០៦:២៣]

**ឆ៖** មុន១៩៧៥ គឺដោះស្រាយតាមគ្រួសារ ពិនិត្យស្រូវសល់ យើងមានយករបស់គេទៅណាពិនិត្យទៅ ហូបសល់។ ប៉ុន្តែដល់រួមស្រូវហ្នឹង ស្រូវហ្នឹងវាមិនបាត់ ប៉ុន្តែវាមានកន្លែងខ្វះ ដែលខ្ញុំតានដានទៅអ៊ីចឹង វាមានកន្លែងខ្វះ ហើយមានកន្លែងគ្រាន់ និងកន្លែងលើស។ បើបូកមកវាខ្វះដដែល វាទៅជាខ្វះវិញ។ ដើម្បីខ្វះហ្នឹង មានតែខំរក ខំធ្វើ ហើយហូបស្រាលតិចទៅរយៈកាលបីខែ។ បីខែហ្នឹងឆ្លងកាត់បីទៅប្រាំមួយខែ ស្រូវទុំហើយ។ ហ្នឹងជម្រាបត្រង់ប៉ុណ្ណឹង ហើយអស់ហើយ។

**ស៖** <មកដល់>ឆ្នាំ១៩៧៥, ១៩៧៦ ហើយ <បើសិនជាមាន>អ្នកណាម្នាក់ត្រូវបានចាប់ខ្លួនដោយសារតែលួចរបស់របរចំណីអាហារ<ឧទាហរណ៍ដំឡូងមី ឬផ្លែឈើផ្សេងទៀត> ដែលជារបស់សម្ភូហភាព។ <តើគេធ្វើអីអ្នកនោះដែរ?> តើ<>ចាត់ទុក<បញ្ហានេះ>ថាជា<>ទោសស្រាល ឬក៏<>ទោសធ្ងន់?

**ឆ៖** អ្នកនោះជាអ្នកប្រព្រឹត្តទោសស្រាលទេ។

**ស៖** ហើយចុះប្រសិនណាជាអ្នកណាប្រព្រឹត្តទោសស្រាលអ៊ីចឹង តើមានអ្វីកើតឡើងដល់អ្នកទាំងនេះ?

**ឆ៖** ប្រភេទអ៊ីចឹង អប់រំ ណែនាំ រៀនសូត្រហ្នឹង និយាយប្រាប់ ពន្យល់ មានទៅរៀន មានឯកសារឯណា សាលាឯណាទេ សាលាក្រោមដើមឈើ ដើរទៅហៅវាមកឲ្យជួបផ្ទាល់ ឬមានពេលក៏ដើរទៅឈោងចូលជួបនិយាយណែនាំទៅ "កុំភ័យអី ន៎ែ ការខុសហ្នឹងវាអត់ល្អ កែលម្អទៅ។ ក្រោយលែងខុសទៀតទៅ រួចខ្លួនហើយ វាលែងអីហើយ" ប្រាប់ត្រង់អ៊ីចឹង ឆាប់បាន ខ្ញុំជម្រាបអ៊ីចឹង។ បើថាសំឡុតហើយ បោលបាត់ហើយ។ សូមអស់។

[១៤:០៩:៣៥]

**ស៖** តើលោកអាចជម្រាបជូនអង្គជំនុំជម្រះថា ក្រោយពីការលួចអ្វីមួយ<ប៉ុន្មាន>ដង<ដែរទើបត្រូវបាន>គេចាប់<>បញ្ជូនទៅកន្លែងអប់រំហ្នឹង<?> តើលួចប៉ុន្មានដងទើបគេបញ្ជូនទៅមន្ទីរអប់រំកែប្រែ?

**ឆ៖** តាមខ្ញុំចាំ មិនដែលមានយកពួកហ្នឹងទៅមន្ទីរអប់រំកែប្រែទេ អប់រំនៅកន្លែងនៅឃុំភូមិហ្នឹងអត់ដែលបញ្ជូនចេញទៅក្រៅទេ រឿងលួចហ្នឹង។

**ស៖** លោកមានដឹងហេតុការណ៍ណាមួយដែលអ្នកណាម្នាក់ត្រូវបានគេសម្លាប់ចោលដោយសារតែលួចរបស់របរកំប៉ិកកំប៉ុក <ដូចជា>លួច<ដំឡូងមី ឬផ្លែឈើ>អ៊ីចឹងទេ?

**ឆ៖** ខ្ញុំអត់មានបានទេ អត់បានជួបសភាពការណ៍អ៊ីចឹងទេ ដល់លួចហើយសម្លាប់ហ្នឹងអត់មានទេ។

**ស៖** ទាក់ទងទៅនឹងការប្រៀបធៀបបែបហ្នឹងតើមានរឿងបែបនេះកើតឡើងនៅភូមិភាគកណ្តាល នៅចម្ការកៅស៊ូដោយសារតែលួចចំណីអាហារអ៊ីចឹង ហើយត្រូវគេសម្លាប់ចោលដែរទេ <ដោយគ្រាន់តែលួចប៉ុណ្ណឹង>?

**ឆ៖** មិនៗបានជួបប្រទះទេ។

[១៤:១១:៥៧]

**ស៖** តើលោកមានដឹងគោលនយោបាយដែលលោកទើបតែរៀបរាប់ពាក់ព័ន្ធៗទៅនឹងបទល្មើសស្រាល តើនៅក្នុងស្រុកដទៃទៀត<>នៅក្នុងតំបន់១៣ វាដូចគ្នាដែរឬក៏អត់ទេ បើប្រៀបធៀបទៅនឹងស្រុក ឬក៏តំបន់ដទៃទៀតនៅភូមិភាគនិរតី?

**ឆ៖** តាមមើលមិនដូចគ្នាទេ ព្រោះការដឹកនាំគ្រប់គ្រងគេសម្រួលដោះស្រាយ កុំឱ្យវាមានបញ្ហាច្រើន ដូចនេះគំនិតតាមតំបន់វាខុសគ្នាបន្តិចៗ វាមិនដូចគ្នាទាំងស្រុង ប៉ុន្តែតែត្រូវទាំងស្រុងថា ទោសលួចទោសស៊ីធីកតិចតួច អាហ្នឹងមិនមានដល់ទោសឧក្រិដ្ឋសម្លាប់ទេ ហ្នឹងគោលអ៊ីចឹង ប៉ុន្តែថាឱ្យវាដូចគ្នាមកទាំងអស់ក្រោមភូមិភាគ អត់ៗដូចទេ។

**ស៖** សំណួរចុងក្រោយរបស់ខ្ញុំទាក់ទងទៅនឹងចំណីអាហារ។ តើលោកអាចជម្រាបជូនអង្គជំនុំជម្រះ ថាតើគោលបំណងទទួលបានស្រូវ ៣តោនក្នុង១ហិកតា ជាទិសដៅពិតប្រាកដ ជាទិសដៅដែលអាចសម្រេចបានពិតប្រាកដដែរឬទេ?

**ឆ៖** កាលនោះ ការសម្រេចមិនមែនខ្ញុំទេ តំបន់ហ្នឹងតាម៉ុករួម អ្នកដែលចូលរួមទាំងអស់។ ខ្ញុំថា "ក្រែងមិនគ្រប់ បើពីរកន្លះប្រហែលបាន", "ទេបីទៅ កំណត់បីទៅ ដំឡូងទៀតជួយ វាបង្គ្រប់៣តោនចុះ"។ បញ្ចាក់ជូនប៉ុណ្ណឹង។

[១៤:១៤:៤៣]

**ស៖** ហើយតើវាមានផលវិបាកអ្វីដែរនៅក្នុងស្រុក?<>បើសិនណាជាមិនសម្រេចបានទិន្នផល ៣តោនក្នុង១ហិកតាទេ <តើជាផលវិបាកធ្ងន់ធ្ងរទេ>សម្រាប់អ្នកទទួលខុសត្រូវក្នុងស្រុកហ្នឹង?

**ឆ៖** អត់មានផលអីវិបាកដល់ស្រុក ដល់អ្នកទទួលខុសត្រូវទេ។ បើវាខ្វះតិចតួច ប៉ុនគេធ្វើវាល់ថ្ងៃ វាកើនពីរដងនោះថែមទៀត។ ដំឡូងក៏ដាំ ស្រូវក៏ធ្វើពីរដងថែមទៀត ចេះតែពង្រីកទៅ ធ្វើថែមទៀតទៅ ដូចនេះការខ្វះខាតបន្តិចបន្តួចនេះជាការឆ្លងកាត់ ព្រោះស្រូវតែបីខែវាទុំ។ ទៅបីទៅប្រាំខែ ទុំ។

**ស៖** អ៊ីចឹង វាត្រឹមត្រូវទេ បើសិនជាខ្ញុំនិយាយថា នៅក្នុងស្រុករបស់លោក ឬក៏ក្នុងស្រុកផ្សេងទៀត គឺថាប្រជាជនមិន<>ត្រូវបានគេបង្ខំឱ្យធ្វើការធ្ងន់ធ្ងរលំបាកលំបិន ដោយសារតែចង់បានទិន្នផល ៣តោនក្នុង១ហិកតានោះទេ។ អ៊ីចឹងត្រឹមត្រូវទេ?

**ឆ៖** មិនត្រឹមត្រូវទេ។

**ស៖** ប្រហែលជាមានបញ្ហានៃការបកប្រែ។ លោកយល់ស្របជាមួយខ្ញុំទេ? <តើអ៊ីចឹងត្រឹមត្រូវទេ?>

**ឆ៖** ខ្ញុំស្តាប់ខ្លឹមសារអត់បាន។

**ប្រធានអង្គជំនុំ៖**

លោកមេធាវី សូមលោកមេធាវីតាំងសំណួរអម្បាញ់មិញនេះសាជាថ្មីម្តងទៀត។ សាក្សីមិនយល់សំណួររបស់លោកទេ ក្តាប់សំណួររបស់លោកសួរមិនបាន បានគាត់មិនអាចឆ្លើយតបបាន។

[១៤:១៧:០២]

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** បាទ ដោយសារតែ<មានការលើកឡើង>អវិជ្ជមានដល់ទៅពីរដង។ តើលោក ពេជ្រ ជឹម លោកយល់ស្របជាមួយខ្ញុំទេ ថានៅក្នុងស្រុករបស់លោក គឺប្រជាជនមិនត្រូវបានគេបង្ខំឲ្យធ្វើការធ្ងន់ធ្ងរដើម្បីគោលបំណងសម្រេចបាន៣តោនក្នុង១ហិកតាទេ។ តើអ៊ីចឹង ឬក៏អត់ទេ?

**លោក ពេជ្រ ជឹម៖**

**ឆ៖** យល់ព្រម។

**ស៖** ឥឡូវនេះ ខ្ញុំសូមចូលទៅប្រធានបទមួយទៀត គឺនិយាយអំពីការអប់រំ<។ ខ្ញុំដឹង> ថាខ្លួនលោកផ្ទាល់ មុននឹងចូលទៅក្នុងព្រៃម៉ាគី<> គឺថាលោកធ្លាប់ធ្វើជាគ្រូបង្រៀននៅក្នុងខេត្តតាកែវ។ តើត្រឹមត្រូវ ឬក៏អត់ទេ?

**ឆ៖** ត្រឹមត្រូវ។

**ស៖** តើលោកអាចជម្រាបជូនអង្គជំនុំជម្រះបានទេ តើលោកធ្វើការជាគ្រូបង្រៀននោះរយៈពេលប៉ុន្មានឆ្នាំដែរ?

**ឆ៖** ៧៩ -- អ៎! ៥៩-៧០ រយៈហ្នឹង។ ១១ឆ្នាំ។

**ស៖** តើលោកអាចជម្រាបជូនអង្គជំនុំជម្រះអំពីគោលបំណងរបស់បក្សកុម្មុយនីស្តកម្ពុជា <និងកម្ពុជាប្រជាធិបតេយ្យ>ទាក់ទង<នឹងការអប់រំបានទេ? តើ>គោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា និងកម្ពុជាប្រជាធិបតេយ្យ ពាក់ព័ន្ធទៅនឹងការចង់សម្រេចបាននូវការអប់រំ<មានអ្វីខ្លះ?> សូមជម្រាបមើល៍ ថាតើគោលបំណងរបស់បក្សកុម្មុយនីស្តកម្ពុជាធ្វើអ្វីដែរ ពាក់ព័ន្ធទៅនឹងវិស័យអប់រំ?

[១៤:១៨:៤៩]

**ឆ៖** វែងណាស់។ សូមឆ្លើយថា ចង់បានរីកចម្រើន ប្រទេសជឿនលឿន ទៅជាប្រទេសជឿនលឿនលើសកលលោក។

**ស៖** ខ្ញុំសួរឲ្យជាក់ស្តែងតែម្តង តើវាជាគោលបំណងនៅក្នុងស្រុករបស់លោកឬ ក្រោយការរំដោះ គឺថាមានបំណងចង់បង្កើតសាលារៀន ឲ្យមានក្មេងទទួលបានការអប់រំតាំងពីសាលាបឋម<>អនុវិទ្យាល័យ?

**ឆ៖** មាន។ គោលបំណង គឺរៀបចំក្នុងស្រុកខ្លួន ហើយមិនតែស្រុករបស់ខ្លួនទេ រួមទាំងខេត្ត ហើយគំនិតចង់បាន រួមទូទាំងប្រទេស មានបឋមសិក្សា រហូតមកមធ្យមសិក្សា ឧត្តមសិក្សា ដើម្បីជាតិយើងរុងរឿង ចម្រើន ខ្លាំងពូកែ។ នេះសំណូមពរ ចង់បានអ៊ីចឹង។

**ស៖** តើលោកអាចធ្វើការប្រៀបធៀបថាប្រព័ន្ធអប់រំនៅក្នុងឆ្នាំ១៩៧៥, ៧៦, ៧៧ នៅក្នុងស្រុកត្រាំកក់ហើយនិងប្រៀបធៀបទៅនឹងប្រព័ន្ធអប់រំមុនសង្គ្រាមស៊ីវិល តើវាមានលក្ខណៈខុសគ្នាយ៉ាងម៉េច?

**ឆ៖** ប្រព័ន្ធអប់រំនៅស្រុកត្រាំកក់ ៧១, ៧២ រហូតដល់ ៧៥ ប្រៀបធៀបទៅពីមុន ពីមុនរីកចម្រើន សាលាពេញទាំងអស់ ប៉ុនក្រោយហ្នឹងអត់មានទទេ។ ប៉ុនក្នុងសង្គ្រាមធ្វើមិនកើត។ អ៊ីចឹងជ្រើសគ្រូម្នាក់ៗបង្រៀនតែក្មេងតូចៗហ្នឹង ថ្នាក់ដំបូងគ្រប់ភូមិមាន មានប៉ុណ្ណឹងចុះ កុំឲ្យវាអត់។ ចាំថ្ងៃក្រោយរៀបទៅទៀត ឈរលើសភាពការណ៍ និងពេលវេលា។

[១៤:២១:៥០]

**ស៖** ហើយក្រោយថ្ងៃ១៧ មេសា ១៩៧៥ តើស្រុក១០៥ មានធ្វើអ្វីដែរទាក់ទងទៅនឹងដូចជាការកសាងសាលារៀនអីជាដើម។ មានធ្វើអ៊ីចឹងដែរទេ?

**ឆ៖** មានសង់ជារោងតូចៗ មិនបានជាសាលាធំដុំទេ រោងល្មមហ្នឹងដាក់តុ ល្មមៗរៀនបាន។ តាមភូមិ ភូមិខ្លះក៏មាន ខ្លះក៏អត់។ អាអត់ហ្នឹងទៅរៀនជិតគ្នាហ្នឹងទៅ ហ្នឹងមាន។

**ស៖** តើការសាងសង់សាលារៀនហ្នឹង វាជាអាទិភាព ឬក៏អត់ទេនៅក្នុងស្រុករបស់លោក?

**ឆ៖** មិនយល់ពី "អាទិភាព"ហ្នឹង។ សង់សាលារៀនជាអាទិភាព មិនយល់ពាក្យហ្នឹង?

**ស៖** តើ<>វាជាមហិច្ឆតា ឬក៏ថាវាជាបំណងចម្បងជាងគេ ឬក៏អត់នៅក្នុងស្រុករបស់លោក<ដើម្បី>សាងសង់សាលារៀន<ឲ្យបានច្រើន>?

**ឆ៖** មិនមែនមហិច្ឆតាទេ វាជាអាទិភាព។ វាជាបំណងល្អរបស់យុវជន របស់ពុកម៉ែ បងប្អូនទាំងអស់ ហើយជារបស់ជាតិទៀត។ វាមានពន្លឺជាតិដើរទៅរួច អត់សាលាហ្នឹងជាតិដើរងងឹត។

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

[១៤:២៣:៤៥]

**ស៖** សូមអរគុណលោក ពេជ្រ ជឹម។ ខ្ញុំចូលទៅប្រធានបទមួយផ្សេងទៀត ទាក់ទងទៅនឹងបញ្ហាសុខាភិបាល។ តើនៅក្នុងស្រុករបស់លោកមានគោលនយោបាយបែបណាដែរ ពាក់ព័ន្ធទៅនឹងការទទួលបានថ្នាំសង្កូវ ការមានលទ្ធភាពចូលសម្រាកនៅមន្ទីរពេទ្យ<?> តើវាមានលក្ខណៈខុសគ្នា ឬក៏អត់រវាងប្រជាជនមូលដ្ឋាន និងប្រជាជនថ្មីនៅពេលដែលគេទទួលអ្នកទាំងនោះទៅឲ្យសម្រាកនៅមន្ទីរពេទ្យ <ឬទទួលបានថ្នាំសង្កូវ> តើវាមានលក្ខណៈខុសគ្នាទេ?

**ឆ៖** តាមទស្សនៈគឺថា ដូចគ្នាថែងដូចគ្នា បានដូចគ្នា។ ប៉ុនការវិភាគថា ទោះយ៉ាងម៉េចក៏មិនដូចដែរ ទោះម៉េចក៏មិនដូចសុទ្ធដែរ ខុសខ្លះ។ ខ្ញុំសូមជម្រាបប៉ុណ្ណឹង។ របស់តិច ថ្នាំពេទ្យក្រណាស់សូមជម្រាប អត់ធ្វើចេះធ្វើកើត នេះនោះឲ្យមក យកជំនួយបរទេសអត់យក។ សុំជំនួយបរទេសអត់ឃើមួយទេ យកអង្ករបរទេសទៀត មហាលោតផ្លោះ មិនមែនមហាធ្លាក់គ្រហុក លោតណ៎ា មហាធ្លាក់ជ្រោះ។ ខ្ញុំសូមជម្រាបអ៊ីចឹង។

**ស៖** ខ្ញុំនឹងសួរបន្ថែមទៅលើចំណុចនេះ តែសំណួរដំបូងរបស់ខ្ញុំ ប្រសិនណាបើប្រជាជនថ្មីណាម្នាក់ធ្លាក់ខ្លួនឈឺ<ធ្ងន់> តើគេឲ្យសម្រាកនៅមន្ទីរពេទ្យដែរឬក៏អត់ទេ? តើការទទួលអ្នកជំងឺទៅឲ្យសម្រាកមន្ទីរពេទ្យគេមានញែកពីគ្នារវាងប្រជាជនថ្មី និងប្រជាជនចាស់< តើមែន>ដែរទេ?

[១៤:២៦:២៧]

**ឆ៖** មិនមានទេ មានគេអន់ៗប្រហែលតែគ្នាហ្នឹងដេក។ តាមចុះមើលអីអត់ទេ ដូចគ្នាទាំងអស់អ្នកថ្មីសួរសុខទុក្ខមីងពូ ប៉ុនថ្នាំក្រណាស់ ណែនាំឲ្យបាយ ឲ្យបបរអីហូបឲ្យឆ្អែត អ៊ីចឹងហើយក៏ថែមឲ្យ -- អង្ករទាក់ទងយកពីឃុំៗជិតហ្នឹង ឃុំណានៅជាប់ពេទ្យហ្នឹងគេយកមក ទៅយកមក ស្រុកសម្រេចហើយ។ ខំគិតគូរ ប៉ុនការឆកល្វែង ជៀសមិនផុត។

**ស៖** តើលោកយល់ស្របជាមួយខ្ញុំទេ ដែលថានៅក្នុងស្រុករបស់លោកពាក់ព័ន្ធទៅនឹងចំណីអាហារ ថ្នាំសង្កូវ ការអប់រំ គឺថាក្នុងស្រុករបស់លោកមិនមានការរើសអើងជាមួយនឹងប្រជាជន ១៧ មេសា ទេ។ យល់ស្របជាមួយខ្ញុំអ៊ីចឹងទេ?

**ឆ៖** យល់ស្រប។

**ស៖** សូមអរគុណលោក ពេជ្រ ជឹម ខ្ញុំសូមចូលទៅប្រធានបទមួយផ្សេងទៀត។ តើលោកដឹងទេ ឬក៏លោកចាំទេ ថា<>មានមហាមីទ្ទិងនៅខែឧសភា ឆ្នាំ៧៥ <នៅទីក្រុងភ្នំពេញ>ដែលកម្មាភិបាល

ទាំងអស់ ទាំងស៊ីវិលទាំងកងទ័ព គឺថាត្រូវបានគេហៅឲ្យមកចូលនៅក្នុងមហាមីទ្ទិង គឺប្រជុំនៅថ្ងៃទីចន្លោះពី២០ ទៅ ២៤ ឧសភា ១៩៧៥ នៅភ្នំពេញ។ លោកមានជ្រាបរឿងនេះទេ?

[១៤:២៨:៥៧]

**ឆ៖** អត់ទេ អត់បានចូលរួម។

**ស៖** វាជាមហាមីទ្ទិងមួយ ប្រហែលជាមានកម្មាភិបាលរាប់រយ ឬក៏រាប់ពាន់នាក់មកចូលរួមប្រជុំទាំងអស់គ្នាដើម្បីពិភាក្សាបញ្ហាឆ្ពោះទៅមុខទៀត។ តើលោកមានដឹងថាកម្មាភិបាលនៅ<គណៈ>ស្រុកជាមួយ លោកហ្នឹង គឺ<ឈ្មោះ ខុម> មានបានមកចូលរួមប្រជុំនៅក្នុងមហាមីទ្ទិង ខែឧសភា ឆ្នាំ ១៩៧៥ ដែរទេ?

**ឆ៖** ដឹងថាគាត់មក។

**ស៖** តើលោកមាននៅចាំទេថា ខុម បានមកចូលរួមប្រជុំទេ? ហើយបើបានមកចូលរួមប្រជុំមែន នៅពេលដែលគាត់ត្រឡប់ទៅវិញ តើគាត់រាយការណ៍ជូន<លោក និង>គណៈ<>ស្រុកដែរឬទេ?

**ឆ៖** គាត់រាយ ហើយរៀបចំធ្វើពិធីពន្យល់ណែនាំទាំងអស់គ្នាហ្នឹង មិនមែនជាពិធីរៀនសូត្រទេ គ្រាន់តែពន្យល់អស់មួយព្រឹកនេះដែរ។

**ស៖** ខ្ញុំគិតថាវាកើតឡើងយូរហើយលោក ពេជ្រ ជឹម។ តើលោកចាំដែរឬទេ ថាតើ<មានព័ត៌មាន ឬ>របាយការណ៍អ្វីដែលគាត់យកត្រឡប់មកវិញ បន្ទាប់ពីការប្រជុំនៅខែឧសភា ឆ្នាំ១៩៧៥? តើគាត់បានរាយការណ៍ទៅលោក ហើយនិងអ្នកផ្សេងទៀតដូចម្ដេចខ្លះ?

[១៤:៣១:០៥]

**ឆ៖** ខ្ញុំអត់ចាំទេ យូរពេក ភ្លេចហើយ។

**ស៖** ខ្ញុំអាចនឹងជួយលោកបាន <>តើ<លោកនៅចាំទេ ថា> គាត់<មាននិយាយប្រាប់លោក និង>សមាជិកផ្សេងទៀត<>ថា នៅក្នុងអង្គប្រជុំនោះមានការពិភាក្សា មានការណែនាំ ជាឧទាហរណ៍ អំពីការលុបបំបាត់ចោលនូវការចរាចរលុយ ហើយនិងការលុបបំបាត់ចោលនៅទីផ្សែង<>?

**ឆ៖** ធ្លាប់ឮ លុយនិងផ្សារ។

**ស៖** តើលោកចាំបានអ្វីខ្លះដែលថាគាត់រាយការណ៍អំពីបញ្ហានេះទៅលោកឬក៏គណៈស្រុកនោះ?

**ឆ៖** និយាយតែអំពីបំបិទផ្សារ ហើយនិងមិនចាយ របបចាយលុយ អត់ចាយលុយទេ។ ចាំតែប៉ុណ្ណឹង ពីរ(ខ)ហ្នឹង។

**ស៖** តើលោកចាំដែរឬទេ ថាតើគាត់និយាយបញ្ហាមួយចំនួនអំពីការផ្សឹក ឬក៏ការឲ្យព្រះសង្ឃលាចាកសិក្ខាបទហ្នឹង តើគាត់បាននិយាយដែរឬទេ?

**ឆ៖** គាត់និយាយ ប៉ុន្តែមិនដឹងកាលហ្នឹង ឬក៏មុនហ្នឹង។ ខ្ញុំអត់ចាំ គាត់មាននិយាយ និយាយហើយអនុវត្ត គាត់ហ្នឹងនាំធ្វើតែម្តង នាំធ្វើគ្រប់ឃុំធ្វើទៅ ជាមួយគ្នានឹង ចែកគ្នាធ្វើតាមផ្នែក។

**ស៖** តើលោកចាំដែរឬទេ ថាតើគាត់ត្រឡប់មកវិញ ហើយបាននិយាយអ្វីខ្លះអំពីអ្វីដែលត្រូវធ្វើចំពោះប្រជាជនដែលជាអតីតមន្ត្រីរដ្ឋការលន់នល់ ឬក៏ជាអតីតទាហានលន់នល់ ឬក៏នៅក្នុងយោធា លន់នល់ ជាដើមនោះ?

**ឆ៖** មិនចាំទេ។

[១៤:៣៤:០២]

**ស៖** លោក ពេជ្រ ជឹម តើលោកស្គាល់នរណាម្នាក់ដែលធ្លាប់ជា<>កម្មាភិបាលថ្នាក់ខ្ពស់នៅភូមិភាគបូព៌ា ដែលគាត់មានឈ្មោះ ហេង សំរិន ដែរឬទេ?

**ឆ៖** អត់ទេ។ ផ្នែកមួយចំហៀងហ្នឹង អត់ទាំងអស់។

**ស៖** ខ្ញុំគ្រាន់តែសួរលោកថា តើលោកដឹងថាលោក ហេង សំរិន <>ជាអ្នកណា<>? តើលោកអាចជម្រាបតុលាការបានទេ?

**ឆ៖** អត់ដឹង។ ខ្ញុំមិនដឹង ដល់សួរ បងពកៗ រៀងទាក់ទើរទៀត "គាត់ធ្វើអីអំពក? គេធ្វើសេដ្ឋកិច្ចកងពល" ថាប៉ុណ្ណឹង ប៉ុន្តែនិយាយដូចម៉េច ប៉ុន្តែគាត់និយាយមិនដាច់។ ជម្រាបជូនប៉ុណ្ណឹង។

**ស៖** តើលោកនៅចាំឬទេ ប្រហែលជាខ្ញុំព្យាយាមរំឭកការចងចាំរបស់លោក ថាតើ ខុម នៅពេលដែលគាត់ត្រឡប់មកវិញ គាត់បាននិយាយទាក់ទងទៅនឹងថាប្រជាជនដែលជា -- ស្ថិតនៅក្នុងអតីតរបបលន់ នល់ គឺថាអាចដាក់នៅក្រៅក្របខ័ណ្ឌ គេត្រូវបំបែកអ្នកទាំងនោះជាជាងសម្លាប់អ្នកទាំងនោះចោល។ តើធ្លាប់ឮបែបនេះដែរឬទេ?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប! សូមអញ្ជើញសហព្រះរាជអាជ្ញារងអន្តរជាតិ!

**លោក ឌេល លីសាក់៖**

អរគុណលោកប្រធាន។ <ខណៈនេះ> មេធាវីការពារក្តី<កំពុងតែ>សួរសំណួរនាំមុខដល់សាក្សី ខ្ញុំ<នឹង>មិនមាន<ការ>ជំទាស់ទេប្រសិនបើគាត់ចង់ប្រើការសិក្សាស្រាវជ្រាវរបស់ ប៉ែន យៀវនិន

ហើយសួរសំណួរសាក្សីដើម្បីរំឭកការចងចាំ<នោះ។ វា>ទាក់ទងទៅអ្វីដែលគាត់បានធ្វើពីម្សិលមិញ <គឺ>មនុស្ស<បី ឬបួននាក់>ដែល<និយាយពី>គោលនយោបាយ <និងការ>ណែនាំ គឺឲ្យកម្ទេច <មនុស្សពីរនាក់ បន្ទាប់មក មេធាវីបានទាញទស្សនៈ>ផ្ទុយ<>ទៅវិញ<។> បើ<ណាជា>គាត់ចង់ប្រើភស្តុតាងនោះ គឺអាចប្រើបាន ប៉ុន្តែមេធាវីមិនគប្បីសួរនាំមុខសាក្សី<ដោយការបកស្រាយតែមួយចំហៀង>ទេ។

[១៤:៣៦:៤៨]

*(ចៅក្រមពិភាក្សាគ្នា)*

[១៤:៣៧:៣៩]

**ប្រធានអង្គជំនុំ៖**

បាទ ហើយអង្គជំនុំជម្រះឯកភាពតាមការកត់សម្គាល់របស់សហព្រះរាជអាជ្ញារងអន្តរជាតិ គឺពិតជាប្រភេទសំណួរនាំមុខ ហើយមានចំនួនច្រើនផងនៅក្នុងការតាំងសំណួរនេះ។

សាក្សីមិនបាច់ឆ្លើយតបនឹងសំណួរដែលសួរនាំមុខអម្បាញ់មិញនេះទេ។ ហើយចំណែកលោកមេធាវី វ៉ិចទ័រ កូប៉េ សូមលោករៀបចំនៅសំណួរសាជាថ្មីម្តងទៀត ជៀសវាងក្នុងការតាំងសំណួរប្រភេទបែបសំណួរនាំមុខ ដែលជាសំណួរហាមឃាត់នៅក្នុងនីតិវិធីតុលាការ។

**លោក វ៉ិចទ័រ កូប៉េ៖**

អរគុណលោកប្រធាន។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោក ពេជ្រ ជឹម តើពាក្យថា "កម្ចាត់" មានន័យដូចម្តេច តាមដែលលោកយល់នោះ?

**លោក ពេជ្រ ជឹម៖**

**ឆ៖** "កម្ចាត់"គឺយកចេញ ធ្វើឲ្យខ្ចាត់ខ្ចាយ ឬថាដកចេញ។ គេប្រើនៅក្នុងមាគ៌ាទេ គោលជំហរទស្សនៈកម្ចាត់សតិអារម្មណ៍ ល្អោភ លោភលន់បុណ្យស័ក្តិ កសាងគោលជំហរកសិករ អត់បុណ្យស័ក្តិ។ កម្ចាត់អ្វីដែលមិនល្អចោលក្នុងខ្លួន ហើយកសាងថ្មីដែលល្អ ដែលត្រឹមត្រូវ សតិអារម្មណ៍នាហ្មឺន មន្ត្រីរាជការ កម្ចាត់វាចោល ហើយកសាងគោលជំហរថ្មី។ ត្រង់ហ្នឹងដែលធ្លាប់ធ្វើនាហ្មឺ ប៉ុនៗណាណី កម្ចាត់ចោល ហើយមកធ្វើអារម្មណ៍មកកសិករ ពិបាកនឹងធ្វើណាស់ គឺគិតអ៊ីចឹងក្នុងពោះ ប៉ុន្តែចេះតែខំធ្វើ។ ខំធ្វើទៅវាបានសម្រេចមួយចំណែកៗ ហើយស្អីដែលធ្វើទៅវាៗចេះតែកើត តែដាំវាចេះតែដុះ។ សូមលើក

ប៉ុណ្ណឹង។ នេះ “កម្ចាត់”។

[១៤:៤០:២០]

**ស៖** សេចក្តីដែលលោកពន្យល់ ដែលលោកពន្យល់អំពីពាក្យថា “កម្ចាត់”នោះ តើវាជាអ្វីដែលស្ថិតនៅក្នុងគោលនយោបាយដែលត្រូវអនុវត្តចំពោះប្រជាជនដែលបានធ្វើការ ចំពោះអតីតរបប លន់ នល់ ដែរឬទេ<?> ដើម្បីអប់រំកែប្រែពួកគេ ដើម្បីយកពួកគាត់ចេញពីក្របខ័ណ្ឌ ហើយក៏ក្រោយមកបញ្ជូនគាត់ចូលមកក្នុងសង្គមវិញ។ តើអ៊ីចឹងដែរឬទេ?

**ឆ៖** ហ្នឹងគាត់ត្រូវ ឱ្យគាត់ខំកសាងខ្លួន ហើយគាត់រស់នៅក្នុងសង្គមមក គាត់កម្ចាត់អ្វីដែលធាតុមិនល្អក្នុងខ្លួនចេញចោលទៅ គាត់មកវិញវាល្អហើយ វាមិនមែនមកភ្លាម ល្អភ្លាម វាទៅបណ្តើរៗយូរមួយឆ្នាំ ពីរឆ្នាំទៅ មកល្អមែនទែន។ ក្នុងន័យអ៊ីចឹង។

**ស៖** លោក ពេជ្រ ជឹម <តើ>វាជាគោលនយោបាយនៅក្នុងស្រុក១០៥ដែរឬទេ នៅពេលដែលនិយាយអំពីការប្រព្រឹត្តទៅលើអតីតរដ្ឋការលន់ នល់ ហើយនិងអតីតអ្នកយោធារបបលន់ នល់ ដើម្បី “កម្ចាត់” ពួកគេហ្នឹង?

[១៤:៤១:៥០]

**ឆ៖** អាហ្នឹង ពាក្យហ្នឹងថា ត្រូវទាំងអស់ៗ ព្រោះភាសា អាហ្នឹងពាក្យភាសាតើ។

**ស៖** <តាម>ភាពជាក់ស្តែង<> តើលោកចាំទេ ខុម, សោម ធ្លាប់បានប្រើពាក្យ “កម្ចាត់” ដែរឬទេ នៅពេលដែលគេ<ប្រព្រឹត្ត> ទៅលើអតីតអ្នករដ្ឋការ ឬក៏ទាហាន លន់ នល់នោះ?

**ឆ៖** តាមធ្លាប់ មិនសូវដែលឮប្រើទេ។ កម្ចាត់នេះ កម្ចាត់នោះ កម្ចាត់របបទាហានលន់ នល់អីមិនដែលប្រើ។ បើរៀនសូត្រ ហើយលើក ដូចខ្ញុំលើកហ្នឹង គេលើកមែន។ អ្ហ៎! កម្ចាត់បុគ្គលដែលអន្តរាយកម្ចាត់អ្វីដែលមិនចំណេញ។ លោគេថាទាហានរដ្ឋបាលលន់ នល់ គាត់ថា “ដែល” មិនមែនកម្ចាត់ទាំងស្រុងទេ ដែលអន្តរាយ។ នៅមាន“ដែល”ទៀត ចុះបើគេអត់អន្តរាយ គេល្អ ប៉ះគេម៉េច កម្ចាត់គេម៉េច។ ដល់នេះ អ្នកដែលយល់សើ កម្មាភិបាលទាបៗ សំខាន់នារីភេទ គាត់វៃរួមទាំងអស់ ហើយយើងយល់ជ្រៅជ្រះជាងហ្នឹង យើងពន្យល់បានដឹងវិញ។ អត់ គាត់មកទាំងអស់។ អ៊ីចឹង អារឿងស្លឹកគ្រៃមួយគល់មាន់មួយ ចាប់ចងចុះឡើង គឺពួកហ្នឹងហើយ។ មិនមែនប្រុសៗដែលងាយធ្វើអ៊ីចឹង មិនងាយទេ។ អ៊ីចឹងមិនងាយនារីភេទទេ ប៉ុន្តែគ្នាវប្បធម៌តិច ហើយអស់លោកឃើញអ៊ីចឹង វប្បធម៌តិច។ ជឿណាស់ ជឿបក្សណាស់ គោរពបក្សណាស់ ប៉ុន្តែអត់ពិចារណាទេ។ ថែបក្សណាស់ ហើយឃើញទៅដល់ បាយផ្អិន

ឥឡូវហើយ មាន់ក៏កាប់ដែរ គឺស្នោះត្រង់អ៊ីចឹង។ ប៉ុន្តែហេតុផលអីច្រើនទៅទៀត ដើម្បីការពារបក្សឱ្យរីកចម្រើននោះ ហ្នឹងប្រៀបធៀបដូចជាបក្ស នែ៎ ហូបបាយហើយ អើសម្រាកបន្តិច ឃើញបក្សសម្រាកលក់ទៅហើយ វុយមកទំច្រមុះលើកដុំថ្មគប់ម៉ាំង។ ម៉ាំង ងាប់បក្ស។ ស្រលាញ់ពេក អត់បញ្ហា។ ខ្ញុំលើកមួយម៉ាត់ហ្នឹង គឺអត់សួរមានបញ្ហា។ ហើយអ្នកណាធ្វើឱ្យមានបញ្ហាអស់ បែក៧០ភ្លាម ធ្វើភ្លាម មកឈ្លូទឹកជន់ បាក់ទំនប់។ បងៗលើៗ នៅលើឯណោះ មានមកនៅក្រោមឯណា។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណសាក្សី។ អរគុណលោកមេធាវី។ បាទ ឥឡូវនេះដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅរហូតដល់ម៉ោងបី សូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សី និងអ្នកជំនាញដល់សាក្សីរូបនេះ នៅក្នុងអំឡុងពេលឈប់សម្រាក និងឱ្យអញ្ជើញគាត់រួមទាំងមេធាវីប្រឹក្សារបស់គាត់ផងមកកាន់កន្លែងផ្តល់សក្ខីកម្មនៅបន្ទប់សវនាការនេះ នៅវេលាម៉ោងបី។

សម្រាកចុះ។

*(សវនាការសម្រាកពីម៉ោង ១៤:៤៦ នាទី ដល់ម៉ោង ១៥:០២ នាទី)*

[១៥:០២:០១]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ ហើយបន្តទៅនេះផ្តល់វេទិកាជូនទៅមេធាវី វ៉ិចទ័រ កូប៉េ ដើម្បីមានឱកាសបន្តការតាំងសំណួរដេញដោលចំពោះសាក្សី។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** ជម្រាបសួរលោក ពេជ្រ ជឹម។ ខ្ញុំមានសំណួរ មួយ ឬពីរ ទៀតដើម្បីបន្តទាក់ទងទៅនឹងសំណួរទាំងឡាយមុនពេលឈប់សម្រាក។ ប្រហែលជាលោកមិនចាំទេ ប៉ុន្តែខ្ញុំបានសួរលោកនូវសំណួរខ្លះនៅក្នុងខែមិថុនា <*(ស៊ីក)*> ឆ្នាំ២០១៣ ក្នុងសវនាការដំបូងនោះ<។> ខ្ញុំគិតថាខ្ញុំដឹង ចម្លើយ<រួច>ទៅ<ហើយ ចំពោះ>សំណួរដែលខ្ញុំ<ចង់>សួរ<>ប៉ុន្តែខ្ញុំ<ចង់>សួរម្តងទៀត។ តើខ្លួនលោកផ្ទាល់នៅ

ពេលដែលលោកនៅស្រុក១០៥ នោះបានឃើញដោយផ្ទាល់ភ្នែកនូវការកាប់សម្លាប់ ឬក៏ការសម្លាប់អតីតមន្ត្រីរដ្ឋការ លន់ នល់ ឬក៏យោធាលន់ នល់ ដែរឬទេ?

**លោក ពេជ្រ ជឹម៖**

**ឆ៖** មិនដែលមានបានឃើញច្បាស់នឹងភ្នែកទេនូវការកាប់សម្លាប់យោធាលន់ នល់។

**ស៖** សំណួរបន្ទាប់ដែលខ្ញុំសួរនៅក្នុងខែមិថុនា<*(ស៊ីក)*> ឆ្នាំ២០១៣ ដែរហ្នឹង ថាតើខ្លួនលោកផ្ទាល់ធ្លាប់បានបញ្ជាឲ្យមានការកាប់សម្លាប់នូវអតីតរដ្ឋការលន់ នល់ ឬក៏អតីតទាហានលន់ នល់ ដែរឬទេ? ខ្ញុំឮលោកនិយាយថាអត់ទេ។

**ឆ៖** ពិតហើយ ខ្ញុំអត់មានដែលកាប់បញ្ជាឲ្យកាប់សម្លាប់ទាហាន លន់ នល់ទេ។

**ស៖** តើលោកដឹងអំពីការកាប់សម្លាប់ណាមួយនូវអតីតរដ្ឋការលន់ នល់ ឬក៏អតីតទាហានលន់ នល់ ដែរឬទេ នៅក្នុងស្រុករបស់លោករវាងឆ្នាំ១៩៧៥ រហូតទៅដល់ឆ្នាំ១៩៧៩ នោះ?

**ឆ៖** ខ្ញុំមិនដែលបានឃើញ ហើយមិនដែលបានធ្វើផ្ទាល់ដៃ តែដឹងថានឹងមានៗ មិនមែនអត់ទេ។

**ស៖** ខ្ញុំសូមបន្តទៅប្រធានតំបន់១៣ គឺឈ្មោះតាសោម។ លោកបានផ្តល់សក្ខីកម្មដល់អ្នកស៊ើបអង្កេតអំពីតាសោម លោកបាននិយាយដោយសង្ខេបអំពីគាត់ ជាពិសេសនៅក្នុងសក្ខីកម្មដំបូងរបស់លោក។ តើលោកអាចជម្រាប<>តុលាការអ្វីខ្លះអំពី តាសោម ថាតើគាត់ជាមនុស្សបែបដូចម្តេចទាក់ទងទៅនឹងមាគ៌ាបក្ស ហើយនិង<គោល>ជំហរនយោបាយរបស់គាត់?

[១៥:០៦:១៣]

**ឆ៖** សូមបញ្ជាក់ថា សោម ពីមុនអត់ស្គាល់ ក្រោយរំដោះទូទាំងប្រទេស ក្រោយរដ្ឋប្រហារៗឃើញគាត់មក។ មកគេប្រាប់ ញៀវ វាខ្សឹបថា "នេះថ្នាក់តំបន់ មិនមែន លោកមុត អនុទេ នេះគណៈតំបន់មកថ្មី" ស្គាល់ត្រឹមហ្នឹងមក។ គាត់មកនៅផ្ទះ ញៀវ ខ្ញុំនៅកន្លែងផ្សេង ប៉ុន្តែល្ងាចឡើងដើរទៅហ្នឹងជួបគ្នាប្រាប់ដោយៗ មិនៗប្រាប់ចំហគេឮទេ ប្រាប់ដោយស្ងាត់ៗចង់ឲ្យស្គាល់មុន។ ក្រោយមកក៏ដំណើរការធ្វើការហែៗទៅ អត់ទាន់មានថ្នាក់លើមកប្រកាសអីទេ តាមមើល សែ គេដឹងអស់ហើយប្រាប់ លោកមុត ខុម អីដឹងអស់ហើយ ទទួលការចាត់ចែងពីគាត់ធ្វើហែៗ។ យូរណាស់បានធ្វើរៀបចំជាគណៈ ប្រកាសជាគណៈ ប៉ុន្តែពេលបុណ្យ ពេលពិធីអីមួយៗគេតាំងអង្គុយគណៈហ្នឹងស្រេច។ គាត់ ខ្ញុំស៊ើបសួរទេបញ្ញាជននៅទីក្រុងភ្នំពេញ ហើយកាលសម័យកុបកម្ម៦៨ មិនដឹងគាត់ទៅនៅឯណា អត់ដឹងទេ។ ដល់គាត់បានប្រពន្ធ នៅយកកំពង់ឆ្នាំង កាលនេះឲ្យគាត់គេចទៅនៅកំពង់ឆ្នាំង។ គាត់មក មិត្តភាស់ ហ្នឹងមក

ដែរ។ មកបានមួយឆ្នាំ ឃើញតាម៉ុករៀបចំឲ្យ ភាស់ នៅកំពង់ឆ្នាំង។ និយាយពីសមត្ថភាព ការអង់អាច គាត់មានរោគប្រចាំខ្លួនរបេង ក្អក។ សមត្ថភាពវប្បធម៌ខ្ពស់ ភាសាខ្មែរចេះជ្រៅជ្រះ សរសេរមិនខុសពាក្យទេ ហើយមិនឈ្លើយពាក្យទេ។

[១៥:០៩:៤១]

**ស៖** តើគេមើលឃើញគាត់ ឬក៏គេចាត់ទុកគាត់ថាៗជាបុគ្គល<>ឆ្វេងនិយមទេ ជាមនុស្សដែលជ្រុលនិយមទេ ជាអ្នកដែលគាំទ្របដិវត្តន៍វប្បធម៌ដែរឬទេ ដែលគេអនុវត្តនៅប្រទេសចិន<>? <> គេឃើញគាត់អ៊ីចឹងដែរឬទេ?

**ឆ៖** ពីបក្សមក ខ្ញុំមិនដឹងទេ។ បើមហាជនក្នុងស្រុក ក្នុងឃុំ គេលើកថាគាត់កាចគេច ដាច់រណសិរ្សហើយតានេះ បែករណសិរ្ស។ រណសិរ្សហ្នឹងថា "ប្រមូលកម្លាំង" ហើយកាចហ្នឹងវាដាក់ខាត។ សូមបញ្ជាក់ប៉ុណ្ណឹង។

**ស៖** តើលោកអាចជម្រាបតុលាការបានទេ តើគាត់មានទំនាក់ទំនងអ្វីជាមួយ ជូ ជេត ហៅស៊ី?

**ឆ៖** មិនមានទេ។ គាត់ហ្នឹងគោរពខាងលើណាស់។ ជូ ជេត ខាងលើរបស់គាត់, តាម៉ុក ក៏លើរបស់គាត់ គោរពខាងលើ។ ធ្វើការមាត់ប្រែ អប់រំនយោបាយ និយាយកាត់ម៉ាត់ៗ ស៊ីជម្រៅ ជ្រះៗថ្លា។ រៀនគាត់ចប់ គឺយល់ ដូចជាគេចេះហ្មង គេចេះវែកញែក ចេះលើក។ ត្រង់ៗថា ជូ ជេត ម៉េចៗ ហើយទាក់ទងម៉េចៗ ឃើញទៅ ជូ ជេត ទៅម្តងដែរ។ ទៅ ជូ ជេត ចូលមន្ទីរស្រុកហ្នឹង គាត់សម្រាន្តនៅហ្នឹង ប្រពន្ធក៏ទៅ, ខុម ក៏ទៅហ្នឹង, សោម ក៏ចេញមកកន្លែងខ្ញុំហ្នឹង។ ប៉ុនកាលនុង់មិនមានទាន់ឮទាស់គ្នាអីទេ។ តាម៉ុក ក៏មកជួបគ្នានៅហ្នឹង។ ហ្នឹងក្រោយរំដោះ។ ដូចនេះ ការវាគាបសង្កត់ មានទាក់ទងអីជាមួយ ខ្ញុំថាអត់ទេ។

[១៥:១២:២៧]

**ស៖** តើ សោម ក្រោយមកគាត់មានបញ្ហាអ្វីដែរ? តើនៅពេលណាមួយគេចាប់ខ្លួនគាត់ដែរឬទេ?

**ឆ៖** អត់ទេ។ គាត់អត់ត្រូវគេចាប់ខ្លួនទេ។ រួចគាត់ឈឺ ជិតៗចប់ហ្នឹង គឺគាត់មកដេកពេទ្យនៅភ្នំពេញ ប្រពន្ធគាត់មកដេកមុន ឆ្លងទន្លេឆ្លងអី បានកូនធំហើយ បានគាត់ឈឺធ្ងន់ ក៏យក បងសោម មកដេកពេទ្យ។ ដល់សភាពការណ៍វៀតណាមចូលមក គេរត់ចេញភ្នំពេញអស់។ ប្រពន្ធធ្វើការហៅភៀវក្រសួងការបរទេស ទាក់ទងភៀវ។ ហើយគាត់ចេញទៅដល់ស៊ីសុផុន យកគាត់ទៅដល់ហ្នឹងជាមួយ។

ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។

ដល់ណេះឲ្យទៅទៀត មិនទៅ ដូចជាវិបត្តិវិកលចរិតយ៉ាងម៉េច។ "អញ យួនចូលស្រុកដោយសារអញ អញមិនទៅទេ ងាប់នៅហ្នឹង"។ ប្រពន្ធធ្វើម៉េចក៏មិនទៅ ដល់យូរដាច់ចិត្តទៅជាមួយកូនទៅ។ ហើយអ្នកមន្ទីរអ្នកអីហ្នឹង។ គាត់នៅហ្នឹង ទៅតាមបានយូរ តាមរកវិញអត់ឃើញ បាត់ត្រឹមហ្នឹង។

**ស៖** តើពេលណាមួយ គាត់បានធ្វើការនៅក្រសួងការបរទេសទេកាលនោះ និយាយពី សោម?

**ឆ៖** ឈ្មោះចូលក្រសួងការបរទេស ប៉ុនខ្លួននៅក្នុងពេទ្យ។ មែន អ៊ីចឹងហើយ។ ក្រសួងការបរទេសមានអ្នកផ្សេងមួយទៀត។ គាត់នុ៎ងអាចថែមពីលើទេ បើគិតជាឋានៈ អ្នកថែមមកហ្នឹង គាត់ហ្នឹងខ្ពស់ជាង។

**ស៖** តើលោកបានឃើញគាត់ចុងក្រោយនៅពេលណា? ខែឆ្នាំណា បាទ?

**ឆ៖** ខ្ញុំហៀបមក លាគាត់ គាត់យំ ថា "នៅនោះមានតែមិត្តទេចិញ្ចឹមខ្ញុំ ឥឡូវ មិត្តទៅចោលខ្ញុំហើយ"។ ជូនពរផង យំផង ហ្នឹងខ្ញុំចេញពីតាកែវ។ ដល់មក គាត់មកនៅពេទ្យ ពេទ្យព្រះសង្ឃ ខ្ញុំនឹក ជិះ -- ន៎ែ ដូង រកដូងបានមួយផ្លាយ ដឹកមក មកលេងគាត់ សួរសុខទុក្ខបង ជូនដូងមួយផ្លាយ។ មកទឹកភ្នែកទៀតហើយ។ ថ្ងៃនោះ ខ្ញុំយកកូនមកតាម តូច ប្រពន្ធក៏មកដែរ។ "ន៎ែ មកក្រោយ មកពេទ្យ កុំយកកូនមក" ហើយក៏លាវិញហើយ មួយភ្លែតទេ លា អត់បានទៅយូរ។

[១៥:១៦:១៤]

**ប្រធានអង្គជំនុំ៖**

លោក ពេជ្រ ជឹម យើងបានជម្រាបលោកម្តងហើយ សូមរំឭកលោកថា សូមលោកស្តាប់សំណួរឲ្យបាន ហើយលោកឆ្លើយតបភាពចាំបាច់ទៅនឹងសំណួរបានហើយ ជៀសវាងលោកធ្វើអត្ថាធិប្បាយវែងឆ្ងាយទៅវាមានការលំបាក។ អ្នកដែលលំបាកខ្លាំងគឺលោកទេ ដែលត្រូវប្រឈមនឹងសំណួរបន្តទៀត ដោយសារមូលហេតុនៃការដែលលោកឆ្លើយផុត ដែលលៀនផុតចេញពីភាពចាំបាច់នៃការឆ្លើយតបនឹងសំណួរ។ ទី២ គឺអង្គជំនុំជម្រះត្រូវការពេលវេលា ព្រោះពេលវេលាមិនវែងទេ សម្រាប់ស្តាប់សក្ខីកម្មរបស់លោក។

សូមអញ្ជើញលោកមេធាវីបន្តទៀត!

**សួរដោយលោក វ៉ិចទ័រ កូប៉េះ**

**ស៖** សំណួរខ្លី លោក ពេជ្រ ជឹម តើលោកបានជួប សោម ទេ បន្ទាប់ពីឆ្នាំ១៩៧៩ ក្រោយពីវៀតណាមបានឈ្លានពានកម្ពុជានោះ?

**លោក ពេជ្រ ជឹម៖**

**ឆ៖** ទេ ជួបតែកាលគាត់នៅដេកពេទ្យ។

**ស៖** ចុះអំពីអនុលេខា<>តំបន់១៧ឈ្មោះ <ផែន> តើលោកដឹងអ្វីខ្លះ<ពី>ឈ្មោះ ផែន។

[១៥:១៧:៤៨]

**ឆ៖** ឈ្មោះ ផែន ទៅធ្វើគណៈតំបន់៤៣។ ទៅណាមកណា ចូលផ្ទះខ្ញុំ។ មកកំពង់ចាម កន្លែង កែ ពក។ ចេញចូលតែហ្នឹង បាយទឹកហ្នឹង សម្រាកហ្នឹង ហើយក៏មកវិញ ទៅផ្ទះគាត់ទៅ។ ក្រោយមក ដកគាត់ទៅវិញ កាលមុន ដកតែភាគកណ្តាល ក្រោយមក ទៅនិរតីវិញ។ ដល់ដកមកនិរតី យើងនៅនោះ លែងដឹងហើយ។

**ស៖** តើ ជូ ជេត <ហៅ ស៊ី> ហើយនិង ផែន គាត់មានទំនាក់ទំនងអ្វីនឹងគ្នាដែរឬទេ?

**ឆ៖** អត់ទេ។ ប៉ុន្តែ ផែន សួរថាម៉េចបានដក? ថាគេចាប់ប្អូន តែប៉ុណ្ណឹង។ ក្រោយមក ឮដំណឹង នៅរស់រហូត។ វៀតណាមចូលមក នៅព្រៃដំរីរមៀល។ ស្លាប់ហ្នឹង វ៉ៃគ្នានៅក្នុងព្រៃ ស្លាប់ហ្នឹង។ ហ្នឹងខ្ញុំ ដឹងតៗមក។ ក្នុងហ្នឹង កូនខ្ញុំស្លាប់ជាមួយម្នាក់ដែរ ខ្ញុំបាត់កូនប្រុសមួយ។ សូមអស់។

**ស៖** <ជាចុងក្រោយ> តើលោកដឹងពីទំនាក់ទំនងអ្វីដែរឬទេ រវាងតាគាវ ហើយនិង ជូ ជេត?

**ឆ៖** អត់ទេ។

**ស៖** ជូ ជេត គឺជាមេដឹកនាំភូមិភាគបស្ចិម ហើយនៅ<>ពេលមួយទៀតនោះ គឺថាជាថ្នាក់ ដឹកនាំនៅភូមិភាគនិរតី<ជាមួយ តាម៉ុក>។ តើលោកនៅចាំដែរឬទេ <>ពេលណាដែលភូមិភាគនឹងត្រូវ បានបែងចែកទៅជាពីរ គឺភូមិភាគនិរតីហ្នឹង ត្រូវបានបំបែកទៅជាភូមិភាគពីរ<នៅពេលណា>?

**ឆ៖** មិនចាំច្បាស់ទេ ប៉ុន្តែក្រោយ១៧ មេសា បំបែកភាគហ្នឹង។ ភូមិភាគនិរតីធ្វើជាពីរ។ ខាង នោះធ្វើជាបស្ចិម ជូ ជេត, ហើយខាងនិរតីនេះ តាម៉ុក។

[១៥:២១:១៥]

**ស៖** តើលោកដឹងមូលហេតុអ្វីបានគេចាប់ ជូ ជេត នៅក្នុងខែមីនា ឆ្នាំ១៩៧៨នោះទេ?

**ឆ៖** អត់ទេ។

**ស៖** តើលោកដឹងពីទំនាក់ទំនងរវាង ជូ ជេត ហើយនិង សោ ភឹម ដែលជាមេដឹកនាំនៅភូមិភាគ បូព៌ាដែរឬទេ?

**ឆ៖** អត់ទេ។

**ស៖** អ្នកស៊ើបអង្កេតបានសួរលោកនូវសំណួរនេះ ហើយខ្ញុំសួរលោកម្តងទៀត តើលោកស្គាល់ រស់ ញឹម ជានរណាដែរឬទេ?

**ឆ៖** ឮតែឈ្មោះ មិនដឹងមុខមាត់អាម៉េចផង ឮតែឈ្មោះ ហើយឮធ្វើការ ធ្វើភូមិភាគ។ មិនដឹងនៅបស្ចិម ឬនៅពាយ័ព្យ ឬបូព៌ា ខ្ញុំមិនចាំអត់ស្គាល់ច្បាស់។ ស្គាល់តែឈ្មោះទទេទេ ដូចស្គាល់ដំរីអ៊ីចឹង។

**ស៖** តើលោកដឹងអ្វីខ្លះដែលថាមានរដ្ឋប្រហារដែលដឹកនាំដោយ សោ ភឹម ក្នុងឆ្នាំ១៩៧៨ដែរឬទេ?

**ឆ៖** អត់ទេ។

**ស៖** តើលោកអាចប្រាប់យើង<បានអ្វីខ្លះ>អំពីការបះបោរ<?> លោកបានឆ្លើយ<ក្នុងកិច្ចសម្ភាសន៍ជូន>ទៅអ្នកស៊ើបអង្កេតអំពីការបះបោរ ហើយម្សិលមិញលោកបាននិយាយ<>អំពីការ<តស៊ូ>ផ្ទៃក្នុង ថាតើអ្នកណាវាយប្រឆាំងជាមួយអ្នកណា? តើលោកអាចនិយាយឲ្យច្បាស់ជាងនោះបានដែរឬទេ? តើលោកចង់មានន័យដូចម្តេចដែល<>និយាយថាក្រុមនៃកម្មាភិបាលនៅក្នុងបក្សកុម្មុយ-នីស្តកម្ពុជា គឺវាយគ្នាទៅវិញទៅមក។ សូមឲ្យលោកពន្យល់តុលាការឲ្យពិស្តារបន្ថែមពីអ្វីដែលលោកចង់និយាយនោះ?

[១៥:២៣:៥០]

**ឆ៖** សូមបញ្ជាក់ខ្លីៗ។ ខ្ញុំឃើញសភាពការណ៍អ៊ីចឹងក៏ខ្ញុំចេះតែគិតឃើញ។ ម៉េចបានទាស់គ្នា? បើទាស់គ្នាសួរចម្លើយ អត់មានមនុស្សពីណាពីខ្សែបក្ស ចាប់ "ក"។ "ក" ឆ្លើយខ្សែបក្សទាំងអស់ ហើយមកចាប់មេក្រុម មេកងយើង វាប៉ះខ្លួនឯង។ ហ៏! ដល់មួយទៀត ទៅអ៊ីចឹងទៀតៗចាប់សុទ្ធតែខ្សែបក្សខ្លួនឯង។ ដល់អ៊ីចឹងខ្ញុំ ទប់មាត់វាមិនបាន អាទឹកចិត្តវាកញ្ច្រោល វាឃើញថាវាមិនត្រូវ ធ្វើអ៊ីចឹងអត់ត្រូវ វាផ្ទុះចេញមក។ សូមជម្រាបត្រង់អ៊ីចឹង។ ហើយដូចរឿងលោកសួរខ្ញុំប៉ុន្មានមកហ្នឹង រឿងអ៊ីចឹង។ តាម៉ុក ជាមួយ ជូ ជេត អត់ត្រូវគ្នា បានបំបែកភាគឲ្យនៅមួយម្នាក់។ បំបែកហើយ ហ៏! បងសែ – បងសែ នៅកំពត។ រួចថា តាសែ ខ្ញុំយួន ទាក់ទងខ្សែយួន ដកទៅសៀមរាប។ ដល់សៀមរាបចាប់បាត់។ មិនដឹងពិតឬមិនពិត ខ្សែក៏មិនមែនខ្សែ ហើយគ្នាយើងហ្នឹងចេះតែយូរៗទៅដណ្តើមគ្នាធ្វើធំ ខ្មែរយើង។ និយាយអ៊ីចឹងខ្ញុំនិយាយត្រង់ហើយហ្នឹង យកដាក់គុករឿងដឹងធ្វើម៉េច ទោសគេថាអ៊ីចឹងក៏ -- ហើយ សយ គាត់សួរទៅ បូព៌ា ពាយ័ព្យ ភឹម, ញឹម ទាំងអស់ហ្នឹងក៏រឿងតែមួយ។ កាល វន វេត នៅ វន វេត ហ្នឹងក៏មិនមែនតូចបក្សធំអី សុទ្ធតែ សុទ្ធធំៗ។ ទីបំផុត និយាយឲ្យអស់ទៅ អត់មានពេលមកបញ្ជាក់ជូនទៀតទេ។ ទីបំផុត

តាម៉ុក, ប៉ុល ពត ទាស់គ្នា យក្សជល់គ្នាថាមួយម៉ាត់ចុះ ហើយនេះបងនួន ហើយ បងខៀវ ឱបដៃមើល។ ជល់គ្នាគ្រាំងមានផ្ទុះអាវុធមួយព្រូ បានទប់ទាន់ទៅ ប៉ុល ពត ប្រគល់អំណាចមកលើតាម៉ុកទាំងអស់។ ទាំងយោធា ទាំងនយោបាយនិងបក្ស ប៉ុល ពត សុំ តាម៉ុក ឡើងឈររៀបចំ។ ខ្ញុំអត់បានចូលទេ ប៉ុន្តែខ្ញុំដឹងតាមពីអ្នកទៅ ក៏ព្រម។ ព្រម ប៉ុន្តែមិនអស់ចិត្ត ឲ្យរៀបចំហើយទទួលទាំងអស់ហ្នឹង វិធីអីទាំងអស់ហ្នឹង។ សូមបញ្ចាក់--

[១៥:២៧:៣៥]

**ស៖** លោកបានឆ្លើយឆ្ងាយពីវិសាលភាពសំណួររបស់ខ្ញុំ។ តើលោកនិយាយអំពីការប៉ះទង្គិចគ្នារវាងតាម៉ុក និង ប៉ុល ពត <នៅអំឡុងឆ្នាំ១៩៧៥ ឬ>ក្រោយពីឆ្នាំ១៩៧៩ ឬក៏ឆ្ងាយរហូតទៅដល់ឆ្នាំ១៩៨០ <ឬ៩០> ឯណោះទេ?

**ឆ៖** ៧៩ ថ្មីៗនេះ ហើយចប់ទៅហ្នឹង។ ហ្នឹងនិយាយហ្នឹងដល់កន្លែងចប់ហើយ បញ្ចប់ត្រឹមហ្នឹង បើមេៗកំពូលបុកគ្នាហើយចប់ រលត់ ទីក្រុងអន្លង់វែងរលត់ ខ្មែរក្រហមត្រូវរលត់ ភ្លើងធំរលត់ទៅហើយ។ សូមអស់។

**ស៖** ខ្ញុំនឹងត្រឡប់ទៅចំណុចមួយ លោក ពេជ្រ ជឹម <គឺអំពី>ពាក្យ<> "ការឆ្លើយដាក់<គ្នា"។ លោកលើកឡើង>ថា "មានអ្នកខ្លះឆ្លើយដាក់ទៅអ្នកខ្លះទៀត"។ តើលោកបានដឹងដែរឬទេថា ដួ ជេត បានឆ្លើយដាក់ទៅ សោម, ផែន, ហើយនិង គាវ ដែរឬទេ ដែលថាជាអ្នកសមគំនិតនឹងគ្នានោះ <ឬក៏> លោក<មិន>បានដឹង<រឿងនេះ>ទេ?

**ប្រធានអង្គជំនុំ៖**

ឆ្លើយលោកពេជ្រ ជឹម អំមិញមិនទាន់ឆ្លើយទេ លោកឆ្លើយក្បាលមីក្រូហ្វូនមិនទាន់ប្រតិបត្តិការទេ។

**លោក ពេជ្រ ជឹម៖**

**ឆ៖** អត់ទេ អត់ដឹងទាំងអស់។

[១៥:២៩:២៦]

**ប្រធានអង្គជំនុំ៖**

ហើយអង្គជំនុំជម្រះកត់សម្គាល់ឃើញលោកអស់កម្លាំងអីចឹងហើយ បានជាអង្គជំនុំជម្រះបានណែនាំលោកឲ្យស្តាប់សំណួរឲ្យបាន ហើយឆ្លើយតបនូវភាពចាំបាច់ពេញលេញគ្រប់គ្រាន់ទៅនឹងសំណួរបានហើយ ជៀសវាងលោកធ្វើអត្ថាធិប្បាយ ហើយលោកមកគិតខ្លួនឯងថាមានការហត់នឿយខ្លាំងទៅ

វិញនោះ។ សូមរំឭកម្តងទៀត សូមឲ្យឆ្លើយឲ្យចំនឹងសំណួរដែរសួរបានហើយ ពាក្យខ្មែរគេថា “សួរអីឆ្លើយហ្នឹង”។

**លោក វ៉ិចទ័រ កូប៉េ៖**

លោកប្រធាន <នេះគ្រាន់តែជាមតិយោបល់ប៉ុណ្ណោះ។ បើសិនជាការកត់សម្គាល់របស់លោកប្រធាន ឃើញ>ថាសាក្សីគាត់មានការនឿយហត់<ពិតមែន> ខ្ញុំអាចនឹងផ្អាកនៅពេលនេះ<ក៏បាន ពីព្រោះ យ៉ាងណាក៏ដោយ> ខ្ញុំអាចបន្តនៅថ្ងៃស្អែក< ហើយ>អាចនឹង<ស៊ីពេល>កន្លះម៉ោងសម្រាប់ខ្ញុំ។ <ការសួរកន្លះម៉ោងនៅថ្ងៃស្អែក ប្រហែលជាបានផលច្រើនជាងកន្លះម៉ោងនៅថ្ងៃនេះ។> អ៊ីចឹង នេះជាសំណើតាមដែលមតិលោកប្រធានទេ ប៉ុន្តែការសម្រេចគឺជាសិទ្ធិរបស់អង្គជំនុំជម្រះបាទ។

*(ចៅក្រមពិភាក្សាគ្នា)*

**ប្រធានអង្គជំនុំ៖**

យ៉ាងម៉េចទៅលោក ពេជ្រ ជឹម ហើយជាក់ស្តែងគឺលោកអាចឆ្លើយតបនឹងសំណួរដែលសួរបន្តនៅកន្លះម៉ោងទៀតនេះបានដែរឬទេ? បើលោកខិតខំឆ្លើយតបទៅនឹងសំណួរ ហើយភាពចាំបាច់នឹងសំណួរដែលសួរ នោះគឺនឹងអាចកាត់បន្ថយនៅភាពនឿយហត់របស់លោក ទី១។ ទី២ លោកនឹងអាចឆាប់បានវិលត្រឡប់ទៅកាន់លំនៅដ្ឋានរបស់លោកវិញនៅថ្ងៃស្អែក ឲ្យប្រាកដប្រជាថាថ្ងៃស្អែកអាចមួយព្រឹកទៀតអាចចប់តែម្តង។ លោកអាចបន្តផ្តល់សក្ខីកម្មរយៈពេលកន្លះម៉ោងនេះទៀតទេ ឬក៏លោកសុំឈប់សម្រាកត្រឹមប៉ុណ្ណោះសិន ថ្ងៃនេះ?

**លោក ពេជ្រ ជឹម៖**

សូមបន្តកន្លះម៉ោងទៀត ខំឆ្លើយ។

**ប្រធានអង្គជំនុំ៖**

មេធាវីអញ្ជើញសួរតាំងសំណួរបន្តទៀត។

[១៥:៣១:៥៣]

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោក ពេជ្រ ជឹម នៅក្នុងចម្លើយដែលលោកឆ្លើយទៅអ្នកស៊ើបអង្កេតនៃសហចៅក្រម

សុើបអង្កេតនោះ លោកបានធ្វើសេចក្តីសង្កេតមួយចំនួនទាក់ទងទៅនឹង ប៉ុល ពត, តាម៉ុក, សុន សេន ហើយនិង នួន ជា។ ខ្ញុំចង់អានចម្លើយរបស់លោកដែលបានឆ្លើយនៅក្នុងឯកសារ E319.1.18។ ជាចម្លើយរបស់លោកនៅសំណួរចម្លើយ៥៨ សំណួរសួរថាដូចខាងក្រោមនេះ។ ខ្ញុំកែសម្រួល ខ្ញុំនឹង<ចាប់ផ្តើម>ពីសំណួរចម្លើយ៥៦<ងាយស្រួលជាង>៖ "សំណួរ៖ តាមលោកដឹង តើ តាម៉ុក មានសិទ្ធិអំណាចគ្រប់គ្រងភូមិភាគផ្សេងទៀតក្រៅពីភូមិភាគនិរតីដែរឬទេ? ចម្លើយ៖ ពេលដែលមាន<>សភាពការណ៍ផ្ទៃក្នុងដូច្នេះ តាម៉ុក មានសិទ្ធិក្តាប់រហូតដល់ភូមិភាគពាយ័ព្យ។ ក្រោយមកទៀត ភូមិភាគកណ្តាល និងភូមិភាគបូព៌ាមានបញ្ហា តាម៉ុក ក៏មានសិទ្ធិក្តោបក្តាប់ភូមិភាគកណ្តាលនិងភូមិភាគបូព៌ាផងដែរ។ តាមខ្ញុំដឹងគឺ ប៉ុល ពត ជាអ្នកប្រគល់សិទ្ធិឱ្យ តាម៉ុក ហើយជាការងារមូលដ្ឋានរបស់ តាម៉ុក។ សំណួរ៖ តាមលោកដឹង តើ តាម៉ុក ទទួលបញ្ជាផ្ទាល់ពី ប៉ុល ពត ឬទទួលបញ្ជាផ្ទាល់ពី សុន សេន ហៅបង៨៩ ដែលជានាយអគ្គសេនាធិការ? ឆ្លើយ៖ តាម៉ុក ទទួលបញ្ជាផ្ទាល់ពី ប៉ុល ពត។ សំណួរ៖ តើលោកសំអាងអ្វីដែលនាំឱ្យលោកជឿថាតាម៉ុក ទទួលបញ្ជាផ្ទាល់ពី ប៉ុល ពត? ចម្លើយ៖ ព្រោះ តាម៉ុក ជាមនុស្សបន្ទាប់ពី ប៉ុល ពត។ រូបភាពចាត់តាំងទី១ ប៉ុល ពត, ទី២ នួន ជា, ហើយទី៣ គឺតាម៉ុក។ ប៉ុន្តែនៅពេលដែលទទួលបញ្ជាគឺ តាម៉ុក ទទួលបញ្ជាផ្ទាល់ពី ប៉ុល ពត មិនមែនទទួលពី នួន ជា ទេ។ ចំណែក សុន សេន ជាអចិន្ត្រៃយ៍មជ្ឈិមបក្ស តែ<មិន>ស្ថិតនៅក្រោម តាម៉ុក"។ ចប់សេចក្តីដកស្រង់។ សំណួរចំពោះលោកគឺថា <លោក ពេជ្រ ជឹម> នេះហាក់ដូចជា<ការយល់>ដឹង<ដ៏ស៊ីជម្រៅអំពីរចនាសម្ព័ន្ធ>នៃការបញ្ជា។ ថាតើលោកដឹងពីព័ត៌មាននេះដោយរបៀបណា?

**លោក ឌេល លីសាក់៖**

លោកប្រធាន--

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញសហព្រះរាជអាជ្ញារងអន្តរជាតិ!

[១៥:៣៤:៤៤]

**លោក ឌេល លីសាក់៖**

ខ្ញុំចង់កែតម្រូវនៅក្នុងកំណត់<ហេតុ>តុលាការ គឺថា មេធាវីបានអានខុសនៅចំណុចចុងក្រោយ <។ នៅក្នុងប្រតិចារឹក ឬកំណត់ហេតុស្តាប់ចម្លើយ ជាក់ស្តែងលើកឡើង>ថា "<ចំណែក>សុន សេន <ជាអចិន្ត្រៃយ៍មជ្ឈិមបក្ស>"នៅក្រោម តាម៉ុក" <តែលោក>មេធាវីការពារក្តីអានថា "មិននៅក្រោម

តាម៉ុក" <ទៅវិញ> ។

**<លោក វ៉ិចទ័រ កូប៉េះ>**

<ខ្ញុំ>សូមកែតម្រូវ គឺ "នៅក្រោម តាម៉ុក"។ ហើយលោកសាក្សី ចម្លើយរបស់លោក ហាក់ដូចជាលម្អិតណាស់<ទាក់ទងនឹង>ការ<យល់>ដឹងរបស់លោកអំពីរចនាសម្ព័ន្ធអង្គការចាត់តាំងនៅគណៈអចិន្ត្រៃយ៍។ ខ្ញុំសូមសួរលោក ថាតើលោកបានដឹងរឿងនេះដោយរបៀបណា? តាមវិធីណា ដែលថាតាមពិត តាម៉ុក ជាបុគ្គលទី២ បាទ?

**ឆ៖** សូមបញ្ជាក់ ទី៣ មិនមែនទី២ទេ។ បន្ទាប់ពី អ៊ំនួន។ មើលតាមគាត់លើកចាត់តាំង ហើយស៊ើបសួរគេអ្នកយល់ គេដឹងមកហែៗ ពិគ្រោះគ្នាទៅ គេឃើញ គេប្រាប់ថាអ៊ីចឹង។ អ៊ំណាទី១ អ៊ំណាទី២។ អ្នកភ្នំពេញហ្នឹងក៏គេប្រាប់ ប៉ុនមិនបាច់ប្រាប់ឈ្មោះអ្នកណាប្រាប់ៗទេ នៅភ្នំពេញហ្នឹង។ ពីមុនអត់ទេ ដឹងតែមូលទាំងអស់។

**ស៖** សូមអរគុណចំពោះការបំភ្លឺ គឺមានប្រយោជន៍ណាស់។ ប៉ុន្តែសំណួរខ្ញុំសួរថា លោកដឹងដោយរបៀបណា? លោកឮពីមនុស្សផ្សេង ឬក៏លោកមានវិធីណាដែលថាដឹងអំពីព័ត៌មានលម្អិត អំពីទិដ្ឋភាពនៃរចនាសម្ព័ន្ធ<នៃការបញ្ជា>ហ្នឹង<>?

[១៥:៣៦:៤២]

**ឆ៖** អត់ទេ ខ្ញុំសួរអ្នកស្គាល់ មិនប៊ានសួរ តាម៉ុក ទេ។ ខ្ញុំសួរៗ កែ ពក។ គាត់ជាមជ្ឈិម ហើយគណៈភាគ។ សួរ គាត់ប្រាប់គោលៗអ៊ីចឹងមក។ តាម៉ុក ក៏កាលមុននៅភាគ ដល់ឡើងមក អនុមជ្ឈិម អនុទី២។ ពីមុនហ្នឹង ដឹងយ៉ាងម៉េច អត់ដឹងទេ។ ហើយឃើញប្រកាស អ៊ំ សុន សេន -- អ៊ំ អៀង សារី គណៈមជ្ឈិម -- អចិន្ត្រៃយ៍មជ្ឈិម។ ដល់ អ៊ំ សុន សេន អចិន្ត្រៃយ៍មជ្ឈិមត្រៀម។ ហើយអស់ត្រឹមហ្នឹង អស់ត្រឹមគាត់ហ្នឹង រាប់មកប្រាំបីនាក់អស់ត្រឹមហ្នឹង។ មានតែប្រាំតើ ប៉ុល ពត , នួន ជា, តាម៉ុក, អៀង សារី, សុន សេន កាលនុំង ភាគ ហើយគណៈមន្ទីរ។

**ស៖** ខ្ញុំសូមព្យាយាមលើកឧទាហរណ៍មួយទៀត តាមរយៈចម្លើយរបស់លោកជូន<អ្នកស៊ើបអង្កេតនៃការិយាល័យ>សហចៅក្រមស៊ើបអង្កេត <ក្នុងឯកសារ> E319.1.18 នៅក្នុងសំណួរចម្លើយ៩៥ លោកឆ្លើយដូចតទៅ លោកនិយាយថា៖ "<សំណួរ៖>សុន សេន នៅក្រោម តាម៉ុក។ តាមដែលលោកដឹង តើ តាម៉ុក ជាអ្នកចាត់តាំង មាស មុត ឲ្យធ្វើជាលេខាកងពល២ដែរឬទេ? <ចម្លើយ៖> ខ្ញុំមិនគិតដូច្នេះទេ ព្រោះនៅខាងមជ្ឈិមដែលទទួលខុសត្រូវខាង<យោធា>ជាអ្នកសម្រេច ហើយអ្នក

ទទួលខុសត្រូវខាង<យោធា> មាន សុន សេន, តាម៉ុក និង ប៉ុល ពត។ពុំមានអ្នកណាម្នាក់អាចសម្រេចបាននោះទេ <គឺត្រូវសម្រេចទាំងអស់គ្នា>។ ខ្ញុំសូមបញ្ជាក់ឡើងវិញថា ខ្ញុំ<>មិនដឹង<ចម្លើយ>ចំពោះសំណួរនេះ<ទេ> ព្រោះ<ខ្ញុំដឹង>មិនច្បាស់”<>។ សំណួរ៖<> តើលោកដឹងថា មាស មុត <អាច>ជា<សមាជិកជំនួយ>គណៈ<យោធារបស់>កងទ័ព<បដិវត្តន៍>កម្ពុជាដែរឬទេ? ចម្លើយ៖ <ដំបូង>ខ្ញុំមិនដឹងទេ <តែ>ខ្ញុំដឹងនៅពេលក្រោយ<ទៀត>។ ខ្ញុំ<>បានឃើញ មាស មុត នៅក្នុងកុនមួយ<>។ ក្រោយមក ខ្ញុំលួចសួរអ្នកដែលធ្លាប់ធ្វើការ<ជាន់ខ្ពស់>នៅក្នុងកងទ័ព ទើបគេប្រាប់ថា មាស មុត ជាសមាជិកជំនួយគណៈយោធារបស់កងទ័ពបដិវត្តន៍កម្ពុជា”។ <ជាថ្មីម្តងទៀត លោក ពេជ្រ ជឹម> នេះគឺជាការដឹងលម្អិតរបស់លោកអំពីរចនាសម្ព័ន្ធនៃថ្នាក់លើ<បំផុត>របស់បក្សកុម្មុយនីស្តកម្ពុជា។ តើលោកអាចរៀបរាប់លម្អិតបន្តិចបានទេ លោកដឹងពីរចនាសម្ព័ន្ធនេះ<>តាមរយៈអ្វីដែរ?

[១៥:៣៩:៥០]

**ឆ៖** សួរ ខ្ញុំសួរ សួរហើយពិភាក្សាគ្នា អ្នកដែលគេយល់ៗ។ អ្នកធ្លាប់ស្គាល់អ៊ំៗពីដើមមក ដូចបងបឿន ដែរ។ បងពក សួរច្រើន ពក គាត់ប្រាប់ខាងលើហ្នឹង។ មានប៉ុណ្ណឹង។ សួរហើយ ស៊ើបសួរ។

**ស៖** ខ្ញុំយល់ហើយលោក ប៉ុន្តែតើលោក សុំលោកពន្យល់មកជូនតុលាការ <ហេតុអ្វី>លោក<ពិតជាមិន>ដឹង<អំពី> សោ ភឹម, រស់ ញឹម ឬក៏ ហេង សំរិន -- ឬក៏មានមូលហេតុអីដែលថាលោកមិនស្គាល់អ្នកទាំងនេះ ឬក៏លោកមានបំណងមិនចង់និយាយអំពីអ្នកទាំងនេះ?

**ឆ៖** នៅឆ្ងាយគ្នា ហេង សំរិន។ សោ ភឹម ក៏ឆ្ងាយ ខ្ញុំនៅនោះ ខ្ញុំទើបតែមកក្រោយរំដោះហើយ។ ចេះថាស្គាល់ៗ បើអត់ស្គាល់ ពិបាកថាដែរ។ សូមអស់។

**ស៖** ខ្ញុំយល់ហើយថាលោកអាចមិនស្គាល់ពួកគាត់ទាំងនោះដោយផ្ទាល់ទេ។ ប៉ុន្តែបើខ្ញុំសុំឱ្យគិតបន្តិចមើល តើលោកដឹងអំពី សោ ភឹម, រស់ ញឹម, ជូ ជេត, វន វ៉េត ដែរឬទេ? តើលោកអាចរៀបរាប់ជូនតុលាការអំពីអ្នកទាំងនេះបានទេ?

[១៥:៤១:៤៨]

**ឆ៖** អត់បានទេ ព្រោះខ្ញុំនៅខាងនោះ មករៀបរាប់នេះ អត់បាន ហើយខ្ញុំទើបស្គាល់។ ដែលនៅបូព៌ាហ្នឹង សោ ភឹម ហើយនិង រស់ ញឹម។ ខ្ញុំពីរហ្នឹងច្រឡំគ្នាផង។ ហើយគាត់ -- អត់ដែលជួបរលីងមកដល់គាត់ស្លាប់។ ហើយចេះតែបង្ខំឱ្យឆ្លើយម៉េច! សូមអស់ហើយ។

**ស៖** សូមអរគុណលោក ពេជ្រ ជឹម ខ្ញុំចូលទៅប្រធានបទមួយថ្មីទៀត។ គឺការដឹងរបស់លោក

ចំពោះអ្វីដែលបានកើតឡើង <ទាក់ទងនឹង>បញ្ហាចំណីអាហារ សុខភាព <ការអប់រំ>ជាដើម។ល។ នៅក្នុងស្រុក<ផ្សេងទៀត>នៅក្នុងតំបន់១៣។ តើលោកអាចជម្រាបជូនតុលាការបាន<ទេ>ថាតើមានអ្វីកើតឡើងនៅកន្លែងលោក នៅចន្លោះពី៧៥ ទៅដល់ ៧៩? ឧទាហរណ៍ដូចជាលោកប្រហែលជាលោកបាននិយាយជាមួយលេខាស្រុក<ផ្សេងទៀត> តើលោកអាចជម្រាបឱ្យបានលម្អិតអំពីស្ថានភាពចំណីអាហារនៅក្នុងស្រុក<ផ្សេងទៀត>ក្នុងតំបន់១៣ នេះបានទេ?

**ឆ៖** តាមពិតគឺនិយាយបានជាគោល។ ១០៥ មានស្រូវ ដំឡូង ប៉ុណ្ណឹងហើយ ចុះកោះអណ្ដែតបានអី? ទ្រាំងបានអី? គិរីវង់គេមានដំឡូងដែរ ហ្នឹងទុកគេគ្រាន់បើចុះ។ អង្គរជ័យ ក៏គេមានដីឯក្រោយដាំដំឡូងដែរ។ ចុះកោះអណ្ដែត ហើយទ្រាំង? ច្បាស់ជាយ៉ាប់ជាងគេ ហើយកាលនោះ មានជួយ។ សោម ស៊ុំ ក៏ជួយអង្ករ ជូនហែ១ ១០បាវ ១៥បាវ ហ្នឹងជាក់ស្ដែងអ៊ីចឹង។ ពិគ្រោះគ្នាជាមួយ ខុម ហើយ ចែកគ្នារស់ ជាបបរទន់នេះ ក៏ឱ្យគ្នាបាននោះផង។ ឯកភាពគ្នា ទាំងឃុំទាំងអស់ទៅ គេព្រម ជូនទៅ។ នេះអត់ហើយ កូនយើងអត់ ប្រជាជនថ្មី ប្រជាជនចាស់ទាំងអស់ហ្នឹង ហូបបបរហើយ ប៉ុន្តែនៅទៅជួយគេ។ ខ្មែរយើងថា “តស៊ូទាន់គ្រាក្រ ជួយគ្នាទាន់គ្រាក្រ” ហូបបបរដូចតែគ្នាទៅ។ ក្នុងស្មារតីជំហរអ៊ីចឹង សូមជម្រាបប៉ុណ្ណឹង។

**ស៖** ទាក់ទងទៅនឹងការអនុវត្តគោលនយោបាយបក្សនៅចំពោះមុខអង្គជំនុំជម្រះនេះ គឺយើងផ្ដោតទៅលើព្រឹត្តិការណ៍នៅក្នុងស្រុក១០៥ ប៉ុន្តែខ្ញុំគិតថាវាក៏ជាតម្រុយមួយដ៏ល្អដែរប្រសិនណាជាលោកអាចធ្វើការប្រៀបធៀបទៅនឹងការសម្រេចបានលទ្ធផល<ឬការមិនសម្រេចបានលទ្ធផល>នៅក្នុងស្រុក១០៥<ជាមួយនឹងស្រុកផ្សេងទៀត>នៅក្នុងតំបន់១៣។ តាមការជួបពិភាក្សាជាមួយថ្នាក់ដឹកនាំស្រុកតើលោកអាចប្រៀបធៀបមើលថានៅក្នុងស្រុក<ទាំង>នេះគេអនុវត្តគោលនយោបាយរបស់បក្សហ្នឹងបានកម្រិតណាដែរ?

[១៥:៤៦:០៨]

**ឆ៖** តាមវិភាគ ពិនិត្យមក ពិគ្រោះគ្នាទៅឃើញថា ទាំងផ្ទាល់ខ្លួន ទាំងពិគ្រោះគ្នាក្នុងការអនុវត្តគោលការណ៍របស់បក្ស គឺបានជាមធ្យម មិនមែនថាល្អឯកទេ ល្អជាមធ្យម។ ឃើញកម្រិតប៉ុណ្ណឹង។

**ស៖** តើលោកដឹងទេ តើប្រជាជនអត់ឃ្លានទេនៅក្នុងស្រុក១០៦, ១០៧, ១០៨, ១០៩?

**ឆ៖** ដូចគ្នា អត់ឃ្លានដូចគ្នា។

**ស៖** ចុះចំពោះសេចក្ដីសម្រេចផ្សឹកលោកសង្ឃ តើលោកដឹងថា ការចាប់ផ្សឹកលោកសង្ឃនេះ

---

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឱ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

កើតមានឡើងនៅស្រុក១០៦, ១០៧, ១០៨, ១០៩ ដែរទេ?

**ឆ៖** ខ្ញុំមិនចាំ។ កាលនោះ លោកមកនៅនេះចង់អស់ហើយ។ មនុស្សទៅវិញ ដូចគ្មានលោកទៅទេ។ គ្រប់ស្រុក មូលមក១០៥ អាចខ្លះនៅអង្គរជ័យ។ ហើយអ៊ីចឹងវិធានការ ផែនការគឺទាំងអស់ចង់នៅឯណាក៏ដោយគឺទាំងអស់។ សូមអស់។

**ស៖** និយាយ<អំពី>គោលនយោបាយចំពោះលោកសង្ឃ តើលោកដឹងថាមាន<សេចក្ដីបង្គាប់ ឬ>ការបញ្ជា<>ណាមួយនៅក្នុងឯកសារទង់បដិវត្តនោះ ទស្សនាវដ្ដីទង់បដិវត្ត ពេលណានិយាយអំពីការប្រព្រឹត្តមកលើព្រះសង្ឃ ការប្រព្រឹត្តចំពោះព្រះពុទ្ធសាសនា តើមានគោលការណ៍<ចម្បង>ណាមួយ<ត្រូវបាន>សរសេរនៅត្រង់<ផ្នែក>ណាមួយនៃទស្សនាវដ្ដីទង់បដិវត្តដែរឬទេ?

[១៥:៤៨:៣៨]

**ឆ៖** កាលនោះបានមើលមួយសា ទង់នោះដូចមិនចប់ផង រវល់ពេក អត់ចាំ អត់ចាំថាមាន ឬមិនមាន។

**ស៖** ត្រឡប់ទៅនិយាយអំពីទស្សនាវដ្ដីទង់បដិវត្តលោកបានឆ្លើយថា លោកបានអានទស្សនាវដ្ដីទង់បដិវត្តចន្លោះពីឆ្នាំ១៩៧៥ ទៅ ឆ្នាំ១៩៧៩។ តើទស្សនាវដ្ដីទង់បដិវត្តក៏មានន័យថាជាការជួយ<> ប្រកាសប្រាប់អំពីគោលនយោបាយរបស់បក្សទៅដល់ថ្នាក់ស្រុក ថ្នាក់តំបន់នោះដែរទេ?

**ឆ៖** មានទង់ ហ្នឹងគឺមានប្រកាស ហើយរំឭកគោលនយោបាយឲ្យកម្មាភិបាលមួយៗ ធ្វើឡើងវិញ។ ប៉ុន្តែកន្លងមក ដល់ខំសម្រុកពេកទៅភ្លេចមើលក្បួន។ ហ្នឹងជម្រាបត្រង់អ៊ីចឹង ទុកគរលើហឹង។ មិនត្រឹមមិនធ្វើ ទុកលើហឹងទេ ធ្វើឲ្យខុសទេ គ្រាន់ថាវារវល់ អត់បានតម្រង់ រំឭកខួរក្បាលឲ្យ លាងវាឲ្យបានញើកញាប់ខ្វះខាតត្រង់ហ្នឹង។ សូមអស់។

**ស៖** តើលោកធ្លាប់បានឃើញការប្រកាសជាគោលនយោបាយណាមួយនៅក្នុងទស្សនាវដ្ដីទង់បដិវត្ត អំពីការរៀបការនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យនេះដែរឬទេ? ហើយថាតើត្រូវធ្វើយ៉ាងម៉េចពាក់ព័ន្ធទៅនឹងគោលនយោបាយស្ដីពីការរៀបការនេះ?

**ឆ៖** កាលនោះស្ទើរតែមិនបានចាំ។ ដឹងជាគោលៗហើយ ប៉ុន្តែទៅចាំលម្អិតនោះអត់ទេ។ ដឹងថាមានពីច្បាប់រៀបការអីនៅក្នុងទង់។ ទៅមើលហើយធ្វើ សម្រួលទៅ។ ដូចខ្ញុំនិយាយខាងដើមអ៊ីចឹង ធ្វើបានកម្រិតហ្នឹង។ សូមអស់។

**ស៖** ត្រឡប់ទៅនិយាយអំពីបញ្ហាព្រះពុទ្ធសាសនា តើលោកមាននៅចាំអ្វីខ្លះក្រោយពីបានអាន

គោលនយោបាយពាក់ព័ន្ធទៅនឹងព្រះពុទ្ធសាសនានៅក្នុងទង់បដិវត្តក្នុងរបបកម្ពុជាប្រជាធិបតេយ្យ?

[១៥:៥២:០៩]

**ផ៖** បានមើលបានគិតពិចារណា ប៉ុន្តែមិនទៅយកនិយាយជាមួយគេទេ គិតតែខ្លួនឯង។ គិតពិចារណាថា តើព្រះពុទ្ធសាសនាប៉ះពាល់អីដល់បដិវត្តន៍ ចេះតែគិតឃើញ ថាមិនជាប៉ះពាល់អីទេ ប៉ុន្តែធ្វើម៉េចបានអីចឹង? ព្រះពុទ្ធសាសនាស្លូតពេក។ ហ្នឹងពាក្យថាក្រៅ មិនថាអ្នកណាៗទេ ស្លូតពេក សម្មាសម្មា ជាងពីរពាន់ឆ្នាំហើយអត់បានអី អស់ទឹកអស់ដី។ ចេះតែគិតទៅ និយាយចំគិតខ្លួនឯង។ ដូចនេះឃើញថាវាមិនប៉ះពាល់ វាល្អ បើទុកវាល្អ។

**ស៖** នៅក្នុងស្រុករបស់លោក តើលោកមានដែលបញ្ហាមិនឲ្យប្រជាជនគោរពប្រតិបត្តិព្រះពុទ្ធសាសនាដែរទេ?

**ផ៖** អត់ទេ អ្នកណាគេគោរពៗទៅ អ្នកណាគេដុតធូប ដុតទៅ អ្នកណាថ្វាយបង្គំថ្វាយទៅរឿងគេ។

**ស៖** តើលោកមានដែលដឹងហេតុការណ៍ណាមួយដែលគេធ្វើទោសទណ្ឌទៅដល់ប្រជាជនណាមួយ ដែល<គោរពប្រតិបត្តិ>ព្រះពុទ្ធសាសនានៅក្នុងស្រុករបស់លោកហ្នឹងដែរទេ?

**ផ៖** មិនមាន។

[១៥:៥៤:៣០]

**ស៖** លោក ពេជ្រ ជឹម ខ្ញុំចាំថាមានសាក្សីពីរនាក់ បានមកផ្តល់សក្ខីកម្មថា នៅក្នុងឆ្នាំ១៩៧៥ សាក្សីទាំងនោះបានឃើញការ<វាយកម្ទេច>រូបសំណាកព្រះពុទ្ធ<នៅក្នុងវត្ត>។ តើលោកធ្លាប់ឮពីបញ្ហានេះទេ?

**ផ៖** ឮ។ ខ្ញុំបានពាក់ព័ន្ធជូនហើយតើ។ រំសាយ បំបាត់ចោលជាទូទៅ ជារួម។ ខុម គាត់អ្នកផ្សាយ។ ខ្ញុំអត់មាត់ៗ ដោយចិត្តមិនពេញចិត្ត មិនមែនអត់មាត់ ហើយទៅច្រងេងច្រងាង។

**ស៖** ខ្ញុំខ្លាចតែខ្ញុំយល់ចម្លើយរបស់លោកមិនបានច្បាស់លាស់។ អ្នកណាទទួលខុសត្រូវក្នុងការវាយកម្ទេចរូបសំណាកព្រះពុទ្ធហ្នឹង លោកដឹងទេ? ខ្ញុំឮថាលោកឆ្លើយជាភាសាខ្មែរ ប៉ុន្តែសូមលោកឆ្លើយម្តងទៀត នៅពេលដែលក្បាលមីក្រូលោកវាមានភ្លើង។

**ផ៖** អត់ទេ។ ខ្ញុំមិនបានដឹងអ្នកណាអ្នកវាយកម្ទេចព្រះពុទ្ធរូប នៅក្នុងស្រុក១០៥ទេ។

**ស៖** លោកដឹងទេ អ្នកណាជាអ្នកដែលបានបញ្ជាឲ្យវាយកម្ទេចរូបសំណាកព្រះពុទ្ធហ្នឹង?

និយាយ ទាក់ទងទៅនឹងអ្នកបញ្ជា លោកដឹងថាអ្នកណាជាអ្នកបញ្ជាដែរអ៊ីចឹង?

**ឆ៖** ខ្ញុំនិយាយមកយូរហើយ។ ប្រធានបក្សណែនាំឲ្យធ្វើ ប៉ុនខ្ញុំមិនពេញចិត្ត ខ្ញុំអត់ធ្វើ។ ប៉ុនខ្ញុំអត់ប្រឆាំង ខ្ញុំនៅស្ងៀម ស្របអំពើគេធ្វើ ទៅតាមដានសួរអ្នកណាធ្វើ អ្នកណាមិនធ្វើអី អ្នកណាអី ចាំមុខមាត់គេ ខ្ញុំអត់គិត។ ការប្រជុំហ្នឹង គណៈទាំងអស់ហ្នឹង ខុម, តាគាវ, ញ៉េវ ទាំងអស់ហ្នឹង។

[១៥:៥៧:៣៦]

**ស៖** ហើយអ្នកណាជា<>ប្រធាន ជាមេទទួលខុសត្រូវក្នុងការប្រជុំសម្រេច វាយកម្ទេចព្រះពុទ្ធសាសនាហ្នឹង? ហើយគេមានដាក់ទណ្ឌកម្មចំពោះអំពើអ្នកទាំងនេះទេ?

**ឆ៖** គឺបក្សហ្នឹង មាន ខុម ហ្នឹងប្រធានបក្ស, តាគាវ អនុ, ញ៉េវ សមាជិក។

**ស៖** ប៉ុន្តែលោកដឹងទេថា អ្នកទាំងនោះសម្រេចវាយកម្ទេចព្រះពុទ្ធសាសនា ដោយមានការណែនាំពី<>ថ្នាក់លើអីដែរឬទេ ឬក៏ធ្វើដោយខ្លួនឯង<គ្មានការអនុញ្ញាតពីថ្នាក់លើ>?

**ឆ៖** ដឹងតែគេធ្វើហ្នឹង ដោយមានការណែនាំពីលើ មិនមែនធ្វើដោយខ្លួនឯងទេ អ្នកធ្វើហ្នឹង។

**ស៖** <>លោកថាមានអ្នកណែនាំ <តើជា>អ្នកណា សូមលោកបញ្ជាក់ឈ្មោះផងបានទេ?

**ឆ៖** ប្រកាសប្រជុំហ្នឹង ខុម ប្រធានបក្ស ឲ្យរំលាយព្រះពុទ្ធរូបចោល។ ឃុំ យកទៅអនុវត្តរៀបរយធ្វើតាមហ្នឹងទៅ។ ឃុំយកទៅ មិនដឹងគេចាត់តាំងអ្នកណាខ្លះ ហើយអ្នកប្រាប់ឲ្យធ្វើ ខុម ហ្នឹងប្រធានបក្ស រួមជាមួយ តាគាវ, ជាមួយ ញ៉េវ ទាំងអស់ហ្នឹង ឯកភាពគ្នា បានថាកើត។

[១៥:៥៩:៤៥]

**ស៖** លោកដឹងទេ ថាហេតុអ្វីបានជានៅភ្នំពេញនេះ មិនមានរបាយការណ៍ពាក់ព័ន្ធទៅនឹងការវាយកម្ទេចរូបសំណាក់ព្រះពុទ្ធ <និងវត្តអារាម>?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប!

សូមអញ្ជើញលោកសហព្រះរាជអាជ្ញារងអន្តរជាតិ!

**លោក ឌេល លីសាក់៖**

ខ្ញុំសូមជំទាស់ ដោយសារមេធាវីសួរសំណួរនាំមុខ ហើយ<>គាត់ក៏<>បែរជា<ធ្វើ>សក្ខីកម្មដោយខ្លួនគាត់ទៅឲ្យសាក្សីវិញ។ <ខ្ញុំមិនដឹងអំពីមូលដ្ឋាននៃការអះអាងផ្នែកនេះទេ ប៉ុន្តែមេធាវី>មិនគួរសួរសំណួរនាំមុខ <និងផ្ដល់សក្ខីកម្ម>បែបនេះទេ។

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** ខ្ញុំសូមរៀបចំសំណួរឡើងវិញ។ លោក ពេជ្រ ជឹម លោកមានបានដឹង<ថាមានអ្វីកើតឡើង ចំពោះ>ព្រះពុទ្ធរូប <និងវត្តអារាម>នៅក្រុងភ្នំពេញ<នៅចន្លោះឆ្នាំ១៩៧៥ និង១៩៧៩ ដែរឬទេ?>

[១៦:០១:០៧]

**លោក ពេជ្រ ជឹម៖**

**ឆ៖** ខ្ញុំឆ្លើយអត់បាន។ ព្រះពុទ្ធរូបនោះ ប៉ះពាល់មកភ្នំពេញនេះម៉េច ខ្ញុំមិនយល់។ សូមប្រធាន ពន្យល់ខ្ញុំមក គាត់និយាយស្រួលចាំ ស្រួលស្តាប់។ សូមប្រធានចុះ។

**ប្រធានអង្គជំនុំ៖**

បាទ គាត់ចង់ដឹងពីរឿងថា តើលោកដឹងរឿងរ៉ាវទាំងឡាយដែលពាក់ព័ន្ធជាមួយនឹងការប្រព្រឹត្ត ទាំងឡាយប៉ះពាល់ទៅលើព្រះពុទ្ធសាសនា បានន័យថាលើពុទ្ធរូប ទៅលើវត្តអារាមអីនៅទីក្រុងភ្នំពេញ ដែរឬទេ នៅក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ?

**លោក ពេជ្រ ជឹម៖**

**ឆ៖** វាប៉ះ ប៉ះមួយប្រទេសតែម្តង មិនមែនអត់ប៉ះទេ ប៉ះព្រះពុទ្ធនេះ ប៉ះព្រះពុទ្ធសកលលោក។ ចិនក៏មានព្រះពុទ្ធ សៀមក៏មានព្រះពុទ្ធ ឥណ្ឌាក៏មានព្រះពុទ្ធដែរ។ ប៉ះទាំងអស់ ប៉ះសកលលោក។ ខ្ញុំ ឆ្លើយប៉ុណ្ណឹង។

[១៦:០២:៣០]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោក វ៉ិចទ័រ កូប៉េ។ អរគុណលោក ពេជ្រ ជឹម។

បាទ សវនាការនៅថ្ងៃនេះ ដល់ពេលឈប់សម្រាកហើយ អង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរ សវនាការសម្រាប់ថ្ងៃនេះ ត្រឹមនេះ។ សវនាការលើកទៅបន្តនៅថ្ងៃស្អែក ថ្ងៃសុក្រ ទី២៤ ខែមេសា ឆ្នាំ ២០១៥ ចាប់ផ្តើមពីម៉ោងប្រាំបួនព្រឹក។ សវនាការនៅថ្ងៃស្អែកនេះ អង្គជំនុំជម្រះនឹងធ្វើសវនាការបន្ត ស្តាប់សក្ខីកម្មសាក្សី ពេជ្រ ជឹម សូមភាគីជ្រាប និងអញ្ជើញចូលរួមតាមពេលវេលាបានកំណត់នេះ។

អង្គជំនុំជម្រះសូមអរគុណលោក ពេជ្រ ជឹម ដំណើរការសវនាការស្តាប់សក្ខីកម្មរបស់លោកក្នុង ឋានៈជាសាក្សីនៅមិនទាន់ចប់នៅឡើយទេ។ អង្គជំនុំជម្រះកោះអញ្ជើញលោកមកបន្តផ្តល់សក្ខីកម្មនៅថ្ងៃ ស្អែកទៀត ដែលនឹងចាប់ផ្តើមពីម៉ោងប្រាំបួនព្រឹកទៅ។ ហើយនាពេលនេះលោកអាចចាកចេញត្រឡប់

ទៅកាន់កន្លែងស្នាក់នៅបានហើយ។

អង្គជំនុំជម្រះអរគុណចំពោះលោកមេធាវី ម៉ម រិទ្ធា ជាមេធាវីប្រឹក្សាសាក្សី ហើយអង្គជំនុំជម្រះក៏សូមអញ្ជើញមេធាវីប្រឹក្សាសាក្សីមកចូលរួមប្រឹក្សានៅក្នុងអំឡុងស្តាប់សក្ខីកម្មសាក្សីរូបនេះ នៅថ្ងៃស្អែកដែរ ដែលចាប់ផ្តើមពីម៉ោងប្រាំបួនព្រឹក។

មន្ត្រីរដ្ឋបាលសម្របសម្រួលជាមួយនឹងមន្ត្រីនៃអង្គភាពគាំពារសាក្សី និងអ្នកជំនាញ ក្នុងការជូនលោក ពេជ្រ ជឹម វិលត្រឡប់កាន់ទៅកន្លែងដែលគាត់ស្នាក់នៅវិញចុះ និងសូមឲ្យអញ្ជើញគាត់មកចូលរួមសវនាការនៅក្នុងបន្ទប់សវនាការនេះវិញ នៅព្រឹកថ្ងៃស្អែកឲ្យបានមុនម៉ោងប្រាំបួន។

បង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទទាំងពីររូប នួន ជា និង ខៀវ សំផន ត្រឡប់ទៅកាន់មន្ទីរឃុំឃាំងនៃ អ.វ.ត.ក វិញចុះ និងបង្គាប់ឲ្យនាំខ្លួនពួកគាត់ទាំងពីររូបត្រឡប់មកចូលរួមសវនាការវិញ នៅព្រឹកថ្ងៃស្អែកឲ្យបានមុនម៉ោងប្រាំបួន។

សម្រាកចុះ៕

*(សវនាការផ្អាកនៅម៉ោង ១៦:០៤ នាទី)*

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*